ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# សួនបន្លែគ្រួសារ



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា_អូស្ត្រាលី

**រៀបរៀងដោយ : លោក ម៉ុង វណ្ណឌី**

**នាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម**

ទូរស័ព្ទ : ០១២ ៨២៨៧២១


**កាលបរិច្ឆេទ : ខែ កក្កដា ឆ្នាំ ២០០៦**


© រក្សាសិទ្ធិគ្រប់យ៉ាង : គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ននិងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជា បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មានបច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើ ប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម តាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តា នុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៏ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើ ផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និង អ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាលនិង ផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។ បអប មានលក្ខណៈដូចខាងក្រោមនេះ :-

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មាន សំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធ កេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៏នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា ។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារបអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់ នៅតាមមូលដ្ឋាន ។

# មាតិកា

I- ប្រតិទិនរដូវកាលដាំដុះ ........................................ ២
១- អំពីរដូវកាលដាំដុះដំណាំបន្លែ ........................................ ២
១.១- ដំណាំរដូវវស្សា ........................................ ២
២- ដំណាំរដូវប្រាំង ........................................ ៤
២- កត្តាសំខាន់ៗនាក់ទង និងការដាំដុះបន្លែក្នុងសួន ........................................ ៧
២.១- ការបែងចែកតំបន់សម្រាប់ដាំដុះដំណាំបន្លែ ........................................ ៧
២.១.១- តំបន់ខ្ពង់រាប ........................................ ៧
២.១.២- តំបន់វាលរាប ........................................ ៧
២.១.៣- តំបន់វាលទំនាប ........................................ ៧
២.២- ប្រភពទឹក និងការកែប្រែគុណភាពទឹក ........................................ ៨
២.២.១- ប្រភពទឹកធម្មជាតិ ........................................ ៨
២.២.២- ប្រភពទឹកក្រោមដី ........................................ ៨
២.២.៣- ការកែប្រែគុណភាពទឹកមានកំណកដីឥដ្ឋ ........................................ ៨
២.២.៤- របៀបកែច្នៃទឹកក្រោមដី ........................................ ៩
២.៣- ការប្រើប្រាស់ដីលើដំណាំនីមួយៗ ........................................ ៩
២.៣.១- ដំណាំដែលធន់ទ្រាំខ្លាំងលើដីអាស៊ីត ឬដីជូរ :........................................ ៩
២.៣.២- ដំណាំធន់ទ្រាំមធ្យមលើដីអាស៊ីដ ឬដីជូរ :........................................ ៩
២.៣.៣- ក្រុមដំណាំធន់ទ្រាំខ្សោយលើដីអាស៊ីដ ឬដីជូរ :........................................ ១០
២.៤- ការកែប្រែជីជាតិដី ........................................ ១០
២.៤.១- ប្រភេទដីល្បាយខ្សាច់ ........................................ ១១
២.៤.២- ប្រភេទដីឥដ្ឋ ........................................ ១១
២.៥- ការរៀបចំដីសម្រាប់ដំណាំបន្លែ........................................ ១១
៣- ដំណើរការដាំដុះពេញមួយឆ្នាំ និងការឆ្លាស់មុខដំណាំ ........................................ ១២
៣.១- ការដាំពេញមួយឆ្នាំ ........................................ ១២
៣.២- ការដាំឆ្លាស់មុខដំណាំ ........................................ ១៣
II- ប្រភេទពូជបន្លែ ដែលអាចដាំក្នុងសួន និង ការរក្សាទុកបន្ត ........................................ ១៤
១- ពូជដំណាំដែលរកបានក្នុងមូលដ្ឋាន និង ប្រភេទពូជមកពីតំបន់ផ្សេង ........................................ ១៤
១.១- ពូជដំណាំដែលកសិកររកបានក្នុងមូលដ្ឋានផ្ទាល់ ........................................ ១៤
១.២- ពូជដែលបានមកពីតំបន់ផ្សេងៗ ........................................ ១៥
២- ការរក្សាទុកពូជបន្ត ........................................ ១៥
២.១- ប្រភេទពូជដំណាំទុំមិនស្ងួត ........................................ ១៥
២.២- ប្រភេទពូជដំណាំទុំស្ងួត........................................ ១៦
២.៣- វិធីសាស្ត្ររក្សាទុកគ្រាប់ពូជ........................................ ១៧
២.៤- គុណវិបត្តិនៃការទុកពូជបន្ត ........................................ ១៩
៣- ប្រភេទដំណាំដែលមិនដាំដោយគ្រាប់ ........................................ ១៩
៣.១- ការដាំឬបន្តពូជដោយគល់ និង មើម........................................ ១៩

៣.២-ការដាំដោយដើម ឬកំណាត់ទង ........................................ ១៩

**III-ការរៀបចំសួនបន្លែគ្រួសារ** ........................................ ២១

១-ទីតាំង និងទំហំសួន ........................................ ២១

២-របៀបធ្វើសួនបន្លែ ........................................ ២២

៣-ការរៀបចំដីក្នុងសួន ........................................ ២៣

៤-ការដាំ និងថែទាំដំណាំក្នុងសួន ........................................ ២៤

៥-គំរូការគ្រាប់ពូជសម្រាប់ដាំដុះ ........................................ ២៤

**IV-ការគ្រប់គ្រងជំងឺ-សត្វល្អិត និងការការពារ** ........................................ ២៧

១-អំពីជំងឺសំខាន់ៗ និងការការពារ ........................................ ២៧

១.១-ក្រុមជំងឺផ្សិត ........................................ ២៧

១.១.១-ជំងឺរលួយគល់កូនដំណាំ (Damping-off) ........................................ ២៧

១.១.២-ជំងឺផ្សិតគល់ ........................................ ២៨

១.១.៣-ជំងឺផ្សិតលើស្លឹក និង ផ្លែ ........................................ ២៩

១.២-ក្រុមជំងឺវីរុស ........................................ ៣១

១.២.១-ការឆ្លងតាមរយៈគ្រាប់ពូជ ........................................ ៣១

១.២.២-ការឆ្លងតាមបរិស្ថាន ........................................ ៣១

១.២.៣-ការឆ្លងតាមសត្វល្អិតជាភ្នាក់ងារបង្ករោគ ........................................ ៣១

១.៣-ក្រុមជំងឺបង្កដោយបាក់តេរី ........................................ ៣៤

២-អំពីសត្វល្អិតចង្រៃសំខាន់ៗ ........................................ ៣៦

២.១-ដង្កូវយោលទោង (Diamond back moth) ........................................ ៣៧

២.២-សត្វខាគួរ (Flea beetle Leaf) ........................................ ៣៧

២.៣-ដង្កូវស៊ីញៀ ឬ ដង្កូវផែនទី (Leaf miner) ........................................ ៣៨

២.៤-ដង្កូវស៊ីរូងក្បាលសណ្តែក ........................................ ៣៩

២.៥-រុយទិចផ្លែ ឬហៅថា ស្រាំងអុច (Fruit fly) ........................................ ៣៩

**V-ការបង្កើនជីជាតិដី សម្រាប់ដំណាំបន្លែ** ........................................ ៤០

១-ប្រយោជន៍នៃជីកំប៉ុស្តិ៍ ........................................ ៤០

១.១-ប្រភេទជីកំប៉ុស្តិ៍ស្ងួត ........................................ ៤០

១.២-ប្រភេទជីកំប៉ុស្តិ៍រាវ ........................................ ៤១

២-ប្រយោជន៍នៃជីលាមកសត្វ ........................................ ៤១

២.១-លាមកគោ និងក្របី ........................................ ៤១

៣-ប្រយោជន៍នៃស្រកីដូង ........................................ ៤២

៤-ការដាំផ្លាស់មុខដំណាំ ........................................ ៤២

៥- ការវិភាគសេដ្ឋកិច្ច : ........................................ ៤៥

**VI-ផែនការ និងវិធីសាស្ត្រផ្សព្វផ្សាយ** ........................................ ៤៧

១-ការទំនាក់ទំនងអាជ្ញាធរមូលដ្ឋាន ........................................ ៤៧

២-របៀបជ្រើសរើសកសិករជាដៃគូ ........................................ ៤៧

៣-ការកំណត់ជាអាទិភាព នៃគ្រួសារជាដៃគូ ........................................ ៤៨

៤- ការរៀបចំសួនតាមលំនៅដ្ឋាន ........................................ ៤៨

៥-ការណែនាំអនុវត្តជំហានដំបូង ........................................ ៤៨
៦- ការបណ្តុះបណ្តាលជាក្រុម ........................................ ៤៩
៧-ថវិកាសម្រាប់ការធ្វើបង្ហាញ ........................................ ៥១
ឧបសម្ព័ន្ធៈ ការជម្រើស និង ប្រើប្រាស់បន្លែសំបូរជីវជាតិ ........................................ ៥៣
១-ការបែងចែកក្រុមបន្លែ ........................................ ៥៣
២-ការប្រើប្រាស់បន្លែនីមួយៗ........................................ ៥៤
៣-សារធាតុសំខាន់ៗដែលសរីរាង្គមនុស្សត្រូវការ........................................ ៥៧

## សេចក្តីសង្ខេប:

**បញ្ហា** : ប្រជាកសិករទូទាំងប្រទេសភាគច្រើន មិនបានរៀបចំគ្រប់គ្រងសួនបន្លែគ្រួសារអោយមានប្រសិទ្ធិភាព ខ្វះបច្ចេកទេសដាំដុះ និង វិធានការការពារ គ្រប់គ្រងលើកត្តាចង្រៃ ។

**គោលដៅ** : ដើម្បីបង្កើនផលិតកម្ម និងឱ្យមានបន្លែបរិភោគគ្រប់រដូវ ដោយមិនប៉ះពាល់ដល់សុខភាព កាត់បន្ថយការចំណាយពេលវេលា និងថវិកាក្នុងគ្រួសារ ។

**វិធីសាស្ត្រ** : ១- រៀបចំសួនបន្លែដែលស្ថិតនៅក្បែរផ្ទះ ឬក្រោយផ្ទះអោយបានត្រឹមត្រូវតាមប្រភេទបន្លែ ដោយត្រូវការផ្ទៃដីតូចៗ ទំហំ ពី ៨០ ទៅ ១២០ម៉ែត្រការ៉េ

២- ផ្តល់ការណែនាំពីប្រភេទដំណាំដែលលូតលាស់បានល្អ ក្នុងតំបន់អាកាសធាតុក្តៅ និងងាយរកបានក្នុងតំបន់ ព្រមទាំងប្រមូលផលបានរៀងរាល់ថ្ងៃ ។

៣-ធ្វើរបងការពារអោយបានមាំជុំវិញសួន

៤-ប្រើជីធម្មជាតិ និង កំប៉ុស្តិ៍ដែលអាចរកបាន ពីកាកសំណល់ផ្ទះបាយ និងលាមកសត្វផ្សេងៗ ដើម្បីកែប្រែគុណភាពដី និង បំប៉នដំណាំឱ្យលូតលាស់បានល្អ ។

-អ្វីទៅហៅថាសួនបន្លែគ្រួសារ : សួនបន្លែគ្រួសារ គឺជាការដាំដំណាំបន្លែចំរុះច្រើនយ៉ាង នៅជុំវិញលំនៅដ្ឋានរបស់លោកអ្នក ដែលប្រើប្រាស់បច្ចេកទេសតាមគោលការណ៍ធម្មជាតិ ដើម្បីបំពេញតំរូវការគ្រួសារប្រចាំថ្ងៃ ។

តើសួនបន្លែគ្រួសារមានសារៈសំខាន់អ្វីខ្លះសម្រាប់ជីវភាពប្រចាំថ្ងៃ? គឺផ្តល់នូវបន្លែបៃតងស្រស់ៗ សំបូរទៅដោយសារធាតុចិញ្ចឹម និងវីតាមីនគ្រប់ប្រភេទដែលធ្វើអោយរាងកាយមាំមួន សុខភាពល្អ និង កាត់បន្ថយបាននូវការកង្វះផ្ទែកអាហាររូបត្ថម្ភ ដល់គ្រប់សមាជិកគ្រួសារ ។

# I-ប្រតិទិនរដូវកាលដាំដុះ

## ១-អំពីរដូវកាលដាំដុះដំណាំបន្លែ

ជាទូទៅ ដំណាំបន្លែជាច្រើនប្រភេទ តែងតែត្រូវការរដូវកាលមួយជាកំណត់ ពីព្រោះរដូវកាលមានទំនាក់ទំនងទៅនឹងរបបទឹកភ្លៀង សំណើមបរិយាកាស សីតុណ្ហភាព របបខ្យល់ និងរយៈពេលនៃពន្លឺថ្ងៃ ។ នៅប្រទេសកម្ពុជា គេបែងចែកជា២រដូវធំៗ គឺរដូវវស្សា និង រដូវប្រាំង ។

**រដូវវស្សា:** ចាប់ពីខែ ឧសភា ដល់ខែ តុលា រដូវនេះអាកាសធាតុក្តៅ សីតុណ្ហភាពអាចកើនឡើងរហូតដល់ 28-30°C ហើយមានភ្លៀងធ្លាក់ច្រើន សំណើមបរិយាកាសឡើងខ្ពស់ រយៈពេលនៃពន្លឺថ្ងៃវែងជាងរយៈពេលយប់ ហើយអំពើនៃពន្លឺថ្ងៃមានសម្ពាធខ្លាំងមកលើផែនដី លក្ខខណ្ឌបែបនេះមិនអំណោយផលល្អដល់ការលូតលាស់ និង បន្តពូជរបស់បន្លែភាគច្រើន មិនតែប៉ុណ្ណោះថែមទាំងបង្កអោយកត្តាចង្រៃបំផ្លាញដំណាំទៀតផង ។

**រដូវប្រាំង:** ចាប់ពីខែ វិច្ឆិកា ដល់ខែ មេសា វាជារដូវមួយសមស្របដល់ការដុះលូតលាស់នៃដំណាំបន្លែ ព្រោះសីតុណ្ហភាពចុះទាប ចន្លោះពី 20-25°C របបខ្យល់ទៀងទាត់ ធ្វើអោយអាកាសធាតុត្រជាក់បង្កររយៈពេលនៃពន្លឺថ្ងៃខ្លីជាងយប់ ពន្លឺថ្ងៃជាមធ្យម មានការប្រែប្រួល នៃសីតុណ្ហភាពរវាងពេលយប់ និងពេលថ្ងៃខុសគ្នា បន្តិចបន្តួច ហើយកំដៅដីកើនឡើងទាប ជាពិសេសពីខែ វិច្ឆិកា ដល់ខែកុម្ភៈ ។ ចាប់ពី ខែ មីនា ដល់ខែ មេសា អាកាសធាតុក្តៅខ្លាំង ហើយរំហួតក្នុងបរិយាកាសក៏កើតមានឡើង ធ្វើអោយដំណាំបន្លែជាច្រើនលូតលាស់ពុំបានល្អ ឡើយ ។

### ១.១-ដំណាំរដូវវស្សា

ដំណាំបន្លែភាគច្រើន តែងទទួលទិន្នផលខ្ពស់នៅរដូវត្រជាក់ ប៉ុន្តែមានដំណាំមួយចំនួន ដែលអាចទទួលផលបានពេញមួយឆ្នាំផងដែរ ដោយសារវាអាចធន់ទ្រាំបានទៅនឹងអាកាសធាតុក្តៅ ព្រមទាំងពន្លឺថ្ងៃវែង (រយៈពេលថ្ងៃលើសពី១០ម៉ោង) ។ យោងតាមការសិក្សាស្រាវជ្រាវជាច្រើនឆ្នាំ នៅក្នុងតំបន់ជាច្រើនស្ទើរពេញប្រទេសកម្ពុជា អាចធ្វើអោយមានមូលដ្ឋានណែនាំអនុវត្តដំណាំរដូវវស្សារួមមាន : ដំណាំត្រកួនគោគ ដំណាំត្រកួន ទឹក ដំណាំខ្ទឹមស្លឹក ដំណាំគុយឆាយ ដំណាំកញ្ឆែត ដំណាំជីម្រះព្រៅ ជីនាងវង ដំណាំម្ទម ដំណាំត្រាវ ដំណាំក្តាត ដំណាំជីរណា ដំណាំននោងជ្រុង ននោងមូល សណ្តែកកួរ ដំណាំឃ្លោក ដំណាំស្ពៃ វាត្រូវការរយៈពេលពន្លឺថ្ងៃ ចន្លោះពី ១០-១៣ ម៉ោងក្នុង ១ថ្ងៃ ហើយធន់នឹងទឹកភ្លៀង ព្រមទាំងសីតុណ្ហភាពក្តៅពី ២៥-៣០ អង្សារសេ ជាមធ្យម ។ ដូចនេះ គេអាចដាំវាបានគ្រប់រដូវ ប៉ុន្តែនៅរដូវវស្សាត្រូវជ្រើសរើសយកប្រភេទដីមិនលិចទឹក (សូមមើលតារាងទី១) ។

ដំណាំទាំងនេះគួរចាប់ផ្តើមដាំវានៅដើមរដូវវស្សា និង រដូវទី២ គួរចាប់ផ្តើមពី ចុងរដូវវស្សា ចន្លោះពីខែកញ្ញា ឬតុលា អាស្រ័យដោយតំបន់ដាំដុះនីមួយៗ អាចធ្វើទៅបាន (សូមមើលប្រតិទិនទី១) ។

**តារាងទី ១ : ប្រភេទ និងអាយុកាលនៃដំណាំសម្រាប់សួនបន្លែគ្រួសារ**

| ប្រភេទដំណាំ | ដាំដោយ | អាយុកូន | រយៈពេលត្រូវប្រមូលផល | រដូវត្រូវដាំ |
|---|---|---|---|---|
| ១- ត្រសក់ចំណារ | គ្រាប់ផ្ទាល់ | | ៤០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ២- ត្រឡាច | កូនបណ្តុះ | ១៥ថ្ងៃ | ៥៥ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៣- ដំណាំម្រះ | កូនបណ្តុះ | ១០ថ្ងៃ | ៦០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៤- សណ្តែកកួរ | គ្រាប់ផ្ទាល់ | | ៥៨ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៥- ល្ពៅ | គ្រាប់ផ្ទាល់ | | ៧០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៦- នននោង | គ្រាប់ផ្ទាល់ | | ៥០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៧- ត្រកួន | ទង និង គ្រាប់ | | ៣០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ៨- ត្រប់ | កូនបណ្តុះ | ២៥ថ្ងៃ | ៧៥ ថ្ងៃក្រោយដាំ | វិច្ឆិកា និង មិថុនា |
| ៩- អូត្រា | កូនបណ្តុះ | ១០ថ្ងៃ | ៧០ ថ្ងៃក្រោយដាំ | វិច្ឆិកា និង មិថុនា |
| ១០- ខ្ទឹមស្លឹក | មើម និង កូន | | ៤០ ថ្ងៃក្រោយដាំ | ធ្នូ និង ឧសភា |
| ១១- ជីរណា | គ្រាប់ផ្ទាល់ | | ៧៥ ថ្ងៃក្រោយដាំ | ប្រក់ដំបូលពេញមួយឆ្នាំ |
| ១២- ជីនាងវង | កូនបណ្តុះ | ១៥ថ្ងៃ | ៣៥ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ១៣- ជីម្រះព្រៅ | កូនបណ្តុះ | ១៥ថ្ងៃ | ៤០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ១៤- ភ្លៅកង្កែប | កូនបណ្តុះ | ២០ថ្ងៃ | ៣៥ ថ្ងៃក្រោយដាំ | រដូវវស្សា |
| ១៥- ដើមម្អម | កូនបណ្តុះ | ១៥ថ្ងៃ | ៤០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ១៦- កញ្ឆែត | កំណាត់ទង | | ៣០ ថ្ងៃក្រោយដាំ | ដីសើមពេញមួយឆ្នាំ |
| ១៧- ដំណាំឃ្លោក | គ្រាប់ផ្ទាល់ | | ៧០ ថ្ងៃក្រោយដាំ | ពេញមួយឆ្នាំ |
| ១៨- ឪឡឹក | គ្រាប់ផ្ទាល់ | | ៦០ ថ្ងៃក្រោយដាំ | រដូវប្រាំងនិងចុងរដូវវស្សា |

## តារាងប្រតិទិនទី១ ដំណាំរដូវវស្សា




កំណត់សំគាល់ ១ ●———● រយៈពេលដែលលូតលាស់ល្អ

២ ●·········● រយៈពេលពិបាកលូតលាស់

## ២-ដំណាំរដូវប្រាំង

អាកាសធាតុក្ដៅ និង ត្រជាក់មានឥទ្ធិពលយ៉ាងខ្លាំងទៅលើការដុះពន្លក ការពន្លូតដើមដង និង ការបន្តពូជ ។ កាលណាលក្ខណៈជីវសាស្ត្ររបស់ដំណាំត្រូវការធាតុអាកាសត្រជាក់ បើយើងយកវាទៅដាំនៅក្នុងលក្ខខណ្ឌអាកាសធាតុក្ដៅ និងនាំអោយការដុះពន្លក និងការវិវឌ្ឍន៍នៃដំណាក់កាលរបស់វាជួបនូវបញ្ហាយ៉ាងច្រើន អាចធ្វើអោយការលូតលាស់មិនដំណើរការបានល្អ គេហៅថា ពុល ឬ មិនធន់ទ្រាំ នឹង អាកាសធាតុ ។ ដូចនេះ ដំណាំរដូវប្រាំង វាសមស្របទៅនឹងរយៈពេលខ្លីនៃពន្លឺថ្ងៃ ពី ៨-១០ ម៉ោង ក្នុង ១ថ្ងៃ ហើយរបាយនៃពន្លឺមានភាពស្រទំ រីឯសីតុណ្ហភាពវិញជាមធ្យមពី ១៨អង្សារសេ ទៅ ២៥អង្សារសេ ក្នុងនោះមាន : ខាត់ណាផ្កា ប្រូកូលី ទំពាំងបារាំង ខាត់ណាក្ដោប

ស្ពៃបូកគោ ស្ពៃក្រញាញ់ក្តោប ប៉េងប៉ោះ ម្ទេស ម្ទេសហាវ៉ៃ សណ្តែកហោឡាំងតាវ សាលាដក្តោប ខ្ទឹមបារាំង ឆៃថាវ ការ៉ុត ខ្ទឹមស ខ្ទឹមក្រហម ស្ពៃខៀវ ស្ពៃចង្កឹះ ស្ពៃស ស្ពៃជើងទា ខាត់ណាដើម ។ល។(សូមមើលតារាង ទី២) ។

## តារាងទី ២ : ប្រភេទ និងអាយុកាលនៃដំណាំ

| ប្រភេទដំណាំ | ដាំដោយ | អាយុកូន | រយៈពេលត្រូវប្រមូលផល | រដូវត្រូវដាំ |
|---|---|---|---|---|
| ១- ម្ទេសគុយទាវ | កូនបណ្តុះ | ២៥ថ្ងៃ | ៨០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង មិថុនា |
| ២- ម្ទេសហាវ៉ៃ | កូនបណ្តុះ | ២៨ថ្ងៃ | ៧៥ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ៣- ម្ទេសដៃនាង | កូនបណ្តុះ | ២៥ថ្ងៃ | ៨០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ៤- ខាត់ណាក្តោប | កូនបណ្តុះ | ២០ថ្ងៃ | ៨៥ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ៥- ខាត់ណាផ្កា | កូនបណ្តុះ | ១៨ថ្ងៃ | ៦៥ ថ្ងៃក្រោយដាំ | ខែ តុលា វិច្ឆិកា និង ធ្នូ |
| ៦- ខាត់ណាដើម | កូនបណ្តុះ | ២០ថ្ងៃ | ៥០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ៧-ប្រូកូលី | កូនបណ្តុះ | ១៨ថ្ងៃ | ៥៥ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា |
| ៨- ស្ពៃក្រញាញ់ក្តោប | កូនបណ្តុះ | ១៥ថ្ងៃ | ៥០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ៩-ស្ពៃខៀវ-ចង្កឹះ | គ្រាប់ផ្ទាល់ | | ៣៥ ថ្ងៃក្រោយដាំ | ខែតុលា វិច្ឆិកា ធ្នូ មករា |
| ១០-ស្ពៃជើងទា | កូនបណ្តុះ | ២០ថ្ងៃ | ៤៥-៥០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ១១- ឆៃថាវ | គ្រាប់ផ្ទាល់ | | ៥០-៦០ ថ្ងៃក្រោយដាំ | ខែ តុលា វិច្ឆិកា ធ្នូ |
| ១២- ការ៉ុត | គ្រាប់ផ្ទាល់ | | ៧០-៨០ ថ្ងៃក្រោយដាំ | ខែ តុលា វិច្ឆិកា |
| ១៣- ខ្ទឹមបារាំង | កូនបណ្តុះ | ៣០ថ្ងៃ | ៨០-៩០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា |
| ១៤- ខ្ទឹមស | មើម | | ៨០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ១៥- ខ្ទឹមក្រហម | មើម | | ៧០-៨០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ១៦- ប៉េងប៉ោះ | កូនបណ្តុះ | ២៥ថ្ងៃ | ៦៥-៧៥ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ១៧- សណ្តែក ហោឡាំងតាវ | គ្រាប់ផ្ទាល់ | | ៥០-៦០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា |
| ១៨- ត្រសក់ផ្អែម | កូនបណ្តុះ | ៧ថ្ងៃ | ៦៥-៧០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ១៩- សាលាដក្តោប | កូនបណ្តុះ | ១៨ថ្ងៃ | ៥០-៦០ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា និង ធ្នូ |
| ២០-សាលាដក្រញាញ់ | កូនបណ្តុះ | ១៥ថ្ងៃ | ៤០-៦៥ ថ្ងៃក្រោយដាំ | ខែ វិច្ឆិកា ធ្នូ មករា |

ប្រភព : លទ្ធផលស្រាវជ្រាវរបស់ស្ថានីយក្បាលកោះ ឆ្នាំ ១៩៩៨-២០០៥

# ប្រតិទិនទី ២ ដំណាំរដូវប្រាំង ឬ រដូវរំហើយ

| ដំណាំ | ខែទាំង ១២ ក្នុងមួយឆ្នាំ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | បន្តនៅឆ្នាំថ្មី |
| ១-ដំណាំម្ទេស | | | | | | | | | | | | | |
| ២-ដំណាំខាត់ណាក្តោប | | | | | | | | | | | | | |
| ៣-ដំណាំស្ពៃបូកគោ | | | | | | | | | | | | | |
| ៤-ដំណាំខាត់ណាផ្កា | | | | | | | | | | | | | |
| ៥-ដំណាំខាត់ណាដើម | | | | | | | | | | | | | |
| ៦-ដំណាំខ្ទឹមបារាំង | | | | | | | | | | | | | |
| ៧-ដំណាំខ្ទឹមស | | | | | | | | | | | | | |
| ៨-ដំណាំខ្ទឹមក្រហម | | | | | | | | | | | | | |
| ៩-ដំណាំស្ពៃជើងទា | | | | | | | | | | | | | |
| ១០-ដំណាំសាលាដក្តោប | | | | | | | | | | | | | |
| ១១-ដំណាំស្ពៃខៀវ | | | | | | | | | | | | | |
| ១២-ដំណាំប៉េងប៉ោះ | | | | | | | | | | | | | |
| ១៣-ដំណាំការ៉ុត | | | | | | | | | | | | | |
| ១៤-ដំណាំឆៃថាវ | | | | | | | | | | | | | |
| ១៥-សណ្តែកហោឡាំងតាវ | | | | | | | | | | | | | |
| ១៦-សណ្តែកបារាំង | | | | | | | | | | | | | |

កំណត់សំគាល់ ១ ●———● រយៈពេលដែលលូតលាស់ល្អ

២ ●••••••● រយៈពេលពិបាកលូតលាស់

## ២-កត្តាសំខាន់ៗទាក់ទង និងការដាំដុះបន្លែក្នុងសួន

ដើម្បីដាំដុះដំណាំបន្លែឱ្យទទួលបានលទ្ធផលល្អ គេត្រូវយល់ដឹងនូវកត្តាសំខាន់ៗជាច្រើន ដែលអាចឱ្យបន្លែលូតលាស់លឿន ប្រឆាំងបាននូវរាល់ការបំផ្លាញពីសត្វល្អិតចង្រៃ ជំងឺផ្សេងៗ ការពុលដោយអាកាសធាតុ និងលក្ខខណ្ឌដីក្នុងតំបន់ជាច្រើន នៃប្រទេសកម្ពុជា។ អត្ថបទនេះសូមលើកយកនូវគន្លឹះសំខាន់ៗជាច្រើន ដែលទាក់ទង ទៅនឹងតំបន់ដាំដុះនីមួយៗ ។

### ២.១-ការបែងចែកតំបន់សម្រាប់ដាំដុះដំណាំបន្លែ

យោងទៅតាមលក្ខខណ្ឌនៃភូមិសាស្ត្រផ្ទាល់របស់ប្រទេសកម្ពុជាយើង ធ្វើអោយមានការបែងចែកជា ៣ តំបន់ធំៗ សម្រាប់ធ្វើការដាំដុះគឺ :

#### ២.១.១-តំបន់ខ្ពង់រាប

ស្ថានភាពដីមានផ្ទៃមិនរាបស្មើ ហើយមានចំណោតខ្លាំង ឬទីទួលខ្ពស់ នៅរដូវវស្សាតែងសំបូរប្រភពទឹក តែនៅរដូវប្រាំងភាគច្រើនកង្វះខាតប្រភពទឹក ។ ម្យ៉ាងវិញទៀត នៅរដូវភ្លៀងធ្លាក់ ការហូរច្រោះមានសន្ទុះខ្លាំង ដូចនេះការដាំដំណាំបន្លែ គេត្រូវកំណត់រយៈពេលអោយច្បាស់ ភាគច្រើនចាប់ផ្តើមពីចុងខែឧសភា ដល់ខែវិច្ឆិកា ដំណាំទាំងនោះតែងទទួលបាននូវរបបទឹកភ្លៀងរួមជាមួយការស្រោចស្រពបន្ថែម ដូចជា ម្ទេស ត្រប់ ប៉េងប៉ោះ ននោងវែង ត្រឡាច ល្ពៅ ឪឡឹក ត្រសក់ស្រូវ ។ល។ អាចធ្វើការ ដាំដុះបានតែមួយដងប៉ុណ្ណោះ ក្នុងមួយឆ្នាំ ។

#### ២.១.២-តំបន់វាលរាប

នៅក្នុងទូទាំងប្រទេសមានផ្ទៃដីវាលរាបជាច្រើនកន្លែង ភាគច្រើនជាផ្ទៃដីផលិតកម្មដំណាំស្រូវ នៅរដូវវស្សា ប៉ុន្តែមានទីទួលខ្លះៗ ដែលប្រជាពលរដ្ឋ អាចធ្វើជាសួនដាំបន្លែបាន ។ នៅក្នុងរដូវភ្លៀងពី ចុងខែតុលា ដល់ខែ វិច្ឆិកា ហើយភាគច្រើនជាដំណាំអាយុកាលខ្លី ឬអាយុកាលមធ្យម មានប្រភេទដំណាំស្ពៃ ត្រកួន ផ្ទី ត្រសក់ សណ្តែកកួរ ល្ពៅ យកត្រួយ ចំពោះដំណាំអាយុកាលវែងដូចជា ននោងវែង ត្រឡាចផ្អែរ ត្រប់ គេអាចដាំបាននៅរដូវវស្សាដែរ ព្រោះវាធន់ទ្រាំ ទៅនិងសភាពដីសើម ដោយឡែកដំណាំមួយចំនួនដូចជា ខាត់ណាផ្កា ម្ទេស ស្ពៃក្តោប ប៉េងប៉ោះ មិនអំណោយផលល្អឡើយ ។

#### ២.១.៣-តំបន់វាលទំនាប

វាលទំនាបច្រើនលាតសន្ធឹងតាមបណ្តោយមាត់ទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាប តំបន់នេះលិចទឹកនៅរដូវវស្សាដោយជំនន់ទន្លេមេគង្គ ហើយដីត្រូវបានបន្ថែមនូវជីជាតិជារៀងរាល់ឆ្នាំ ។ ការដាំដំណាំបន្លែក្នុងសួនច្រើនតែនៅរដូវទឹកសំរក ចាប់ពីខែតុលា ដល់ខែមិនា ស្ទើរគ្រប់ប្រភេទបន្លែទាំងអាយុកាលវែង និង ខ្លី ប៉ុន្តែត្រូវការស្រោចទឹក ដូចជា ត្រសក់ស្រូវ ត្រសក់ចំណារ សណ្តែកកួរ ត្រប់ ដំណាំជីគ្រប់ប្រភេទ ជន្លង់, ម្រះ, ត្រឡាច, ឃ្លោក, ល្ពៅ, ស្លឹកបាស, ម្ទេសយកផ្លែ យកស្លឹក, ននោងមូល, ននោងជ្រុង ។ល។

## ២.២-ប្រភពទឹក និងការកែប្រែគុណភាពទឹក

មានប្រភពទឹកជាច្រើនកន្លែងដែលគេយកមកស្រោចស្រពដំណាំបានដូចជា :

### ២.២.១-ប្រភពទឹកធម្មជាតិ

ទឹកទន្លេ បឹង អូរ ស្ទឹង ជាប្រភេទទឹកដ៏ល្អដែលមានរុក្ខជាតិទឹកដុះជាច្រើន ធ្វើអោយទឹកនោះមានបរិមាណអុកស៊ីសែនគ្រប់គ្រាន់ មានសភាពរងថ្លា មិនល្អក់ គឺកំទិច ម៉ត់របស់ដីឥដ្ឋមានភាគរយទាប ជាពិសេសទៅទៀត ផ្ទៃលំហ នៃទឹកវាលស្រឡះ ពន្លឺថ្ងៃគ្រប់គ្រាន់ ទឹកនោះពុំចាំបាច់កែប្រែឡើយ គេអាចយកមកស្រោចស្រពភ្លាមៗបាន ។

### ២.២.២-ប្រភពទឹកក្រោមដី

ទឹកអណ្តូងលូ ដែលជីកក្នុងជំរៅរាក់ៗ ភាគច្រើនគេអាចយកមកស្រោចដំណាំភ្លាមៗបាន ។ ដោយឡែកទឹកអណ្តូងបុកភាគច្រើនពុលដោយជាតិដែក ស័ង្កសី ជាតិកំបោរ ស្ពាន់ធ័រ បណ្តាលអោយកង្វះអុកស៊ីសែន ពេលបូមមកយកទៅស្រោចដំណាំភ្លាមៗមិនល្អឡើយ គេត្រូវបូមដាក់អាងនៅក្នុងលំហធម្មតារយៈពេល ២-៣ ថ្ងៃ អោយទឹកនោះមានអុកស៊ីសែនឡើងវិញ ទើបយកទៅស្រោចដំណាំបានមិនបណ្តាលអោយគ្រោះថ្នាក់ ។

### ២.២.៣-ការកែប្រែគុណភាពទឹកមានកំណកដីឥដ្ឋ

ប្រភេទស្រះទឹកដែលទើបនឹងជីក ឬស្ពានថ្មី គេមិនត្រូវបញ្ចូលទឹកក្រោយជីកបានហើយនោះទេ គប្បីយកកំបោរសទៅបាចតាមរូបមន្តមួយម៉ែត្រការ៉េ នៃផ្ទៃស្រះប្រើកំបោរពី ១,០ ទៅ ១,២០គក្រ ហើយហាលថ្ងៃអោយស្ងួតរយៈពេលយូរថ្ងៃ បន្ទាប់មកនៅផ្នែកជើងទេរនៃស្រះគេត្រូវដាំប្រភេទស្មៅក្នុងទឹកអោយបានច្រើន ដូចជា ដើមកន្ទ្រាំងហែ ដើមស្មៅចំផ្លូង ត្រកួនព្រៃ (ត្រកួនក្រហម) អោយរុក្ខជាតិទាំងនោះដុះលូតលាស់រយៈពេល ១-២ ខែ បន្ទាប់មក យកកាកសំណល់ផ្សេងៗដូចជា លាមកគោ ក្របី កាកសំណល់ស្មៅពុកៗ ដើមសណ្តែក ដើមទន្រ្ទេងខែត ចំបើងស្រូវ សំដីស្រូវ ជាពិសេសផេះអង្កាមយកទៅដាក់បាតស្រះ អោយបានច្រើន ទើបបញ្ចូលទឹកទៅក្នុងស្រះនោះ ។ ក្រោយពីការបញ្ចូលទឹករយៈពេលពី ២-៣ អាទិត្យ ទឹកនោះចាប់ផ្តើមរងថ្លាបន្តិចម្តងៗ ហើយការពារទឹកពីក្រៅមិនអោយហូរចូលបន្ថែមជារៀងរាល់ថ្ងៃ នៅពេលយើងបូមទឹកពីស្រះទៅប្រើប្រាស់ទឹកក្នុងស្រះស្រកចុះមួយភាគបីនៃជំរៅទឹក គេត្រូវបញ្ចូលបន្ថែម ។ ក្រោយពីទឹកនៅក្នុងស្រះរងថ្លាបន្តិចហើយ គេត្រូវធ្វើក្បូនឬស្សីបួនជ្រុង គឺឬស្សីមូលដែលមានរាងជាការ៉េ ឬចតុកោណកែង បណ្តែតក្នុងទឹកស្រះអោយច្រើនកន្លែង (បណ្តែតលើផ្ទៃទឹក) ក្បូននោះមិនមានទម្រនៅពីលើក្បូនឡើយ គឺក្នុងរង្វង់នៃក្បូននោះ ផ្ទៃទឹកធម្មតាក្រោយមកគេបោះបង្គោលចងក្បូននោះនៅនឹងកន្លែង បន្ទាប់មកយកដើម កំប្លោកអោយបានច្រើនមកដាក់ក្នុងរង្វង់នោះ អាចធ្វើអោយទឹកស្រះឆាប់រងថ្លា ហើយកំដៅទឹក ប្រែប្រួលទាំងបរិមាណ អុកស៊ីសែននៅក្នុងទឹកកាន់តែប្រសើរ ធ្វើរបៀបនេះរយៈពេល ២ ទៅ ៣ ខែគេអាចយកទឹកទៅស្រោចដំណាំបាន ។ លក្ខណៈពិសេសមួយទៀត នៅជុំវិញមាត់ស្រះត្រូវដាំដំណាំ ឬឈើពហុប្រយោជន៍ អោយបានច្រើនដូចជា អាកាស្យា អង្កាញ់ អង្គារដី ឬកន្ធំថេត វាឆាប់ធំបានម្លប់ដល់ទឹក ស្លឹករបស់វាជួយអោយទឹកងាយរងថ្លាបាននៅពេលវាជ្រុះចូលទៅក្នុងស្រះ ។



**ប្រភេទស្រះទឹកលើដីឥដ្ឋទើបនឹងជីក ហើយត្រូវកែប្រែ**

**២.២.៤-របៀបកែច្នៃទឹកក្រោមដី**

អាង ឬស្រះសម្រាប់ស្តុកទឹកបូមពីក្នុងដី ត្រូវធ្វើដូចគ្នានឹងស្រះធម្មតាដែរ ដូចជាការដាំស្មៅជុំវិញជើងទេរ ដាក់កាកសំណល់រុក្ខជាតិ និងសត្វ ។ **ប៉ុន្តែមិនត្រូវបាចកំបោរសឡើយ** ត្រូវប្រើផេះអង្កាម ឬស្រកីដូងទុំអោយច្រើន ហើយអាង ឬស្រះនេះត្រូវនៅក្បែរអណ្តូងងាយក្នុងការបូមទឹកបញ្ចូល ។ ក្រោយពីការបូមទឹកចេញពី ក្នុងដីហើយ ទុករយៈពេល ២ ទៅ ៣ ថ្ងៃ ទើបអាចយកទៅស្រោចដំណាំបាន ។

## ២.៣.ការប្រើប្រាស់ដីលើដំណាំនីមួយៗ

លទ្ធផលនៃការស្រាវជ្រាវរវាងប្រភេទដីដាំដុះ និងតំរូវការរបស់ដំណាំនីមួយៗ គេបែងចែកដំណាំជា ៣ ក្រុមធំៗ ទៅតាម ភាពធន់ទ្រាំនៃការកង្វះដីជាតិដីដូចជា :

**២.៣.១-ដំណាំដែលធន់ទ្រាំខ្លាំងលើដីអាស៊ីត ឬដីជូរ :**

នៅពេលកំរិតជីជាតិដីចុះថយកាន់តែខ្លាំង (pH ទាប ៤.៥ — ៥.៥) ហើយដំណាំនៅតែដុះលូតលាស់បាន គេអោយឈ្មោះថា ដំណាំធន់ទ្រាំដីអាស៊ីត (ដីជូរ) ។ ក្នុងនោះមានដំឡូងបារាំង ផ្លែថាវក្រហម ខ្ទឹមក្រហម ដំឡូងជ្វា ឪឡឹក សណ្តែកអង្គុយ ស្រូវ និងដំណាំឈើពហុប្រយោជន៍ឯទៀត ។

**២.៣.២-ដំណាំធន់ទ្រាំមធ្យមលើដីអាស៊ីដ ឬដីជូរ :**

នៅពេលកំរិតជីជាតិដីកាន់តែចុះទាប ដំណាំថយចុះនូវការលូតលាស់ និងថយចុះផល គេហៅថាដំណាំធន់ទ្រាំលើប្រភេទដីជាតិអាស៊ីតមធ្យម (pH ៥.៥ - ៦.៥) ។ ដំណាំទាំងនោះមាន ពពាយស្បែក ជីវ៉ាន់ស៊ុយ ការ៉ុត ពោតត្រសក់ចំណារ ត្រប់ ខ្ទឹមស សណ្តែកហោឡាំងតាវ ម្ទេស ល្ពៅ ផ្លែថាវ សណ្តែកបាយ ប៉េងប៉ោះ ខាត់ណាដើម ក្តាត

ត្រាវ ដំឡូងដូង ខ្ទាយ សណ្ដែកសៀង រមៀត ម្រះព្រៅ ជីរនាងវង ជីរសាំងក្រហ៊ុំ ជីរអង្កាម ម្ទម រំដេង ដំណាំទាំងនេះរាប់បញ្ចូលទៅ ក្នុងដំណាំដែលជ្រើសរើសប្រភេទដីជាបង្គួរ ។

**២.៣.៣-ក្រុមដំណាំធន់ទ្រាំខ្សោយលើដីអាស៊ីត ឬដីជូរ :**

ប្រភេទដំណាំដែលធន់ទ្រាំខ្សោយលើដីជាតអាស៊ីត វាតម្រូវការដីមានជីជាតិគ្រប់គ្រាន់ ទើបដុះលូតលាស់ និងអោយផល កាលណាជីជាតិមិនគ្រប់គ្រាន់ ធ្វើអោយការលូតលាស់មានភាពប្រែប្រួល ទិន្នផលចុះទាបខ្លាំង ឬមិនអោយផល ។ តំរូវការជីជាតិដីល្អ (pH ៦,៥ - ៧,៥) ក្នុងនោះពពួកដំណាំ ម្រះ ប្រូកូលី ខាត់ណាផ្កា ខាត់ណាក្តោប ខ្ទឹមបារាំង ភ្លៅកង្កែប គុយឆាយ ខ្ទឹមគុយទាវ សណ្តែកដី សាលាដគ្រប់ប្រភេទ ត្រសក់ស្រូវ ខាត់ណា ។ ដូចនេះមុននឹងធ្វើការដាំដុះ អ្នកដាំដំណាំទាំងឡាយគួរយល់ដឹងនូវលក្ខណៈជីជាតិដីជាមុន រួមផ្សំ និងបច្ចេកវិទ្យារបស់ដំណាំនីមួយៗ ទើបធ្វើអោយមានលក្ខណៈសេដ្ឋកិច្ចល្អប្រសើរ ។

## ២.៤_ការកែប្រែជីជាតិដី

ការប្រើប្រាស់ដីក្នុងការដាំដុះដំណាំបានធ្វើអោយបាត់បង់ជាបណ្តើរៗ នូវជីជាតិដែលមាននៅក្នុងដីពីមួយឆ្នាំទៅមួយឆ្នាំ មិនតែប៉ុណ្ណោះមានអំពើជាច្រើនទៀតដែលធ្វើអោយការសឹករិចរិលកើតមានឡើង ដូចជា ការទុកដីអោយប្រេះក្រហែង ទុកដីទំនេរអោយដីស្ងួតខ្លាំង ល្បឿនទឹកហូរលឿនបណ្តាលមកភ្លៀងធ្លាក់ខ្លាំង ឬទឹកជំនន់ ពីតំបន់ផ្សេងៗទៀត ។ ការបាត់បង់ និងសឹករិចរិល ជាពិសេសទៅលើសារធាតុអំពុក ដែលកកើតជាមមោត មមោតនេះហើយដែលជំរុញអោយសារធាតុឯទៀតមានការវិវត្តលឿន ដូចជាដីល្បាយខ្សាច់តាមជើងភ្នំ ការហូរច្រោះជាច្រើនរយឆ្នាំ បាត់បង់នូវសារធាតុទាំងនោះនៅសល់តែល្បាយខ្សាច់ កាលណាដីសំបូរទៅដោយល្បាយខ្សាច់ ដីនោះងាយនឹងឆាប់ស្ងួតហើយប្រែប្រួលកំដៅយ៉ាងលឿន ។ ដូច្នេះការកែប្រែជីជាតិដី ជាតួនាទីមួយចាំបាច់ ដែលអ្នកដាំដុះដំណាំត្រូវតែអនុវត្ត ដើម្បី ការពារនិងរក្សាអោយដីមានលំនឹងភាព ផ្នែកជីជាតិ ផ្តល់អោយការដាំដុះទទួលបានភាពជោគជ័យទៅបណ្តាឆ្នាំ ខាងមុខៗ ។



**ការកប់ដីកុំប៉ុស្តិ៍លើរងដំណាំ**

### ២.៤.១-ប្រភេទដីល្បាយខ្សាច់

ផ្ទៃដីមួយភាគធំនៃប្រទេសកម្ពុជាគឺជាប្រភេទដីល្បាយខ្សាច់(តំបន់វាលរាប) ដើម្បីកែប្រែអោយដីនេះសំបូរជីជាតិគេត្រូវប្រើសារធាតុសរីរាង្គ អោយបានច្រើន ដែលបានមកពី លាមកសត្វ កាកសំណល់រុក្ខជាតិ ជីកុំប៉ុស្តិ៍ ហើយព្យាយាមដាំដំណាំអំបូរ សណ្តែកអោយបានច្រើនដង ជាពិសេសសណ្តែកអង្គុយ ឬពួកស្មោរស្លឹកតូចៗ ។ ចំពោះការដាំដំណាំលើដីវិញត្រូវគិតអំពីការប្តូរមុខដំណាំអោយច្បាស់លាស់ពីរដូវមួយទៅរដូវមួយ ។ ករណីផ្សេងទៀត បើដីនោះមិនទាន់ត្រូវការដាំដំណាំ គេត្រូវយកគ្រាប់ទន្រ្ទានខែត គ្រាប់សណ្តែកខ្មៅ គ្រាប់ស្មៅ ទៅបាចអោយវាដុះដើម្បីគ្របការពារដីនិងបង្កើនជីជាតិដល់ដី ក្រៅពីនោះទៀត គេដាំដើមឈើលូតាស់រហ័សប្រភេទ កន្ទំថេត អង្គ្រែដី អាកាស្យា ជាដើម អោយបានរយៈពេល ២ ទៅ ៣ឆ្នាំ បន្ទាប់មកកែប្រែដីនោះទៅជាការដាំដំណាំវិញ វារិតតែទទួលបានផលល្អ ។ ចំពោះការប្រើប្រាស់ជីគីមីវិញ ត្រូវប្រុងប្រយត្ន័ជាទីបំផុត ព្រោះរិតតែធ្វើអោយបាត់បង់លក្ខណៈគីមីរបស់ដីយ៉ាងលឿន ។

### ២.៤.២-ប្រភេទដីឥដ្ឋ

ការសិក្សាអំពីលក្ខណៈ និងក្រុមរបស់ដីក្នុងប្រទេសកម្ពុជា សង្កេតឃើញមានដីលក្ខណៈជាដីឥដ្ឋ មានច្រើនប្រភេទដូចជា ប្រភេទដីឥដ្ឋគ្មានថ្មបាយក្រៀម ។ ប៉ុន្តែប្រភេទដីមួយក្រុមទៀត ច្រើននៅលើវាលរាបស្ទើរគ្រប់តំបន់។ ដីនេះស្រទាប់ខាងលើ ច្រើនមានខ្សាច់ម៉ត់ពណ៌ក្រមៅ ឬពណ៌ភ្លឺ ជំរៅប្រហែល ១០-១៥សម ប៉ុណ្ណោះ បន្ទាប់មកស្រទាប់ទីពីរ គឺមានទំរង់ជាដីឥដ្ឋ លាយជាមួយថ្មបាយក្រៀមពណ៌ច្រេះ ។ ដើម្បីកែប្រែដីនេះអោយមានជី ជាតិជាបង្គួរឡើងវិញ គេមិនត្រូវប្រើជីលាមកសត្វប្រភេទណាដែលមានជាតិកំបោខ្ពស់នោះឡើយ ដូចជាលាមកមាន់ ទា ។ ក្រោយពីការភ្ជួរដីហើយ ត្រូវយកជីលាមកសត្វមកបាចពីលើអោយបានច្រើនពី ១,៥ ទៅ ២,០គ.ក្រ លើដី $1m^2$ ជាពិសេស លាមកគោ ក្របី និងជ្រូក។ ក្រៅពីនោះទៀតដូចជា អង្កាម ដើមសណ្តែក ស្លឹកឈើពុកៗ ក្រោយពីបាចហើយត្រូវភ្ជួរត្រឡប់ចូលទៅក្នុងដី បើអាចបញ្ចូលទឹកបានត្រូវបញ្ចូលទឹកអោយលិចដីរយៈពេល ២ ទៅ ៣ អាទិត្យ ទើបអាចរៀបចំដីដាំដំណាំផ្សេងៗបាន ។

## ២.៥-ការរៀបចំដីសម្រាប់ដំណាំបន្លែ

ការរៀបចំដីសម្រាប់ដាំដំណាំបន្លែ មានលក្ខណៈខុសប្លែកពីដំណាំស្រូវ ហើយនៅក្នុងដំណាំបន្លែនីមួយៗ ក៏មានវិធីសាស្រ្តក្នុងការភ្ជួររាស់ផ្សេងៗពីគ្នាដែរ ទៅតាមប្រភេទដំណាំ និងប្រភេទដីដូចជា :

**-ប្រភេទដីល្បាយខ្សាច់លាយល្បប់ចាស់:** ចាប់ផ្តើមភ្ជួរដីលើកដំបូង នៅពេលដីមានសំណើមល្មមមិនទាន់ស្ងួតប្រេះ អោយបានជំរៅជាមធ្យមពី (១៥-២០សម) ក្រោយពីភ្ជួរហើយ បើកាលណាដីនោះមិនស្អិតគេត្រូវរាស់បំបែកដីក្នុងពេលតែមួយ តែបើដីភ្ជួរហើយមានសភាពនៅស្អិតបន្តិច គេត្រូវហាលដីនោះរយៈពេលមួយថ្ងៃទើបរាស់បំបែកដី ។ ក្រោយពីរាស់ បំបែកដីហើយត្រូវផ្អាប់ហាលដីនោះរយៈពេល ៥-៧ ថ្ងៃ ទើបភ្ជួរប្រែដីឡើងវិញ បន្ទាប់មកលើករង ហើយធ្វើការដាំដុះ ដូចជាដំឡូងជ្វា ដំឡូងឈើ ដំឡូងដូង រមៀត ត្រាវ ខ្ញី សណ្តែកដី ។ ចំពោះដំណាំមើម

ដាំដោយគ្រាប់ផ្ទាល់ដូចជា ឆៃថាវ ការ៉ុត ប៊ិតក់ ខាត់ណាមើម ក្រោយពីលើករងហើយ ត្រូវវ៉ាយ បំបែកដីដុំលើរងនីមួយអោយតូចល្អិតបន្តិចទើបធ្វើការដាំដុះ ។

**-ប្រភេទដីខ្សាច់លាយដីឥដ្ឋ** : ដីប្រភេទនេះភាគច្រើនល្បាយខ្សាច់ស្រទាប់លើ ហើយល្បាយដីឥដ្ឋនៅស្រទាប់ទីពីរ ។ បើដីសើមទុកអោយដីស្ងួតទើបភ្ជួររាស់ ព្រោះវាងាយស្រួលភ្ជួរជាងដីសើម ។ ក្រោយពីភ្ជួរហើយត្រូវរាស់បំបែកដីប្រមូលយកស្មៅចេញ ហើយហាលដីរយៈពេល ៤-៥ ថ្ងៃ អោយដីនោះស្ងួតថែមទៀត រួចហើយភ្ជួរប្រែឡើងវិញ និងត្រូវរាស់បំបែកដីមួយទៅពីរដង បន្ទាប់មកអាចលើករងភ្លាម ឬហាលដីចោលរយៈពេល ១-២ អាទិត្យទើបលើករងក៏បាន ។ បន្ទាប់មកយកដីធម្មជាតិមកបាចពីលើរងអោយបានច្រើនពី ១,៥ ទៅ ២,០គ.ក្រ ក្នុងមួយម៉ែត្រការ៉េ ជ្រុំដីនោះលប់ទៅក្នុងដីពង្រាបរងអោយស្មើ អាចធ្វើការដាំដុះបាន ។

**-ប្រភេទដីក្រហមភ្នំភ្លើង និងដីខ្មៅ** : ដីប្រភេទនេះពេលសើម ស្អិតខ្លាំង ហើយពេលស្ងួតស្រួយខ្លាំង ដូចនេះពេលចាប់ផ្តើមភ្ជួរជាលើកដំបូង នៅពេលដីមានសំណើមបន្តិចៗ ត្រូវរាស់បំបែកដីភ្លាម។ បន្ទាប់មកហាលដីអោយស្ងួតរយៈពេល ៤ ទៅ ៥ ថ្ងៃ ហើយភ្ជួរប្រែដីឡើងវិញអោយជ្រៅជាងមុនបន្តិច អាចលើករងដាំដំណាំបាន។ ប៉ុន្តែសម្រាប់ដំណាំដែលដាំដោយគ្រាប់ផ្ទាល់ គេត្រូវពង្រាបរងឡើងវិញអោយស្មើ ទើបធ្វើការដាំដុះ។ ក្រោយពីដាំរួចត្រូវប្រើគំរបស្ងួតគ្របពីលើរងអោយជិតទើបស្រោចទឹកបាន ធ្វើអោយកូនដំណាំងាយក្នុងការដុះពន្លក ។

## ៣_ដំណើរការដាំដុះពេញមួយឆ្នាំ និងការផ្លាស់មុខដំណាំ

### ៣.១_ការដាំពេញមួយឆ្នាំ

ដំណាំបន្លែតែងត្រូវការនូវកត្តាអាកាសធាតុជាចំបង ពីព្រោះប្រភេទបន្លែខ្លះត្រូវការអាកាសធាតុត្រជាក់ ដំណាំខ្លះត្រូវការអាកាសធាតុក្តៅ ហើយដំណាំនីមួយៗនៅក្នុងវគ្គខ្លះ វាត្រូវការពន្លឺថ្ងៃមធ្យម គឺរយៈពេលមានពន្លឺខ្លី (ថ្ងៃខ្លី) ហើយវគ្គខ្លះវាត្រូវការរយៈពេលថ្ងៃ និងរយៈពេលយប់ស្មើគ្នា ។ កាលណាគេដាំដំណាំដែលត្រូវការអាកាសធាតុត្រជាក់ នៅក្នុងរដូវក្តៅ គេអោយឈ្មោះថា ការដាំខុសរដូវ ។ សូមមើលតារាងទី ៣

**តារាងទី ៣ ដាំដុះពេញមួយឆ្នាំ**

| តំបន់ | រដូវវស្សា | រដូវក្តៅ | រដូវរំហើយ |
|---|---|---|---|
| ខ្ពង់រាប | ———— | ………… | ———— |
| វាលរាប | ……——— | ———…… | ——— |
| វាលទំនាប | ………… | ……——— | ———— |

———— រយៈពេលលូតលាស់ល្អ

………… រយៈពេលពិបាកលូតលាស់

## ៣.២_ការដាំឆ្លាស់មុខដំណាំ

ជាមធ្យមតាក្នុងដំណាក់កាលបច្ចុប្បន្ន កសិករតែងមានផ្ទៃដីផលិតកម្មតូចៗ ដូចនេះគេត្រូវដាំដំណាំស្ទើរពេញមួយឆ្នាំ ផុតពីរដូវមួយ ទៅរដូវមួយ ផុតពីដំណាំមួយទៅដំណាំមួយថ្មីទៀត ដូចនេះអ្នកដាំដំណាំទាំងអស់ត្រូវយល់ដឹងអោយច្បាស់ថា កាលណាផុតពីរដូវមួយទៅរដូវមួយ យកប្រភេទដំណាំដដែល ឬដំណាំផ្សេងគ្នា តែស្ថិតនៅអំបូរតែមួយមកដាំម្តងទៀតនឹងជួបប្រទះនូវបញ្ហាយ៉ាងច្រើន ។ តាមលទ្ធផលនៃការស្រាវជ្រាវជាច្រើនឆ្នាំក្នុងស្ថានីយ៍ក្បាលកោះបានអោយដឹងថា លទ្ធភាពដ៏ល្អគេត្រូវធ្វើការឆ្លាស់មុខដំណាំដូចតារាងខាងក្រោម :

**តារាងទី ៤ ការឆ្លាស់មុខដំណាំ**

| **រដូវដំបូង (ទី ១)** | **រដូវបន្ទាប់ (ទី ២)** | **រដូវបន្ទាប់ (ទី ៣)** |
|---|---|---|
| ដំណាំស្រូវ | ដាំបានគ្រប់បន្លែ | ដំណាំស្រូវ ឬ ទឹកលិច |
| ដំណាំប៉េងប៉ោះ | ដំណាំសណ្តែក | ដំណាំអំបូរត្រសក់ |
| ដំណាំអំបូរស្ពៃ | ដំណាំម្ទេស , ត្រប់ | ដំណាំអំបូរសណ្តែក |
| ដំណាំអំបូរត្រសក់ | ដំណាំម្ទេស , ត្រប់ , ប៉េងប៉ោះ | ដំណាំអំបូរសណ្តែក |
| ដំណាំអំបូរម្ទេស | អំបូរត្រសក់ | ដំណាំអំបូរសណ្តែក |
| ដំណាំអំបូរត្រប់ | ដំណាំអំបូរសណ្តែក | ដំណាំអំបូរស្ពៃ |
| ដំណាំអំបូរស្ពៃ | ដំណាំអំបូរពោត | ដាំគ្រប់ដំណាំក្រៅពីស្ពៃ |

បំរាម : ក្រោយពីដំណាំស្ពៃ មិនត្រូវដាំសណ្តែកកួរ ត្រសក់ ឬដំណាំអំបូរខាត់ណាឡើយ ។

*កំណត់សំគាល់* : -ដំណាំអំបូរស្ពៃ មាន : ស្ពៃគ្រប់ប្រភេទ និង ខាត់ណាគ្រប់ប្រភេទ

-ដំណាំអំបូរប៉េងប៉ោះមាន : ម្ទេស ត្រប់ អូក្រា

-ដំណាំអំបូរត្រសក់មាន : ល្ពៅ ឪឡឹក ននោង ត្រឡាច ឃ្លោក ម្រះ ។

-អំបូរសណ្តែកមាន : សណ្តែកគ្រប់ប្រភេទ ពពាយគ្រប់ប្រភេទ

## II-ប្រភេទពូជបន្លែ ដែលអាចដាំក្នុងសួន និង ការរក្សាទុកបន្ត

### ១.ពូជដំណាំដែលរកបានក្នុងមូលដ្ឋាន និង ប្រភេទពូជមកពីតំបន់ផ្សេង

នៅក្នុងទូទាំងប្រទេសកម្ពុជា មានពូជដំណាំបន្លែមួយភាគធំ ដែលប្រជាកសិករយើង បានដាំនឹងប្រើប្រាស់ព្រមទាំងរក្សាទុកពូជបន្តពីរដូវមួយទៅរដូវមួយ បានយ៉ាងងាយស្រួល ដោយសារលក្ខណៈពិសេសពីរយ៉ាងគឺ ប្រពៃណីពីដូនតាបំរុងទុកពូជបន្ត និងកត្តាភូមិសាស្ត្រ ទាក់ទងទៅនិងរដូវធំៗពីគឺប្រាំង និងវស្សា ។ ដំណាំខ្លះគេទុកពូជពីរដូវប្រាំងយកទៅដាំបន្តរដូវវស្សា ហើយពីរដូវវស្សាបន្តទៅរដូវប្រាំងវិញ ។ តំបន់ខ្លះមិនអំណោយផលក្នុងការទុកនៅតំបន់របស់ខ្លួន គេបានផ្ទេរវាទៅតំបន់មួយក្នុងរដូវពិបាកដាំដុះ ឬមានគ្រោះមហន្តរាយផ្សេងដូចជា ទឹកជន់ លិចបន្ទាប់ពីទឹកសំរក គេបានទៅយកមកដាំឡើងវិញ របៀបនេះឱ្យឈ្មោះថា ការបំលាស់ប្តូរទីតាំងនៃពូជ ដើម្បីចិញ្ចឹម និងរក្សាប្រភពពូជក្នុងមូលដ្ឋាន ។

#### ១.១.ពូជដំណាំដែលកសិកររកបានក្នុងមូលដ្ឋានផ្ទាល់

ប្រភេទពូជដំណាំបន្លែចំរុះ ដែលយកមកដាំក្នុងសួនបន្លែ ហើយមានលទ្ធភាពរកបានក្នុងតំបន់របស់ខ្លួន ឬតំបន់ជិតខាងភាគច្រើនគឺ ប្រភេទដំណាំអាកាសធាតុក្តៅ ដូចជា : ពូជននោងមូល ននោងជ្រុង ត្រឡាច ល្ពៅ ម្រះ ត្រសក់ចំណារ ត្រសក់ស្រូវ ស្លឹកបាស ម្ទេស ត្រប់គ្រប់ប្រភេទ សណ្តែកកួរ ឃ្លោក ម្រុំ ផ្ទី ជីរគ្រប់ប្រភេទ ស្លឹកគ្រៃ ងប់ ស្ពៃ ពពាយជ្រុង ។ល។ មធ្យោបាយដែលកសិករអាចរកបានគឺ តាមរយៈការសំគាល់ឃើញ ហើយធ្វើការទិញ ឬដូរពីគ្នាទៅវិញទៅមក ជាពិសេសគឺ ការផ្លាស់ប្តូររវាងគ្នានឹងគ្នា តាមរយៈភូមិផងជិតខាងគ្នាដោយភាពមិនរើសអើង ។



**ពូជត្រសក់មូលដ្ឋាន កសិករអាចទុកបន្តរដូវខាងមុខ**

### ១.២-ពូជដែលបានមកពីតំបន់ផ្សេងៗ

ប្រភេទបន្លែខ្លះ ដែលប្រជាកសិករតែងនិយម ហើយប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ប៉ុន្តែលក្ខខណ្ឌភូមិសាស្ត្រ មិនអាចទុកពូជបាន គេត្រូវធ្វើការទិញពីមជ្ឈមណ្ឌលស្រាវជ្រាវ ឬក៏បានមកពីការទិញនៅទីផ្សារ ។ ពូជទាំងនេះមានប្រភេទខ្លះនាំចូលពីក្រៅប្រទេស រួមមាន : ប៉េងប៉ោះ មិនប្រកាន់រដូវ ខាត់ណាដើម ផៃថាវ ស្ពៃចង្កឹះ ស្ពៃខៀវ ម្ទេសហាវ៉ៃ ត្រកួនគ្រាប់ ។ល។ ពូជទាំងនេះ ភាគច្រើនតាមរយៈអាជីវករលក់ដូរ ដូចនេះ ត្រូវសាកសួរព័ត៌មានពីអាជីវករទាំងនោះអោយច្បាស់ នូវលក្ខណៈផ្សេងៗដូចជា ភាគរយនៃការដុះរបស់គ្រាប់ អាយុកាលនៃការដុះលូតលាស់ រួមទាំងទិន្នផលផងដែរ ព្រោះថាពូជខ្លះការទុកដាក់មិនបានត្រឹមត្រូវ លើសឆ្នាំកំណត់ប្រើប្រាស់ មិនសមស្របនឹងតំបន់ដាំដុះនីមួយៗ ធ្វើអោយការដាំដុះជួបនូវវិបត្តិដូចជា អាត្រាដុះតិចបំផុត ដុះលូតលាស់ ល្អតែមិនផ្លែក៏មាន ព្រមទាំងកើតជំងឺ និងបំផ្លាញដោយសត្វល្អិត ។

## ២-ការរក្សាទុកពូជបន្លែ

ដើម្បីអោយការសន្សំ និងទុកពូជបន្លែទទួលបានលទ្ធផលល្អ សូមលើកយកនូវបញ្ហាសំខាន់ៗមួយចំនួនក្នុងអត្ថបទខាងក្រោមមកជំរាបជូន :

### ២.១-ប្រភេទពូជដំណាំទុំមិនស្ងួត

មានប្រភេទដំណាំបន្លែយកផ្លែជាច្រើន ដែលការរក្សាទុកពូជបន្តតាមប្រពៃណីដោយផ្លែទុំ ឬក្បួរទុំ ។ ដំណាំដែលមានផ្លែ ឬក្បួរដែលទុំ ហើយផ្លែ ឬក្បួរមិនស្ងួតត្រូវរលួយកាលណាគេទុកយូរថ្ងៃ ឬខែរួមមាន : ត្រឡាច ម្រះ ល្ពៅ ត្រប់ ម្ទេស ប៉េងប៉ោះ ត្រសក់ស្រូវ ត្រសក់ចំណារជាដើម ។ គេត្រូវរក្សាទុកផ្លែណាមួយ ដែលអ្នក យល់ឃើញថាវាសមល្មមអាចទុកពូជបាន ត្រូវទុកអោយវាទុំនៅនឹងដើម រហូតដល់ល្មមបេះដូចជា :

-ត្រឡាច ល្ពៅ ពេលផ្លែរបស់វាមានឡើងក្រាមម្សៅពណ៌ស អាចបេះយកមកទុកយ៉ាងយូរ មួយអាទិត្យ ត្រូវពុះយកគ្រាប់មកត្រាំទឹកមួយយប់ ហើយលាងទឹកអោយស្អាត ដាក់ហាលថ្ងៃអោយស្ងួតរយៈពេល ២ ទៅ ៣ ថ្ងៃ (ហាមហាលថ្ងៃត្រង់ក្តៅខ្លាំង) អាចយកមកទុកបាន (របៀបទុកដាក់ពូជសូមមើលចំណុច ២.៣ )




**ពូជត្រឡាច និង ល្ពៅ អាចសំរាំងយកគ្រាប់បាន**

-ត្រប់ ត្រសក់ចំណារ ម្រះ ត្រសក់ស្រូវ ប៉េងប៉ោះ ម្ទេស គេត្រូវរក្សាទុកផ្លែអោយទុំមានពណ៌ក្រហម (ទន់ជ្រាយត្រសក់ស្រូវរបេះទង) ត្រូវប្រមូលយកផ្លែ ដំណាំទាំងនោះមកពុសយកគ្រាប់ដាក់ត្រាំទឹកមួយយប់ ហើយលាងសំអាតអោយអស់រំអិល ដាក់ហាលថ្ងៃអោយស្ងួតរយៈពេល ២ ទៅ ៣ ថ្ងៃ (ហាមហាលថ្ងៃត្រង់ក្តៅខ្លាំង) អាចយកទៅទុកដាក់បាន ។



**ភាពទុំពេញលក្ខណៈរបស់ពូជអាចសំរាំងយកគ្រាប់បាន**

## ២.២-ប្រភេទពូជដំណាំទុំស្ងួត

ប្រភេទដំណាំយកផ្លែ ឬស្លឹកខ្លះ ពេលទុំសំបកផ្លែ ឬក្ទួរនោះស្ងួតដូចជា :

-ប្រភេទស្ពៃចង្កឹះ ស្ពៃខ្សៀវ សាលាដ សណ្តែកកួរ និងជីគ្រប់ប្រភេទ ពេលទុំក្ទួររបស់វាស្ងួត ។ នៅពេលវាស្ងួតល្មម គេត្រូវច្រូត ឬបេះក្ទួរនោះទៅសំងួតបន្ថែមរយៈពេល ១ ទៅ ២ ថ្ងៃ អាចសំរាំងយកសំបកចេញ រួមជាមួយរើសចោលនូវគ្រាប់ស្កុយ គ្រាប់តូច គ្រាប់ស្អៀត ឬគ្រាប់មានសត្វល្អិតបំផ្លាញ ហើយដាក់ហាលបន្ថែមចំនួន ២ ទៅ ៣ថ្ងៃទៀត ទើបយកទៅទុកដាក់បាន ។ ដើម្បីធានាកុំឱ្យមានការបាត់បង់ដូចជា ស្ពៃ សាលាដ មិនត្រូវទុកផ្លែ ឬក្ទួរវាអោយទុំយូរថ្ងៃនៅក្នុងថ្នាលឡើយ ព្រោះវាប្រេះជ្រុះគ្រាប់ ឬគ្រាប់ដុះផ្សិតពេលត្រូវទឹកសន្សើមពេលយប់ ។ ចំពោះសណ្តែកកួរគេទុកពូជបានល្អក្នុងរដូវប្រាំង ត្រូវបេះក្ទួរដែលទុំស្ងួតថ្មីៗ ប្រសិនបើទុកក្ទួរអោយស្ងួតយូរថ្ងៃ ជាបច្ច័យអាក្រក់មួយ គឺមេសត្វខ្ទួតពងដាក់ហើយអាចទៅញាស់ស៊ីក្នុងឧបករណ៍នៃរយៈពេលរក្សាទុកពូជដោយមិនដឹងខ្លួន (របៀបទុកដាក់ពូជសូមមើលចំណុចទី ២.៣)

-ប្រភេទពពាយ នននោងមូល នននោងជ្រុង និង ឃ្លោក គេត្រូវទុកផ្លែអោយស្ងួតក្នុងចំការ ក្រោយមកបេះផ្លែទាំងនោះមកដាក់ហាលថ្ងៃ បន្ថែមរយៈពេល ២ ទៅ ៣ ថ្ងៃ បន្ទាប់មកយកទៅចងព្យួរទុកក្រោមផ្ទះ ឬចង្រ្កានបាយដោយពុំចាំបាច់សំរាំងយកគ្រាប់ឡើយ នេះជាការទុកសម្រាប់ដាំលក្ខណៈគ្រួសារ ។




**ផ្លែននោងជ្រុងទុំ អាចបេះយកទៅរក្សាទុកបាន**

## ២.៣.វិធីសាស្ត្ររក្សាទុកគ្រាប់ពូជ

ជាទូទៅការរក្សាទុកគ្រាប់ពូជ សម្រាប់ដាំដុះក្នុងរដូវបន្តបន្ទាប់កសិករភាគច្រើន ជួបនូវបញ្ហាដូចជា ភាគរយនៃដំណុះត្រូវចុះថយខ្លាំង គ្រាប់ពូជត្រូវស៊ីបំផ្លាញដោយសត្វល្អិត ជាពិសេសតួខ្មូត ទាំងនេះបណ្តាលមកពីការប្រមូលពូជពីចំការយឺតយ៉ាវ ការសំរាំងពូជមិនបានត្រឹមត្រូវ ភាពស្ងួតនៃគ្រាប់ពូជមិនល្អ ហើយការទុកដាក់ពុំបានត្រូវតាមបច្ចេកទេសទុកដាក់គ្រាប់ពូជឡើយ ។ ដូចនេះ ដើម្បីជួយអោយការទុកដាក់គ្រាប់ពូជបន្លែ ប្រកបដោយជោគជ័យ អត្ថបទនេះសូមធ្វើការណែនាំដូចតទៅ :

**-ការប្រមូលយកផ្លែ ឬក្លួរទុំពីចំការ** : ត្រូវបេះយកផ្លែ ឬក្លួរដែលទុំពេញលេញ មិនត្រូវទុកអោយទុំរលួយ ឬទុំ ស្ងួតយូរថ្ងៃនៅចំការឡើយ ។

**-ការសំរាំងយកគ្រាប់ពូជ** : ក្រោយពីបេះបានត្រូវពុះ ឬវះយកគ្រាប់ដាក់ត្រាំទឹករយៈពេលមួយយប់ ហើយលាងសំអាតជាតិស្ករជាប់នឹងគ្រាប់អោយស្ងួត ។ ប្រភេទពូជទុំស្ងួត ត្រូវវាយបំបែកសំបក សំអាតអោយស្អាត ហើយរើសយកចេញនូវគ្រាប់ដែលមិនល្អ ឬមានសត្វល្អិតស៊ី ព្រមទាំងមានជំងឺជាពិសេសគ្រាប់ពូជសណ្តែកកួរ និងពោត ។



**ការសំរាំងយកគ្រាប់ត្រប់**




**ផ្លែត្រប់ទុំអាចសំរាំងយកគ្រាប់បាន**

**-ការសំងួតគ្រាប់** ៖ គេត្រូវដាក់ហាលគ្រាប់ពូជអោយស្ងួត ទៅតាមប្រភេទនៃពូជនីមួយៗ ដូចជា គ្រាប់ពូជស្ពៃ ពូជជី ពូជឆី្ន ម្ទេស ត្រប់ ប៉េងប៉ោះ សាលាដ ត្រូវខ្ចប់នឹងសំណាញ់ញឹក ដាក់ហាលថ្ងៃចំនួន ២ ទៅ ៣ ថ្ងៃ រីឯគ្រាប់ពូជ បន្លែដែលមានទំហំធំ ដូចជា ម្រះ ត្រសក់ ល្ពៅ ននោង សណ្តែកកួរ ត្រកួន ឃ្លោក ត្រូវសំងួត អោយស្ងួតរយៈ ពេល ៣ ទៅ ៤ ថ្ងៃអាចទុកបាន (ហាមហាលថ្ងៃក្តៅខ្លាំង ជាពិសេសថ្ងៃត្រង់) ។



**ការហាលគ្រាប់ពូជក្នុងកញ្ចប់សំណាញ់ ការពារកំដៅថ្ងៃ**

**-ការទុកដាក់គ្រាប់ពូជ** ៖ ដើម្បីអោយគ្រាប់រក្សាបាននូវដំណុះ និងជៀសផុតពីសត្វល្អិតបំផ្លាញ គឺ ក្រោយពី សំងួតហើយ គេមិនអាចពន្យាពេលច្រើនម៉ោង ក្នុងការច្រកចូលក្នុងឧបករណ៍ដូចជា ដប ស្បោង ក្រដាស់ស្ងួត កញ្ចប់ ក្រដាសកែវធំៗ ឬកញ្ចប់ក្រដាស់អាលុយមីញ៉ូម ដែលក្នុងកញ្ចប់ ឬកែវទាំងនោះត្រូវច្រកកំទិចធ្យូងស្ងួតខ្លះៗជាមុន ។ ក្រោយពីច្រកគ្រាប់ពូជ ហើយត្រូវដាក់កំទិចធ្យូងស្ងួតតូចៗពីលើគ្រាប់ពូជ ហើយបិទអោយជិត ដើម្បីការពារ បាននូវការស្រូបយកសំណើមពីបរិយាកាសចូលទៅក្នុងគ្រាប់វិញ ពីព្រោះសំណើមគ្រាប់ពូជ និងសំណើមបរិយាកាស ខុសគ្នាខ្លាំង ។ កាលណាគេមិនបានបិទអោយជិត ធ្វើអោយគ្រាប់ពូជងាយទទួលយកសំណើម កាលណាវាសើម បណ្តាលអោយដុះផ្សិត ប៉ះពាល់ដល់ដំណុះនៃគ្រាប់ពូជ ។ ជាពិសេសទៅទៀតគេត្រូវយកកញ្ចប់ ឬកែវដាក់គ្រាប់ពូជ ទៅរក្សាទុកក្នុងទីកន្លែងត្រជាក់ ហើយស្ងួត ហាមត្រូវកំដៅ និងសំណើមជាហេតុបណ្តាលអោយគ្រាប់ពូជងាយ និងខូច ខាត ។



**គ្រាប់ពូជលាយជុំធ្យូងដាក់ក្នុងកែវរក្សាទុក**



**គ្រាប់ពូជលាយធ្យូងដាក់ក្នុងកញ្ចប់ក្រដាស់**

## ២.៤ គុណវិបត្តិនៃការទុកពូជបន្ត

លទ្ធផលនៃការស្រាវជ្រាវរយៈពេលច្រើនឆ្នាំកន្លងមក បានរកឃើញនូវគុណវិបត្តិមួយចំនួនធំ ដោយកសិករមានទំលាប់ដ៏ពិសិដ្ឋមួយគឺ កាលណាដំណាំរបស់គាត់ផ្លែធំល្អ តែងតែរក្សាទុកពូជបន្ត ការធ្វើរបៀបនេះ សមស្របតែរយៈពេល ៣០-៤០ ឆ្នាំមុនប៉ុណ្ណោះ ដោយសារតែសម័យនោះពូជភាគច្រើន ជាពូជបង្កាត់សេរី (OP) ។ ដោយឡែកក្នុងសម័យបច្ចុប្បន្នពូជកាន់តែទំនើបគឺ ពូជកូនកាត់ ឬពូជបង្កាត់ មិនអាចអោយកសិកររក្សាទុកពូជបន្តបានឡើយ ជាពិសេសពូជដែលច្រកក្នុងកញ្ចប់ ឬកំប៉ុង ដែលនាំមកពីបរទេសដូចជា ត្រសក់ចំណារ ខាត់ណាដើម ម្ទេសហាវ៉ៃ ស្ពៃគ្រប់ប្រភេទ ត្រឡាច ល្ពៅ ប៉េងប៉ោះ ត្រប់ជាដើម ដែលមានសញ្ញាអក្សរអេស្វមួយ ($F_1$) ពូជនេះផលិតដោយក្រុមហ៊ុនគ្រាប់ពូជធំៗ ។ កសិករត្រូវចំណាយក្នុងការទិញពីក្រុមហ៊ុនរៀងរាល់រដូវ ។ ដូចអ្នកជំនាញការផ្នែកគ្រាប់ពូជសូមណែនាំដូចតទៅ បើពូជណាមួយមិនស្គាល់នូវប្រភព ឬអត្តសញ្ញាណច្បាស់លាស់សូមមេត្តាកុំទុកពូជបន្ត សម្រាប់រដូវបន្ទាប់ បើពូជប្រពៃណីមានប្រភពត្រឹមត្រូវ អាយុចំណាស់ក្នុងតំបន់របស់ខ្លួន អាចជម្រើសហើយទុកពូជបន្តបាន ។

# ៣ ប្រភេទដំណាំដែលមិនដាំដោយគ្រាប់

មានប្រភេទដំណាំបន្លែខ្លះ ដែលអាចដុះលូតលាស់តាមរយៈគល់-ដើម កំណាត់ទង ឬដើមដូចជា :

## ៣.១ ការដាំឬបន្តពូជដោយគល់ និង មើម

ប្រភេទដំណាំបន្លែ ដែលមានសមត្ថភាពដុះលូតលាស់បន្ត ពីរដូវមួយទៅរដូវមួយទៀតដោយសារគល់ឬមើម មានដូចជា ត្រាវ ក្តាត ងប់ ម្ទេស វល្លិបាស ផ្កាឡៃហ៊ាង រមៀត រំដេង ខ្ញី ស្លឹកគ្រៃ ខ្ទឹមស ក្រហម ខ្ទឹមខ្យល់ ជន្លង់ ។ល។

## ៣.២ ការដាំដោយដើម ឬកំណាត់ទង

បន្លែមួយចំនួន ច្រើនដុះលូតលាស់ពេញមួយឆ្នាំ ហើយប្រជាកសិកច្រើនតែធ្វើការដាំដោយប្រើកំណាត់ទង ឬដើមដូចជា ដើមស្ពៃ ជំឡូងជ្វា ជំឡូងឈើ ត្រកួនទឹក ។ល។ ដើម្បីអោយប្រភេទដំណាំទាំងនេះដុះលូតលាស់ល្អ គេគួរតែកាត់កំណាត់ដើម ឬទង មិនខ្ចី ឬចាស់ពេកអោយបានប្រវែងពី ២៥-៣០ស.ម រួចដាក់ត្រាំទឹកមួយយប់ បន្ទាប់មកយកទៅដាំបាន ។ គេដាំដោយបញ្ចិតដាក់អោយត្រូវទិសប៉ែកខាងចុងចេញផុតពីដី ហើយប៉ែកខាងគល់កប់ចូលទៅក្នុងដី ស្រោចទឹកអោយជោគរាល់ថ្ងៃ ទើបវាដុះពន្លកថ្មីបាន (តារាងទី៥) ។

## តារាងទី ៥ : គំរូចការមើម_ក្តៀង_គល់_ដើម សម្រាប់ដាំដុះ

| ល.រ | ប្រភេទដំណាំ | ដាំដោយ | ផ្ទៃដី 10 $m^2$ | ផ្ទៃដី 1 ha | ចន្លោះគុម្ព និង ជួរ Cm |
|---|---|---|---|---|---|
| | | | ចំនួនគុម្ព | ចំនួនគុម្ព | |
| ១ | ត្រាវ | កូន និង ដើម | ១៥ | ១៥.000 | ១00 x ៧0 |
| ២ | ក្ដាតអន្ទត់ | គល់នៃដើម | ១0 | ១0.000 | ១00 x ១00 |
| ៣ | រមៀត | ដើម | ១៥ | ១៥.000 | ១00 x ៧0 |
| ៤ | ខ្ចាយ | មើម | ២0 | ២0.000 | ១00 x ៥0 |
| ៥ | រំដេង | ក្តៀង | ២0 | ២0.000 | ១00 x ៥0 |
| ៦ | ស្លឹកគ្រៃ | គល់ | ១២ | ១២.000 | ១00 x ៥0 |
| ៧ | ស្លឹកបាស់ | គល់ | ២0 | ២0.000 | ១00 x ៥0 |
| ៨ | ខ្ទឹមក្រហម | កំពិស | ២00 | ២00.000 | ២0 x ២0 |
| ៩ | ខ្ទឹមស | កំពិស | ២៥0 | ៥00.000 | ២0 x ១៨ |
| ១0 | ខ្ទឹមស្លឹក | កំពិស-គល់ | ២00 | ២00.000 | ២0 x ២0 |
| ១១ | វល្លិផ្កាឡៃហ៊ាង | គល់-ទង | ១0 | ១0.000 | ១00 x ១00 |
| ១២ | ដើមស្ពៃ | កំណាត់ដើម | ៥ | ៥.000 | ១00 x ២00 |
| ១៣ | គុយឆាយ | មើមទុំ | ២00 | ២00.000 | ២0 x ២0 |
| ១៤ | ដំឡូងដូង | មើម | ២0 | ២0.000 | ១00 x ២0 |
| ១៥ | ភ្លៅកង្កែប | គល់ | ១៥0 | ១៥0.000 | ៣0 x ៣0 |
| ១៦ | ម្អម | គល់ | ២00 | ២00.000 | ២0 x ២0 |

ប្រភព: លទ្ធផលស្រាវជ្រាវស្ថានីយក្បាលកោះ 2000-2005

## III-ការរៀបចំសួនបន្លែគ្រួសារ

ដើម្បីអោយសមាជិកគ្រួសារនីមួយៗនៅតាមតំបន់ជាច្រើន ស្ទើរពេញផ្ទៃប្រទេសទទួលបានអាហារដែលសំបូរនូវជីវជាតិ រួមទាំង វីតាមីន គេត្រូវទទួលទានអាហារបៃតង ដែលសំបូរនូវសារធាតុចិញ្ចឹម គឺបន្លែគ្រប់ប្រភេទ ដើម្បីមានបន្លែបៃតងប្រកបដោយជីវជាតិសម្រាប់ទ្រទ្រង់សុខភាព គេត្រូវធ្វើការដាំដុះបន្លែជុំវិញលំនៅដ្ឋាន ហើយដើម្បីឱ្យបន្លែនោះលូតលាស់ ធានាបានក្នុងការប្រើប្រាស់ប្រចាំថ្ងៃប្រកបដោយសុវត្ថិភាពល្អ គេត្រូវបង្កើតសួនបន្លែគ្រួសារដោយខ្លួនឯង ។



**សួនបន្លែរបស់កសិករ ចែត សារឿន ក្នុងខេត្តសៀមរាប ២០០៦**

### ១-ទីតាំង និងទំហំសួន

ទីតាំងដែលត្រូវបង្កើតសួនបន្លែគ្រួសារ គឺមិនត្រូវស្ថិតនៅឆ្ងាយពីលំនៅដ្ឋានឡើយ គេត្រូវបង្កើតវានៅចំហៀង ឬ ពីក្រោយផ្ទះដែលមានលំហវាលស្រឡះជាបង្គួរ គឺស្ថិតនៅចន្លោះដំណាំឈើហូបផ្លែផ្សេងៗ ឬ ទីវាល រួមទាំងងាយស្រួលក្នុងការយកទឹកទៅស្រោចស្រពនៅរដូវរាំងស្ងួត ព្រោះដំណាំខ្លះវាត្រូវការទឹកស្ទើររាល់ថ្ងៃ តែដំណាំខ្លះទៀត វាត្រូវការទឹក ៣-៤ ថ្ងៃម្តងប៉ុណ្ណោះ ពុំត្រូវការបរិមាណទឹកស្រោចស្រពច្រើននោះឡើយ ។

អំពីទំហំសួនបន្លែ : ជាទូទៅទំហំនៃសួននីមួយៗ វាអាស្រ័យទៅនឹងបរិមាណប្រើប្រាស់ ចំនួនសមាជិកគ្រួសារ ជាពិសេសត្រូវគិតអំពីពលកម្មថៃទាំ ។ តែទោះជាយ៉ាងណាក៏ដោយ ទំហំជាមធ្យមពី ៧០ម៉ែត្រការ៉េ ទៅ ១២០ម៉ែត្រការ៉េ គឺ (៧ ម × ១០ម), (៨ម × ១០ម), (៩ម × ១០ម), (១០ម ×១០ម) (១១ម × ១១ម ) តែធំជាងគេបំផុត គឺ ១២ម ×១២ម ប៉ុណ្ណោះ ។



**របៀបបង្ហាញទំហំនឹងទីតាំងសួន**

## ២-របៀបធ្វើសួនបន្លែ

ក្រោយពីកំណត់ទីតាំងបានហើយ គេត្រូវដាក់ខ្សែបន្ទាត់ទៅតាមទ្រង់ទ្រាយនៃដីដែលជ្រុងនីមួយៗ (៤ជ្រុង) ត្រង់បន្ទាត់មកកំណត់ចំណុចដែលត្រូវដាំបង្គោលធ្វើរបងសួន ព្រមទាំងទុកច្រកចេញចូលមួយងាយក្នុងការយកទឹក, ស្រោចកូនដំណាំ ជី រួមទាំងការចេញចូលថែទាំ និងប្រមូលផល។ បង្គោលរបងដាំចំងាយពីគ្នាប្រវែង ១,២០ម ប្រវែងបង្គោលត្រូវកាត់ គឺ ១,៣០ម ហើយជំរៅក្នុងការដាំធ្វើយ៉ាងណាអោយកំពស់របងជាមធ្យម ៧០-៨០ស.ម ក្រោយពីការដាំបង្គោលហើយ ត្រូវយកបន្ទះឫស្សី ឬ កូនឈើមូលវែងៗ ត្រង់ៗមកវាយជារបារ ចំនួន ៣ ឬ ៤ ធ្វើយ៉ាងណាអោយមាំការពារសត្វពាហនៈផ្សេងៗដែលលែង ឬ ដាច់ខ្សែចូលស៊ីដំណាំ ។ ច្រកចេញចូលត្រូវធ្វើទ្វារ បិទបើកអោយមាំ ។



**ការធ្វើសួនដោយកសិករផ្ទាល់**

## ៣-ការរៀបចំដីក្នុងសួន

ក្រោយពីធ្វើរបងសុវត្ថិភាពសួនរួចហើយ ត្រូវកាប់បំផុសដីអោយសព្វពេញផ្ទៃសួន វាយបំបែកអោយល្អិត ប្រមូលយកស្មៅចេញអោយស្អាត ហើយហាលដីអោយស្ងួតរយៈពេល ១អាទិត្យ ។ បន្ទាប់មកកាប់ជ្រោយដីនោះឡើងវិញអោយជ្រៅ ហើយអោយធូរ ប្រមូលយកស្មៅចេញ ទើបរៀបចំលើករងសម្រាប់ដាំដំណាំដែលត្រូវដាំគឺ :



**គំរូប្លង់សួនបន្លែគ្រួសារ**

**រង្វង់ទី១ :** នៅផ្ទៃខាង១ជាប់របងទទឹងរង ៦០សម កំពស់ ២៥ ឬ ៣០សម កៀវអោយស្មើរួចកាប់រណ្ដៅចំងាយពីគ្នា ៧០សម ចំពីលើរងជំរៅ ៣០សម ជាមធ្យម ទំហំរណ្ដៅ (២៥សម x ២៥សម) ហើយដាក់ជីកុំប៉ុស្តិ៍នៅបាតរណ្ដៅទំងន់ ២ ទៅ ៣គក្រ សម្រាប់ដាក់ដាំពួកបន្លែយូរ មានដើមងប់ ដើមស្ពៃ ដើមម្រុំ មើមរំដេង ស្លឹកគ្រៃ ខ្ទាយ, រមៀត ព្រមទាំងននោងវែង ឬ ត្រឡាច ដែលវាបោះទងវែង ហើយទន្ទ្រានលើគេឯង ។

**រង្វង់បន្ទប់១ក្នុងសួន :** ចំច្រកចេញចូលត្រូវទុកផ្លូវដើរទទឹង ៥០ស.ម រហូតដល់កណ្ដាលសួន ហើយចែកចេញទៅស្ដាំ និងទៅឆ្វេងដៃទំហំដូចគ្នា ដើម្បីចែកផ្ទៃសួនជា ៣ផ្នែកធំ១ (សូមមើលប្លង់) ក្នុងផ្នែកនីមួយ១ត្រូវធ្វើរងដំណាំដែលមានទទឹងប្រវែង ១ម កំពស់ ២៥ ស.ម ហើយចន្លោះរងនីមួយ១ ២៥ ស.ម ធ្វើយ៉ាងនេះ គេអាចមានរងជាច្រើនសម្រាប់ដាំដំណាំដែលគេនិយមប្រើប្រាស់ក្នុងគ្រួសារ ។



**ការរៀបចំដីក្នុងសួនបន្លែ**

## ៤.ការដាំ និងថែទាំដំណាំក្នុងសួន

ដើម្បីអោយសួនបន្លែមានសោភ័ណភាពល្អ និងទាក់ទាញអារម្មណ៍ នៃសមាជិកគ្រួសារ ក៏ដូចជាអ្នកជិតខាង គេត្រូវធ្វើការដាំដុះដូចតទៅ :

- ផ្នែខាង១នៃរបងសួន : ផ្នែកខាងមុខជាប់របងត្រូវដាំដើមល្ហុងលាយម្រុំ ផ្នែកពាក់កណ្ដាលខាងមុខចំហៀងសួនខាងស្ដាំ ដាំដើមងប់ដោយគ្រាប់ ឬ ដោយគាស់គល់ និងដាំដោយកាត់ដើមចេញ ។ ពាក់កណ្ដាលខាងមុខចំហៀងសួនខាងឆ្វេង ដាំពពួកឡើងទ្រើង ដូចជាពពាយ ឬ វល្លិ៍មេឡៃប៉ាង ។ ប៉ែកខាងក្រោយនៃសួន ដាំននោងវែង ត្រឡាចផ្អែរ ឬ ឃ្លោក ព្រោះវាលូតលាស់យូរ ហើយបោះទងឆ្ងាយ ងាយធ្វើ ផ្អែរក្រៅសួនជាប់របង ។

-ផ្នែកណ្ដាលសួន គេដាំដូចជា ម្រុំ សណ្ដែកកួរ ដើមស្លឹកបាស់ ម្ទេស ប៉េងប៉ោះ និងត្រប់ នៅរង្វង់ទី២ ជាប់ពីរង្វង់ទី១ ។ ហើយក្រៅពីនោះ គេដាំដូចជា ជីរណា ជីម្រះព្រៅ ជីនាងវង ផ្ទី ស្ពៃចង្កឹះ ឬ ស្ពៃខៀវ ជន្លង់ ខ្ទឹមស្លឹក ត្រសក់ចំណារ រួមជាមួយបន្លែឯទៀត ដែលមានអាយុកាលលូតលាស់ខ្លី ហើយតំរូវការពូជក្នុងការដាំដុះក្នុងសួន សូម មើលចំណុចទី "៥" ។

## ៥.តំរូវការគ្រាប់ពូជសម្រាប់ដាំដុះ

ជាទូទៅ គ្រាប់ពូជបន្លែមានទំហំ និងទំងន់ខុស១គ្នា ជាពិសេសទៅទៀត អត្រាដំណុះរបស់ពូជនីមួយ១ ក៏ខុសគ្នាដែរ វាអាស្រ័យទៅនឹងវិធីសាស្ត្រទុកដាក់ រួមទាំងរយៈពេលនៃការរក្សាទុកផងដែរ ដូចនេះបរិមាណគ្រាប់និងតំរូវការក៏ដូចគ្នាដែរ ។ កាលណាដំណាំដែលមានគ្រាប់តូច ហើយប្រភេទដែលដាំ ឬស្ទូងចំនួនដើមច្រើនក្នុងមួយថ្នាល១

តំរូវការ បរិមាណជាបង្គួរ ឧទាហរណ៍ គ្រាប់ជីរបន្លា ឬ ជីរបារាំង គ្រាប់ម្ទម គ្រាប់ជីរនាងវង គ្រាប់ផ្ទី គ្រាប់ស្ពៃ គ្រាប់ ម្រះព្រៅ ។ល។ ក្រៅពីនោះទៀត ប្រភេទគ្រាប់តូចល្អិតដែរ តែការដាំដុះរឡើល ដូចជា ម្ទេស ត្រប់ ប៉េងប៉ោះ សាលាដក្តោប ខាត់ណាផ្កា ខាត់ណាដើម ខាត់ណាក្តោប គេតំរូវការបរិមាណគ្រាប់តិច ។ ចំពោះប្រភេទពូជដំណាំ គ្រាប់ធំដូចជាត្រសក់ ម្រះ ល្ពៅ ននោង ពពាយ សណ្តែកកួរ សណ្តែកបារាំង ។ល។ គេត្រូវការបរិមាណគ្រាប់ច្រើនជាបង្គួរជាងដំណាំឯទៀត ដោយសារតែគ្រាប់ធំ ហើយមានទំងន់ធ្ងន់ ( សូមមើលតារាងទី ៦ អំពីតំរូវការពូជ ) ។

ក្រៅពីដំណាំដែលដាំដោយគ្រាប់ នូវមានដំណាំដែលដាំដោយទង ដោយគល់ ដោយកំពិស ដោយមើម គេត្រូវការចំនួន និងទំងន់ក៏ខុសគ្នាដែរ ។ ដូចនេះដើម្បីអោយអ្នកដាំដុះងាយយល់ដឹង អំពីតំរូវការនេះ សូមបញ្ជាក់ជូនក្នុងតារាងទី ៦ ដូចតទៅ :

### តារាងទី ៦ : តំរូវការទំងន់គ្រាប់ពូជ និងចំនួនកូនសម្រាប់ដាំដុះ

| ល.រ | ប្រភេទដំណាំ | លើផ្ទៃដី 10 $m^2$ | | លើផ្ទៃដី 1 ha (10.000 $m^2$) | | ចន្លោះគុម្ព និង ជួរ (ស.ម) |
|---|---|---|---|---|---|---|
| | | ទំងន់ពូជ (ក្រាម) | ចំនួនកូន (ដើម) | ទំងន់ពូជ (ក្រាម) | ចំនួនកូន (ដើម) | |
| ១ | ម្ទេសហាវ៉ៃ | ០,២០ | ២០ | ២០០ | ២០.០០០ | ៥០ x ៦០ |
| ២ | ម្ទេសដៃនាង | ០,៣០ | ១៩ | ៣០០ | ១៩.០០០ | ៥០ x ៧០ |
| ៣ | ម្ទេសគុយទាវ | ០,២០ | ១៨ | ២០០ | ១៨.០០០ | ៥០ x ៨០ |
| ៤ | ប៉េងប៉ោះ | ០,១៥ | ២០ | ១៥០ | ២០.០០០ | ៥០ x ៦០ |
| ៥ | ត្រប់ស្រួយ | ០,១៥ | ១៨ | ១៥០ | ១៨.០០០ | ៦០ x ៦០ |
| ៦ | ត្រប់វែង | ០,១៨ | ១៥ | ១៨០ | ១៦.០០០ | ៧០ x ៩០ |
| ៧ | ត្រប់ក្រាមរមាស | ០,១៨ | ១៥ | ១៨០ | ១៦.០០០ | ៧០ x ៩០ |
| ៨ | ខាត់ណាក្តោប | ០,៣០ | ៤០ | ៣០០ | ៤០.០០០ | ៥០ x ៤០ |
| ៩ | ខាត់ណាដើម | ១២ | ២០០ | ១២០០០ | ២០០.០០០ | ២០ x ២០ |
| ១០ | ស្ពៃចង្កឹះ ឬ ខ្សៀវ | ០,៩០ | ២៥០ | ៩០០០ | ២៥០.០០០ | ១៥ x ១៥ |
| ១១ | ត្រឡាច | ០,២០ | ១៥ | ២០០០ | ១៤.៩០០ | ១០០ x ២០០ |
| ១២ | ល្ពៅ | ០,១៥ | ១៥ | ១៥០០ | ១៤.០០០ | ១០០ x ២០០ |
| ១៣ | ត្រសក់ចំណារ | ០,៥០ | ១០០ | ៥០០០ | ២០០.០០០ | ២០ x ៥០ |
| ១៤ | ត្រសក់ស្រូវ | ០,៣០ | ១៤ | ៣០០០ | ១៤.០០០ | ១០០ x ២០០ |
| ១៥ | ននោងមូល | ០,៣៥ | ១០ | ៣៥០០ | ១០.៩៩៩ | ៣០ x ៣០០ |
| ១៦ | ននោងជ្រុង | ០,៤០ | ១៥ | ៤០០០ | ១២.០០០ | ៣០ x ២៥០ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | ម្រះ | ០,៥០ | ១០០ | ៥០០០ | ១០០.០០០ | ៥០ x ២០ |
| ១៨ | សណ្តែកកួរ | ៨,០០ | ៨០ | ២០.០០០ | ៨០.០០០ | ៥០ x ៥០ |
| ១៩ | ជីរនាងវង | ០,១០ | ១០០ | ២០០០ | ១០០.០០០ | ៣០ x ៣០ |
| ២០ | ជីររណា | ០,១០ | ៤០០ | ២០០០ | ៤០០.០០០ | ១៥ x ១៥ |
| ២១ | ត្រកួនគោក | ១០០ | ៥០០ | ៦០០ | ៥០០.០០០ | ២០ x ១៥ |
| ២២ | សណ្តែកបារាំង | ២០ | ១០០ | ៣០.០០០ | ១០០.០០០ | ៥០ x ៣០ |
| ២៣ | ឃ្លោក | ០,២០ | ៨ | ២៥០ | ៨០.០០០ | ២០០ x ៣០០ |
| ២៤ | អូក្រា | ១០ | ៤០ | ៣០០០ | ៤០.០០០ | ៥០ x ៦០ |
| ២៥ | ជីរវ៉ាន់ស៊ុយ | ១៥ | ២០០ | ៨០០០ | ២០០.០០០ | ២០ x ២០ |
| ២៦ | ការ៉ុត | ៤ | ១៨០ | ៤០០០ | ២០០.០០០ | ២០ x ២០ |
| ២៧ | ឆៃថាវ | ៣ | ១៥០ | ៣០០០ | ២០០.០០០ | ២០ x ២០ |
| ២៨ | ខ្ទឹមបារាំង | ៤ | ២០០ | ៦០០០ | ២០០.០០០ | ១៥ x ២០ |

## IV-ការគ្រប់គ្រងជំងឺ-សត្វល្អិត និងការការពារ

### ១-អំពីជំងឺសំខាន់ៗ និងការការពារ

ជាទូទៅដំណាំបន្លែ តែងតែទទួលរងជំងឺសំខាន់ៗជាច្រើនក្រុម និង ច្រើនប្រភេទ ដែលមានលទ្ធភាពចំលង និង បង្ករោគ ដោយសារកត្តាមួយចំនួនដូចជា : ការឆ្លងតាមរយៈគ្រាប់ពូជ ឆ្លងតាមរយៈទឹកស្រោច ឆ្លងតាមរយៈដីមិនបានអនាម័យ ឆ្លងតាមរយៈសត្វល្អិតជាអ្នកចំលង និងឆ្លងតាមអំពើនៃអាកាសធាតុ ។ គេអាចបែងចែកជំងឺ ជា ៥ ក្រុមដូចតទៅ :

#### ១.១-ក្រុមជំងឺផ្សិត

ជំងឺនេះមានច្រើនសណ្ឋានបំផ្លាញដំណាំក្នុងដំណាក់កាលផ្សេងគ្នា ហើយទៅលើផ្នែកផ្សេងៗនៃបន្លែ ដូចជា :

**១.១.១-ជំងឺរលួយគល់កូនដំណាំ (Damping-off)**

កូនដំណាំបន្លែស្ទើរគ្រប់ប្រភេទក្រោយពីដុះបានរយៈ ៥ ទៅ ១០ ថ្ងៃ ក្នុងដំណាក់កាលកូនសំណាបខ្ចីៗ តែងតែរលួយគល់ក្បែរៗដី ធ្វើអោយបាត់បង់ចំនួនកូនដំណាំជាច្រើន កសិករខ្លះពុំទទួលបានកូនដំណាំដាំដុះឡើយ ។ វាបណ្តាលមកពីកត្តាជាច្រើនដូចជា :

+ ដីថ្នាលសំណាប : ដីសម្រាប់សាប ឬបណ្តុះកូនស្តុកមេរោគ

+ ទឹកសម្រាប់ស្រោច : មេរោគរស់នៅក្នុងទឹក

+ គ្រាប់ពូជមានជំងឺ : ពូជមិនធន់ទ្រាំ ហើយគ្រាប់ពូជត្រូវបានជាប់មេរោគមកជាមួយ

+ សំណើមដីថ្នាលសើមខ្លាំង : ក្នុងវគ្គដុះពន្លកថ្នាលសំណាប ឬ កន្ទោងបណ្តុះសើមខ្លាំងលើសតំរូវការ

+ បរិយាកាសមិនល្អ : អាកាសធាតុក្តៅ គ្មានពន្លឺ និងខ្យល់ចេញចូល ភ្លៀងធ្លាក់ខ្លាំង ហើយញឹកញាប់



**កូនត្រសក់កើតជំងឺរលួយគល់**

**វិធានការការពារ** : ដើម្បីទប់ទល់ នឹងជំងឺនោះ គេអនុវត្តវិធីសាស្ត្រជាច្រើនដូចជា : ការកាប់ហាលដីថ្នាលអោយស្ងួត ដីសម្រាប់បណ្តុះក្នុងកន្ទោងត្រូវដុតសំលាប់មេរោគ ថ្នាលសំណាបមុនសាបត្រូវដុតដីជាមុន ធ្វើដំបូលគ្របការពារភ្លៀង ឬកំដៅថ្ងៃ ទីថ្នាលសំណាបគួរស្ថិតនៅទួលស្រឡះល្អ គ្រាប់ពូជត្រូវលាយជាមួយថ្នាំសំលាប់ផ្សិត

មុនសាប ឬ ដាំ បន្ថយការស្រោចទឹកពេលមានជំងឺ មិនត្រូវស្រោចបំប៉នជីឡើយពេលមានសញ្ញាបំផ្លាញ ត្រូវដកកូនដែលរលួយនោះចេញភ្លាម ក្រោយមកយកថ្នាំការពារផ្សិតទៅលាយទឹកស្រោចអោយជោក ។

**១.១.២ -ជំងឺផ្សិតគល់**

លក្ខណៈនៃការបំផ្លាញដោយជំងឺនេះមានរូបសណ្ឋានតែមួយគត់ គឺ កើតលើគ្រប់ដំណាំក្នុងវគ្គអោយផល ដូចជា ពោត សណ្តែកកួរ ម្ទេស ត្រប់ ប៉េងប៉ោះ ត្រសក់ ឪឡឹក ។ វាចាប់ផ្តើមធ្វើអោយគល់រលាក ហើយដុះចេញសរសៃផ្សិតស១ក្បែរដី ក្រោយមកដុះចេញគ្រាប់ផ្សិតពណ៌ព្រឿងជាគ្រាប់១ដូចពងត្រី (Southern Blight)



**ជំងឺផ្សិត កើតលើគល់ម្ទេស និង ប៉េងប៉ោះ**

ពេលខ្លះវាកើតលើផ្លែដែលនៅប៉ះដីសើមដូចជា ត្រឡាច ឪឡឹក ល្ពៅ សណ្តែកកួរ ត្រសក់ស្រូវ ។ល។ ធ្វើអោយផ្លែរលួយដុះផ្សិត ។ កត្តាដែលបណ្តាលអោយកកើតគឺ :

+ **ដីស្តុកទុកមេរោគ** : គឺការប្រើប្រាស់ដីដាំដំណាំដដែល១ ក្រោយពេលប្រមូលផលចប់កសិករតែងទុកកាកសំណល់ដំណាំដែលផ្ទុកមេរោគនៅរាយប៉ាយលើដី ។

+ **ការប្រើប្រាស់ជីកុំប៉ុស្តិ៍មិនទាន់ពុក** : កុំប៉ុស្តិ៍ដែលផ្សំពីកាកសំណល់ដំណាំលាយជាមួយលាមកសត្វ គ្រប់ប្រភេទមិនទាន់ពុកផុយល្អ ឬការផ្សំជីកុំប៉ុស្តិ៍ ពុំបានប្រើកំបោរសំលាប់មេរោគដែលជាប់នឹងកាកសំណល់ ។

+ **ប្រភពទឹកមិនល្អ** : ទឹកដែលយកមកស្រោចស្រពពីទឹកស្រះដែលផ្ទុកដោយកាកសំណល់ដំណាំមានមេរោគរលួយ ។

+ **ដីហាប់ណែន** : ដីខ្លះល្អិតក្រោយពីភ្លៀងដក់ក្នុងចំការដំណាំ ឬក្រោយពីបញ្ចូលទឹកលិចជោកជាំលើផ្ទៃរងក្រោយ ពីដីនោះស្ងួត ជំងឺលេចចេញភ្លាម ។

+ **អាកាសធាតុមិនល្អ** : ពេលអាកាសធាតុរវាងពេលយប់ និងពេលថ្ងៃខុសគ្នាខ្លាំង (សីតុណ្ហភាព សំណើមបរិយាកាស ថ្ងៃក្តៅខ្លាំងហើយស្ងួត ពេលយប់ត្រជាក់សើម )។

+ **ពូជមិនធន់ទ្រាំ** : ប្រភេទពូជមួយចំនួនងាយទទួលរង នូវការបំផ្លាញ ដោយសារសមត្ថភាពធន់ទ្រាំទាប ។

**វិធានការការពារ:** ដើម្បីទប់ទល់នឹងជំងឺនេះ គេត្រូវអនុវត្តនូវវិធានការចំបង។ដូចជា: មិនត្រូវបញ្ចូលទឹកអោយលិចរងដំណាំឡើយ គ្របការពារកំដៅដី ដោយរុក្ខជាតិឬកាកសំណល់ស្ងួត ដូចជាកំប្លោក ឬចំបើងក្នុងរដូវក្តៅ ប្រើ ជីកុំប៉ុស្តិ៍ពុកផុយល្អ ផ្លាស់ប្តូរមុខដំណាំអោយទៀងទាត់ សំអាតស្មៅអោយល្អ រៀបចំដីមុនដាំឱ្យបានច្រើនដង សំអាតចំការក្រោយពេលប្រមូលផល បន្ថយការស្រោចទឹកពេលលេចចេញជំងឺនេះ គេប្រើថ្នាំសំលាប់ផ្សិតប្រភេទទង់ដែង អុកស៊ីដ គឺខុបភើ (Copper by droxide) យកមកលាយទឹកស្រោច ឬបាញ់ក៏រិត ៣០ក្រាម (១ ស្លាបព្រាបាយពេញ ទឹក១៥ លីត្រ) ៥ ថ្ងៃម្តង គេប្រើតែ ២ ឬ ៣ ដងប៉ុណ្ណោះ ។

**១.១.៧-ជំងឺផ្សិតលើស្លឹក និង ផ្លែ**

លើគ្រប់ដំណាំទាំងអស់ ទាំងដំណាំស្លឹក ដំណាំផ្លែ ដំណាំមើម មានជំងឺផ្សិតជាច្រើន ដែលកើតលើស្លឹក និងផ្លែ ដូចជា :

**-ជំងឺផ្សិតម្សៅ** : វាកើតលើស្លឹក សណ្តែកកួរ ត្រសក់ ឪឡឹក ត្រឡាច ល្ពៅ ប៉េងប៉ោះ ភាគច្រើននៅរដូវត្រជាក់ស្ងួត និងរដូវប្រាំងក្តៅហួតហែង (Powdery mildew)



**ជំងឺផ្សិតម្សៅកើតលើស្លឹកដំណាំអំបូរត្រសក់**

**ការកកើតគឺ** : មានលេចចេញ ជាដំណក់ម្សៅកញ្ចុំ។នៅពេលព្រឹកព្រលឹមចំនួន ២ ទៅ ៣ ថ្ងៃដំបូង ក្រោយមកចាប់ផ្តើមមានម្សៅស។ ដាស់ពេញស្លឹក ក្នុងរយៈពេលពី ៥-១០ ថ្ងៃ ធ្វើអោយស្លឹកដំណាំស្ងួតជ្រុះ ដំណាំលែងអោយផល ។

**ការការពារ និងកំចាត់** : ត្រូវបាញ់ទឹកលាងស្លឹកពេលព្រឹកព្រលឹម ក្រោយពីពិនិត្យឃើញ មានដំណក់ម្សៅជាលើកដំបូង ក្រោយមកគេត្រូវយកថ្នាំសំលាប់ផ្សិតប្រភេទ ម៉ែនកូសែប (Mancozeb) មកលាយទឹកក្នុងក៏រិត ៣០ ទៅ ៤០ក្រាម (២-៣ ស្លាបព្រាបាយស្មើ។) លាយទឹក ១៥ លីត្រ បាញ់អោយជោគ ៣ ថ្ងៃម្តង។ ចំនួន ២ ឬ ៣ ដង ។

**-ជំងឺធ្មុំស្លឹក** : វាកើតលើដំណាំអំបូរត្រសក់ ល្ពៅ ម្រះ ត្រឡាច ប៉េងប៉ោះ សណ្តែកកួរ ជាពិសេសនៅរដូវភ្លៀងធ្លាក់ញឹកញាប់ (Downy mildew)



**ជំងឺទុំស្លឹក  កើតលើដំណាំអំបូរត្រសក់ និង សណ្តែក**

**ការកកើត** :  ដំបូងសង្កេតឃើញ  ស្លឹកក្រោមៗក្បែរៗដីមានលេចឡើងសញ្ញាពណ៌លឿងផ្នែកខាងលើនៃស្លឹក ដោយដុំៗ  ក្រោយមក  រយៈពេលតែ  ៤  ទៅ  ៥ថ្ងៃ  ចំណុចលឿងនោះបានបង្ហាញនូវស្នាមលឿងទុំ  ហើយស្ងួតជាបណ្តើរៗ ទៅជាត្នោតខ្ចី ក្រោយមកភាពស្ងួតនោះបានរីកជារង្វង់ៗធំឡើងៗ  ។

**វិធានការការពារ** :   គេត្រូវកាត់ស្លឹកក្រោមៗក្បែរៗដីចេញពីចំការ  បន្ថយការស្រោចទឹក  ផ្អាកការដាក់ជីបំប៉ន  ព្រោះមេរោគនេះវារីកលឿន  ដោយសារតែធាតុអាសូត  (N)  វិធីសាស្ត្រដាំដុះ  គឺប្តូរមុខដំណាំ  សំអាតចំការដោយ ដកដើមយកទៅដុតចោល  ក្រោយពីប្រមូលផល  ហាមដាំដំណាំអំបូរត្រសក់ដដែលៗ  ។

**-ជំងឺធ្យូងស្លឹក** :   គេអោយឈ្មោះថា  ជាជំងឺធ្យូងស្លឹក  ព្រោះដំណាំដែលកើតជំងឺនេះ  តែងមានស្លឹកស្ងួតពណ៌ខ្មៅ ដូចកំទិចធ្យូង  ច្រើនតែកើតនៅរដូវក្តៅ ចុងរដូវប្រាំង និងដើមរដូវវស្សា (Black Leaf mold)

**ការកកើត** :  ដំណាំមួយចំនួនដែលតែងកើតជំងឺនេះមាន  ប៉េងប៉ោះ  សណ្តែកកួរ  ត្រសក់ចំណារ  ឪឡឹក  ម្រះ  ជីតាំងឱ  ជីនាងវង រួមជាមួយដំណាំឯទៀត   ។



**ជំងឺធ្យូងស្លឹក  កើតលើស្លឹកប៉េងប៉ោះ  ម្ទេស និង សណ្តែកកួរ**

ដំបូងគេពិនិត្យឃើញស្លឹកក្រោមៗក្បែរដី មានចំណុចពណ៌ត្នោត ហើយគល់ដំណាំមានស្នាមស្នួតពណ៌ខ្មៅ ក្បែរដី បន្ទាប់មកចំណុចជាំនោះស្ងួតលេចចេញម្សៅ ដូចកំទិចធ្យូងម៉ត់ នៅពីលើស្លឹក ផ្ទៃស្លឹកទាំងមូលចាប់ផ្តើមរមូរក្តោបឡើងលើ វាបន្តពីស្លឹកក្រោមឡើងមកលើ ហើយជ្រុះជាបណ្តើរៗ ។

**វិធានការការពារ :** នៅពេលលេចចេញសញ្ញាដូចបញ្ជាក់ខាងលើ គេចាប់ផ្តើមកាត់ស្លឹកក្រោមចេញអោយអស់ បន្ថយ ឬផ្អាកការស្រោចទឹកចំនួន ២-៣ ថ្ងៃ ដោយបាញ់ថ្នាំការពារជំងឺផ្សិតប្រភេទ Methomyl កំរិត ២៥ក្រាម (១ស្លាប ព្រាបាយពេញ) លាយទឹក ១៥ លីត្រ បាញ់អោយជោគទាំងគល់ក្បែរដី និងផ្ទៃស្លឹក ២ ថ្ងៃម្តង ចំនួន ២ ឬ ៣ ដង រួចបញ្ឈប់ការបាញ់ ។

## ១.២. ក្រុមជំងឺវីរ៉ុស

មានជំងឺវីរ៉ុសជាច្រើនប្រភេទផ្សេងៗគ្នា ដែលកើតលើដំណាំបន្លែ ហើយវីរ៉ុសទាំងនោះ មានលក្ខណៈឆ្លងច្រើនយ៉ាងពីដើមមួយទៅដើមមួយ ពីរដូវមួយទៅរដូវមួយ ។ កត្តាដែលទាក់ទងទៅនិងការឆ្លង និងកកើត នូវជំងឺ វីរ៉ុសអោយឈ្មោះថា មូសាអ៊ិច វីរ៉ុស (Mosaic Virus) មាន ៣យ៉ាងសំខាន់ៗគឺ :

### ១.២.១ -ការឆ្លងតាមរយៈគ្រាប់ពូជ

ឆ្លងរបៀបនេះច្រើនតែកើតក្នុងវគ្គលូតលាស់ដំបូងមុនចេញផ្កា ឬកំពុងចេញផ្កា ដូចជា ម្ទេស ប៉េងប៉ោះ ត្រសក់ចំណារ ឪឡឹក សណ្តែកកួរ ត្រឡាច ល្ពៅ ននោងជ្រុង ករណីនេះគឺ កើតចេញពីការជ្រើសរើសពូជមេបាពីរដូវមុនមិន បានសំរាំងដើមដែលមានផ្លែល្អធ្វើពូជរក្សាទុក មានន័យថា ដើមនោះបានកើតជំងឺនេះរួចហើយ ហើយផ្លែរបស់ វាមានគ្រាប់ ដែលមានជំងឺនេះស្កុកក្នុងកំពឹងដំណុះរួចជាស្រេច (Embryo of Seed) ។

### ១.២.២ -ការឆ្លងតាមបរិស្ថាន

មានពូជថ្មីមួយចំនួន ដែលពុំទាន់មានប្រវត្តិដាំដុះក្នុងតំបន់នេះ វាត្រូវការនូវលក្ខខណ្ឌអាកាសធាតុដ៏ល្អ ឬពូជមួយដែលវាប្រកាន់រដូវមានន័យថា លក្ខខណ្ឌរដូវដែលដាំដុះនេះ មិនសមប្រកបទៅនឹងលក្ខណៈសម្បត្តិរបស់ពូជធ្វើអោយលេចចេញនូវជំងឺវីរ៉ុសជាច្រើន ហើយមិនទទួលបានផល ដូចជា ប៉េងប៉ោះ ពូជប្រពៃណីមិនអាចដាំនៅរដូវភ្លៀងបានឡើយ ច្រើនតែរួញ ឬម្យ៉ាងទៀតវាឆ្លងជម្ងឺតាមរយៈដីដែលបន្សល់ទុកនូវមេរោគ ។

### ១.២.៣ -ការឆ្លងតាមសត្វល្អិតជាភ្នាក់ងារបង្ករោគ

អំពើនៃការចំលងមេរោគជំងឺវីរ៉ុសពីសត្វល្អិត ទៅដល់ដណាំគឺ បណ្តាលមកពីចំលង និងបញ្ចូលដោយភ្នាក់ងារបង្ក រោគម្យ៉ាងឈ្មោះ មូសាអ៊ិច (Mosaic) ។ សត្វល្អិតទាំងនោះមានច្រើន ហើយការចំលងជំងឺវីរ៉ុស ប្រភេទផ្សេងៗគ្នា ដូចជា:

**-សត្វរុយស (White fly)** វាមានមាឌតូចៗ សៗនៅក្រោមស្លឹកដំណាំគឺ ស្លឹកងប់ ស្លឹកបាស់ ស្លឹកប៉េងប៉ោះ ស្លឹកម្ទេស ស្លឹកត្រប់ ស្លឹកត្រសក់ ស្លឹកល្ពៅ ស្លឹកត្រឡាច លេចចេញជាសញ្ញារួញពីត្រួយមកមុន ក្នុងវគ្គបង្កបង្កើត និងបន្តពូជ នៃដំណាំ គឺរួញហើយពណិលឿង មិនធ្វើអោយដំណាំងាប់ឡើយតែបាត់បង់ទិន្នផល ។



**រុយស ជញ្ជក់ស្លឹក**



**វីរុសកើតមកពីរុយសជញ្ជក់**

**-សត្វមមាចខៀវជញ្ជក់ស្លឹក (Leaf hopper)** វាមានមាឌតូចរាងជ្រុងៗ ខ្នងស្រួចពណិខៀវ ឬបៃតងដូចស្លឹកដំណាំ ហើយតែងតែជ្រកក្នុងស្មៅ និងក្រោមស្លឹកដំណាំជាពិសេសគឺ ដំណាំឪឡឹក ត្រសក់ ល្ពៅ ត្រឡាច អូក្រា ម្ទេស ប៉េងប៉ោះ ម្រះ ត្រប់ ននោង ។ ក្រោយពីវាជញ្ជក់ស្រូបយកជីវជាតិពីដំណាំធ្វើអោយស្ងួតស្លឹករមូរ ហើយពណិលឿងក្នុងវគ្គជិតអោយផល ។



**ស្លឹកត្រប់ស្ងួត ក្រោយពីមមាចខៀវជញ្ជក់**

**-សត្វចៃមាន ចៃម្សៅ ចៃបៃតង និងចៃខ្មៅ:** ចៃទាំង៣ប្រភេទនេះបំផ្លាញដំណាំផ្សេងៗពី គ្នាដូចជា:

+ **ចៃម្សៅ** (Powder aphid) វាបំផ្លាញ ប៉េងប៉ោះ ត្រប់ ម្ទេស និងដំណាំឈើហូបផ្លែ ធ្វើអោយផលដំណាំចុះទាបយ៉ាងខ្លាំង ទាំងបរិមាណ និងគុណភាព ព្រមទាំងបាត់បង់រសជាតិ ។

+ **ចៃបៃតង** (Green peachaphid) ចៃប្រភេទនេះចូលចិត្តបំផ្លាញដំណាំ ស្ពៃក្រញាញ់ ត្រសក់ចំណារ ផ្ទៃថាវ ត្រឡាច សណ្តែកហោឡាំងតាវ ម្ទេសហាវៃ ស្លឹកបាស់ ជីរនាងវង ជីររណា ម្រះ ជីតាំងឱ វាបំផ្លាញលក្ខណៈជាក្រុមធ្វើអោយស្លឹកដំណាំរួញកើតជាជំងឺវីរុស ។



**ចៃបៃតងជញ្ជក់ស្លឹកដំណាំអំបូរស្ពៃ**

+ **ចៃខ្មៅ** (Black aphid ឬ Legumaphid) ការបំផ្លាញខ្លាំងលើដំណាំសណ្តែកកួរ ធ្វើអោយរួញទាំងដើម ស្លឹក និងកួរ បំផ្លាញម្ទេសគ្រប់ប្រភេទ ឪឡឹក ព្រមទាំងប៉េងប៉ោះ និង ត្រប់ ធ្វើអោយរួញកើតជាជំងឺវីរុស ។

លក្ខណៈពិសេសនៃចៃទាំង ៣ នេះ គេអាចដឹងដោយសារសត្វស្រមោច កាលណាមានស្រមោចតោងឡើង គឺជាសញ្ញាដំបូងនូវវត្តមានរបស់សត្វចៃ មិនយូរដំណាំនឹងរួញ

**-មមង់បន្លែ** (Vegetable thrips) លក្ខណៈនៃសត្វមមង់ ឬទ្រីបនេះ គឺពេលថ្ងៃវាលាក់ខ្លួនក្នុងស្មៅ ក្នុងក្រហែង ឬដីដុំ ការបំផ្លាញច្រើនពេលយប់ វាចាប់ផ្តើមបំផ្លាញដំណាំចាប់ពីវគ្គកូនសំណាប រហូតដល់វគ្គបន្តពូជ គឺធ្វើអោយស្លឹកកូនដំណាំដូចជា ម្ទេស ប៉េងប៉ោះ ត្រប់ ត្រសក់ ឪឡឹក ត្រឡាច ល្ពៅ ស្ងួតគែមស្លឹកកូទីឡេដុង ឬ ស្លឹកកំណើត ។ ក្រោយពីការបំផ្លាញកូន ដំណាំលូតលាស់យឺត ប៉ុន្តែមិនធ្វើអោយលេចចេញសញ្ញារួញភ្លាមឡើយ មេរោគបានបញ្ចូលពីសត្វនេះទៅក្នុងកោសិកាដំណាំ ហើយមេរោគវិវត្តបន្តិចម្តងៗ រហូតដល់ដំណាំពេញវ័យទើបបង្ហាញនូវសញ្ញារួញ គឺជំងឺវីរុសដូចជា :

• ម្ទេស និង ប៉េងប៉ោះ ក្លាយជាជំងឺវីរុសងាប់កំពូល ហៅថា ស្ពតវីស (Spot wilt)





**មមង់បន្លែ** **វីរ៉ុសងាប់កំពូល ដោយសារមមង់ជញ្ជក់**

• ឪឡឹក ត្រឡាច ត្រសក់ ល្ពៅ កើតជាជំងឺ កន្ទុយដំរី ហៅថា រីងស្ពតវីរ៉ុស (Ring Spot Virus)

**វិធានការការពារ និងកំចាត់** :

ត្រូវធ្វើការជ្រើសរើសពូជអោយបានល្អ ពូជសុទ្ធ មានប្រភពត្រឹមត្រូវ មិនត្រូវដាំដំណាំដដែលលើផ្ទៃដីដដែល១ ប្រើពូជធន់ទ្រាំ ត្រូវពិនិត្យតាមដាននូវប្រភេទស្រមោច ដែលតោងឡើងដំណាំ ព្រោះងាយនឹងតាមរកប្រភេទចៃ នៅលើស្លឹក ឬដើមដំណាំ ។ កាត់យកស្លឹកដែលមានចៃចេញ ឬដកដើមដែលរួញចោល តាមដាននូវសត្វល្អិតដូចជា មមាចរុយស និងមម៉ង់ ពីវគ្គកូនសំណាប រហូតដល់វគ្គអោយផល ជាពិសេសទៀត គឺគេសាបកូនម្ទេស ត្រប់ ប៉េងប៉ោះ គ្របសំណាញ់អោយជិតការពារសត្វល្អិតទាំងនេះ ។ ក្នុងករណីការកាត់ស្លឹក ឬមែក ត្រូវប្រយ័ត្នមិនត្រូវយកឧបករណ៍ដែលកាត់ដើមរួញទៅកាត់ដើមល្អឡើយ បណ្តាលអោយជំងឺងាយឆ្លងបាន ជាពិសេសទៅទៀតការរក្សាទុកពូជ ត្រូវជ្រើសរើសដើមមេបាអោយបានត្រឹមត្រូវជាមុន ។ ចំពោះចៃវិញគេត្រូវព្រលែងសត្វ អង្រ្កង ស្រមោចទ្រក ឬ ស្រមោចខ្មៅច់ ដើម្បីអោយសត្វល្អិតទាំងនេះទៅស៊ីបំផ្លាញសត្វចៃ ។ គេអោយឈ្មោះប្រព័ន្ធការពារដំណាំនេះថា ការការពារតាមបែបជីវសាស្រ្ត (Biological control) ។

## ១.៣_ក្រុមជំងឺបង្កដោយបាក់តេរី

ដំណាំបន្លែតែងបង្កដោយជំងឺបាក់តេរី ជាច្រើនប្រភេទ ប៉ុន្តែការជួបខ្លាំងជាងគេគឺមានបាក់តេរី ៣ សំខាន់១ ហើយបំផ្លាញដំណាំផ្សេង១ពីគ្នា ក្នុងនោះមាន :

**-ជំងឺបាក់តេរីបង្កអោយរលាក ឬរលួយ** : ធ្វើអោយរលាកក្នុងក្តោបស្ពៃ បណ្តួលខាត់ណា ផ្កាខាត់ណា រលួយបាតមើមខ្ទឹម រលួយផ្លែម្ទេស រលួយផ្លែប៉េងប៉ោះ ហៅថា សស្វ៉ូត (Soft Rots) ។

ជំងឺនេះបណ្តាលមកពីអាកាសធាតុក្តៅខ្លាំង សំណើមលើសសេចក្តីត្រូវ បណ្តាលមកពីការផ្តល់ជីអាសូត (N) លើសសេចក្តីត្រូវការរួមជាមួយបរិយាកាសអាប់អួរ និងដីស្អុកនូវមេរោគស្រាប់ ជាពិសេសការដាំនៅរដូវភ្លៀងធ្លាក់ ហៅថា ដំណាំខុសរដូវ ។



**បាក់តេរីបង្កអោយរលួយក្តោប**

**-ជំងឺបាក់តេរីបង្កអោយប្រជ្រុយ ឬស្លោតគន្លួល:** ភាគច្រើនកើតលើដំណាំប៉េងប៉ោះ ធ្វើអោយផ្លែប៉េងប៉ោះមានស្នាមកន្ទួលប្រជ្រុយពណ៌ត្នោត ហើយបណ្តាលអោយស្ងួតដើម មែក ផ្កា និងស្លឹក មិនទទួលបានផលឡើយ ។ ករណីកើតលើដំណាំម្ទេស គឺស្អុយក្នុងផ្លែ កើតលើស្ពៃក្រញាញ់ និងស្ពៃជើងទា បណ្តាលអោយស្លឹក ធាងស្ពៃអុចៗពណ៌ត្នោត វាបង្កឡើងដោយកត្តាអាកាសធាតុ ដីស្តុកមេរោគ និងពូជមិនធន់ទ្រាំ ជាពិសេសនៅរដូវក្តៅ មានភ្លៀងធ្លាក់ជាលើកដំបូង ។



**ផ្លែប៉េងប៉ោះកើតជំងឺបាក់តេរីប្រជ្រុយ**

**-ជំងឺបាក់តេរីបង្កអោយស្រពោន ខាប់:** បាក់តេរីប្រភេទនេះ ច្រើនតែរស់នៅក្នុងទឹក ក្នុងដី ឬកំទិចកំទីស្លឹក មែក នៃដើមឈើងាប់ ហើយអណ្តែត ឬហូរនាំមកតំបន់ផ្សេងៗទៀត ជាពិសេសលើប្រភេទដី ដែលខ្សោះជីជាតិ ដែលកង្វះនូវសារធាតុសំខាន់ៗ ដីដូចជាបរិមាណអុកស៊ីសែននៃដីចុះទាប សារធាតុស្ងួតរបស់ដី មានភាគ រយទាបជាង ៣៥% (កំរិតល្អ ៤៥-៥០% ) ការបំលែងនូវសារធាតុចិញ្ចឹមរបស់ដីយឺត បង្កអោយកង្វះជីជាតិ ងាយទទួលរងនូវជំងឺនេះក្នុងនោះ គឺដំណាំ ខាត់ណាផ្កា ស្ពៃបូកគោ ឪឡឹក សាលាដក្តោប ម្ទេសហាវៃ ប៉េងប៉ោះ ។



**បាក់តេរីបង្កអោយដើមប៉េងប៉ោះស្រពោន**

**វិធានការការពារ និងកំចាត់ :**

បាក់តេរី ជាប្រភេទជំងឺមួយដែលពិបាក នឹងរកនូវវិធានការក្នុងការការពារ និង កំចាត់អោយមានប្រសិទ្ធិភាពមួយរយភាគរយ ប៉ុន្តែមានវិធីសាស្ត្រមួយចំនួន ដែលក្រុមអ្នកស្រាវជ្រាវបានយកមកណែនាំអោយប្រើដូចជា :

-ការសំលាប់មេរោគក្នុងដី មុននឹងសាប ឬបណ្តុះកូន គេត្រូវដុតដីថ្នាល ឬ ដីយកមកបណ្តុះជាមុន អោយមានកំដៅរហូតដល់ ២២ អង្សារសេ ។

-ការជ្រុំជ្រោយដីថ្នាល អោយបានច្រើនដង ហាលដីអោយយូរថ្ងៃ ធ្វើយ៉ាងណាអោយដីធូរ និងមានអុកស៊ីសែនគ្រប់គ្រាន់ ។

-របៀបកែប្រែបង្កើនដីជាតិដី ដោយប្រើជីលាមកសត្វ ឬកាកសំណល់ពីដំណាំស្រូវ ពីមួយ ឆ្នាំទៅមួយឆ្នាំ ដើម្បីអោយដីធូរ បង្កើនម៉ាស់សួតដល់ដី បង្កអោយបាក់តេរីមានប្រយោជន៍របស់ដីមានជីវិត និងសកម្មភាពល្អ ។

-ការធ្វើការឆ្លាស់មុខដំណាំបន្លែ និងស្រូវ ពីរដូវមួយទៅរដូវមួយ ជាវិធីល្អមួយព្រោះ បាក់តេរីទាំង៣ប្រភេទខាងលើនេះ មិនបង្ក និងវិវត្តបានដោយងាយជាមួយដំណាំស្រូវឡើយ ។

-ការប្រើប្រាស់ពូជធន : ត្រូវជ្រើសរើសពូជដំណាំអោយបានល្អ មុននឹងយកទៅដាំ ជាពិសេសគឺពូជដែលត្រូវបានណែនាំប្រើដោយក្រុមអ្នកស្រាវជ្រាវ ។

-ក្នុងវគ្គលូតលាស់នៃដំណាំត្រូវផ្អាកការស្រោចជី ផ្អាកការស្រោចទឹក ដកដើមកើតជំងឺចេញចំពោះកូនសំណាបវិញត្រូវធ្វើដំបូលគ្របការពារភ្លៀង និងកំដៅថ្ងៃព្រមទាំងទីកន្លែងបណ្តុះគួរមានពន្លឺថ្ងៃ និងខ្យល់អាកាសបរិបូរ ។

## ២-អំពីសត្វល្អិតចង្រៃសំខាន់ៗ

ដំណាំបន្លែតែងទទួលរងដោយក្រុមសត្វល្អិត ស៊ីបំផ្លាញជាច្រើនប្រភេទ ប៉ុន្តែក្នុងអត្ថបទនេះ យើងខ្ញុំសូមលើកយកតែសត្វល្អិតចង្រៃមួយចំនួនមកបកស្រាយ និងណែនាំអនុវត្ត ជាពិសេសគឺដំណាំសួនបន្លែគ្រួសារ ក្នុងនោះរួមមាន :

## ២.១-ដង្កូវយោលទោង (Diamond back moth)

សត្វល្អិតប្រភេទនេះជាសត្រូវយ៉ាងចំបង តែដំណាំអំបូរស្ពៃប៉ុណ្ណោះដូចជា ខាត់ណាដើម ខាត់ណាផ្កា ស្ពៃក្តោប និងស្ពៃឯទៀត ហើយការបំផ្លាញធ្វើអោយគ្រោះថ្នាក់ជាខ្លាំងក្នុងខែធ្នូ ដល់ខែមិនា នៅរដូវភ្លៀងធ្លាក់ និង រដូវត្រជាក់មិនធ្វើអោយគ្រោះថ្នាក់ឡើយ ។



**ដង្កូវយោលទោងស៊ីបំផ្លាញស្លឹកស្ពៃ**

## ២.២-សត្វទាគូរ (Flea beetle Leaf)

វាជាសត្វល្អិតដែលមានស្លាបរឹងអាចលោត និង ហើរបានក្នុងកំពស់ ១,៣០ ម វាជាសត្រូវនៃដំណាំអំបូរស្ពៃ ដូច ដង្កូវយោលទោងដែរ ប៉ុន្តែពុំមានរដូវបញ្ឈប់ការបំផ្លាញដូចដង្កូវយោលទោងឡើយ វាបន្តពូជ និងបំផ្លាញពេញមួយឆ្នាំ ។ មេរបស់ទាគូរស៊ីស្លឹកស្ពៃ ហើយពងដាក់ក្នុងដីថ្នាលស្ពៃ ពីព្រោះកូនញាស់របស់វាដំបូងស៊ីឫសស្ពៃជាអាហារ ដែលកសិករកម្ពុជាហៅថា កណ្តៀរដីស៊ីឫស ។



**មេទាគូរស៊ីបំផ្លាញស្លឹកដំណាំអំបូរស្ពៃ**

**វិធានការការពារ និង កំចាត់:** សត្វល្អិតទាំងពីរប្រភេទនេះ គេអនុវត្តវិធានការខ្លះដូចគ្នា ដូចជា :

**-វិគ្គកូនសំណាប** : ចាប់ពីសាបគ្រាប់ពូជភ្លាម គេត្រូវគ្របសំណាញ់ញឹកការពារ មិនអោយមេអំបៅនៃដង្កូវយោលទោង និងមេចំណាស់ទាគូរចូលទៅពងដាក់ក្នុងដីថ្នាល ឬពងដាក់លើស្លឹកស្ពៃ រហូតដល់ពេលដក កូនស្ពៃទៅដាំក្នុងចំការ ជាការល្អ ។

**-ការរៀបចំដី** ៖ ត្រូវដកយកគល់ស្ពៃចាស់ចេញពីចំការ មុននឹងភ្ជួរ ឬកាប់ដី ព្រោះឬសនឹងគល់ស្ពៃជាជំរកពងនៃទាគូរ បន្ទាប់មកមុននឹងសាបគ្រាប់ ឬស្ទូងកូន គេត្រូវដុតដីលើថ្នាលជាមុន ក្នុងគោលបំណងកំចាត់ពង និងកូនដង្កូវ ទាគូររួមទាំងកត្តាចង្រៃឯទៀត ។

**-ការប្រើទឹកស្លឹកប៉េងប៉ោះ** ៖ ត្រូវយកស្លឹកប៉េងប៉ោះទៅបុកអោយម៉ត់ ទំងន់ស្លឹក ២គ.ក្រ ហើយយកមកលាយទឹកចំនួន ១៥ លីត្រ ច្រោះអោយស្អាត ហើយលាយទឹកធម្មតាបន្ថែម ១០ លីត្រទៀត ដោយប្រើសាប៊ូលាងចានចំនួន ២ ស្លាបព្រាបាយ រួចបាញ់អោយជោគទៅលើស្លឹកស្ពៃនាពេលល្ងាច ដើម្បីការពារដង្កូវយោលទោង ។

**-ការព្យាយាមបាញ់ទឹកទៅលើសត្វទាគូរ**:គេត្រូវបាញ់ទឹកស្រោចលើស្លឹក នៅពេលថ្ងៃក្តៅស្ងួតដី ព្រោះពេលស្លឹកស្ពៃស្ងួត ដីស្ងួត ហើយក្តៅ មេរបស់វាតែងចូលស៊ីស្លឹកស្ពៃ ហើយបន្តពូជពងដាក់លើថ្នាលស្ពៃ ។ ពេលដីស្ងួតមានកំដៅ បើអាចធ្វើទៅបានគេគ្របដីដោយចំបើង ហើយស្ទូងកូនស្ពៃជាការល្អ ។ ប៉ុន្តែដង្កូវយោលទោង គេគួរតែបាញ់ទឹកពេលល្ងាចព្រលប់ៗ ដើម្បីដេញមេអំបៅមិនអោយបន្តពូជ និងពងដាក់ស្លឹកស្ពៃ ព្រោះមេអំបៅមិនចូលចិត្តភាពសើមឡើយ ។

## ២.៣.ដង្កូវស៊ីញ៉ៀ ឬ ដង្កូវផែនទី (Leaf miner)

ដង្កូវមានមាឌតូច វាញាស់ចេញពីរុយតូចៗ វាមិនមានរាងដូចផែនទី ឬស៊ីញ៉ៀឡើយ ។ តែស្នាមបំផ្លាញរបស់វាលើផ្ទៃស្លឹកមានរាងដូចគំនូសផែនទី ឬស៊ីញ៉ៀ ទើបកសិករអោយឈ្មោះថា ដង្កូវស៊ីញ៉ៀ ។ មេរុយតូចដូចមម៉ងផ្ទះបាយ វាពង បញ្ចូលទៅក្នុងបន្ទះស្លឹកដំណាំដូចជា ប៉េងប៉ោះ ត្រសក់ចំណារ សណ្តែកកួរ ត្រឡាច ននោងជ្រុង ននោងមូល ឪឡឹក ជាពិសេសចាប់ពីខែមករា ដល់ខែមេសា រហូតដល់ពេលមានភ្លៀងធ្លាក់ជោគជាំ ទើបដង្កូវនេះលែងស៊ីបំផ្លាញ ។ លក្ខណៈបំផ្លាញ គឺស៊ីពីស្លឹកក្រោមឡើងមកស្លឹកលើ ធ្វើអោយដំណាំស្ងួតស្លឹក លែងលូតលាស់ ។



**ស្នាមបំផ្លាញដោយដង្កូវស៊ីញ៉ៀ ឬ ផែនទី**

**វិធានការការពារ និងកំចាត់** ៖ ព្យាយាមពិនិត្យរករុយនេះ នៅលើផ្ទៃស្លឹកពេលស្លឹកដំណាំស្ងួត ពីម៉ោង ៨ ព្រឹកដល់ ម៉ោង ១៦ ល្ងាច ជាពេលដែលវាចេញបន្តពូជ បើមានមេរុយនេះច្រើនរយៈពេល ២ ទៅ ៣ ថ្ងៃ លេចចេញសញ្ញា

បំផ្លាញ គេត្រូវកាត់រំលោះស្លឹកក្រោម យកទៅដុតចោល ហើយព្យាយាមបាញ់ទឹកពេលថ្ងៃអោយស្លឹកដំណាំ សើម១ បន្ថយការបំផ្លាញបានច្រើន ។

## ២.៤-ដង្កូវស៊ីរូងកួរសណ្តែក

កសិករជាច្រើនក្នុងតំបន់អាស៊ី កំពុងជួបប្រទះនូវដង្កូវប្រភេទនេះ (Bean pod borer) គឺវាបំផ្លាញក្នុងវគ្គ សណ្តែកចេញផ្កា មេអំបៅពងដាក់លើកញ្ចុំផ្កា ពេលវាញាស់កូនដង្កូវ នឹងចោះចូលទៅស៊ីក្នុងផ្កា ធ្វើអោយផ្កាជ្រុះ ពេល បង្កើតបានជាកួរ វាចោះស៊ីក្នុងកួរ ។



**ដង្កូវស៊ីរូងកួរសណ្តែកគ្រប់ប្រភេទ**

**វិធានការការពារ និងកំចាត់** : ដំបូងត្រូវដាំសណ្តែកអោយរង្វើល ចំនួនដើមក្នុងគុម្ពមិនលើសពី ២ ឬ ៣ ដើមឡើយ ។ ពេលសណ្តែកមានស្លឹកទ្រុបទ្រុល ឬទងវែងរុំផុតចំណារ ត្រូវកាត់ទងនោះចេញព្រមជាមួយ ការកាត់រំលោះស្លឹកក្រោម១ចោលមួយភាគធ្វើអោយសណ្តែកអាចមានផ្កា និងកួរច្រើន ជាពិសេសទៀតត្រូវព្រលែង អង្រ្កង ក្នុងគុម្ពសណ្តែកអោយវាតាមចាប់ស៊ីដង្កូវជាអាហារ ។

## ២.៥-រុយទិចផ្លែ ឬហៅថា ស្រាំងអុច (Fruit fly)

រុយនេះមានស្លាបស្តើងក្បាលមានពណ៌លឿងទឹកមាស ហើយចេញបន្តពូជពេលស្លឹកដំណាំស្ងួត នៅក្នុងចំការ ម្រះ ត្រឡាច ឪឡឹក ត្រសក់ស្រូវ ត្រសក់ចំណារ ល្ពៅ ននោងជ្រុង ម្ទេស គឺវាទិចបញ្ចូលពងទៅក្នុងក្តិបតូច១ នៃផ្លែដំណាំទាំងនោះ ។ ដោយឡែកផ្លែម្ទេសពេលផ្លែចាស់ជិតទុំ ក្រោយពីមេរុយទិចបញ្ចូលពងទៅក្នុង ផ្លែមានស្នាម ចេញជ័រថ្មី១ ក្រោយមកពងនោះញាស់ជាដង្កូវស៊ីក្នុងផ្លែធ្វើអោយផ្លែដំណាំស្អុយលែងទទួលផល ។

**វិធានការការពារ និងកំចាត់** :

ក្នុងវគ្គដំណាំចេញផ្កា និងមានក្តិប គេត្រូវព្យាយាមបាញ់ទឹកអោយសើមស្លឹកក្នុងអំឡុងម៉ោង ១១ព្រឹក ដល់ម៉ោង ៣ល្ងាច ដើម្បីរំខានដល់ការជួបគ្នារវាងសត្វញី និងឈ្មោល ។ម្យ៉ាងទៀតពេលត្រឡាចផ្ទើរ និង ននោង មានក្តិបផ្កា ព្យាយាមបំពួកភ្នក់ភ្លើងអោយមានផ្សែងហុយ១ ដើម្បីបណ្តេញវាចេញពីចំការក្នុងម៉ោងដូចគ្នា ។ ចំពោះផ្លែ ម្រះ គេត្រូវព្យាយាមយកក្រណាត់ ឬកញ្ចប់ក្រដាស ទៅស្រោបច្រកក្តិបដែលមានផ្កាខាងចុងស្រពោន ឬជ្រុះថ្មី១ ចាប់ពីម៉ោង ៨ ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់ ជាការល្អ ។ការច្រក ឬរុំក្តិបជារៀងរាល់ព្រឹក ម្រះទទួលបានផ្លែច្រើន ។

## V-ការបង្កើនជីជាតិដី សម្រាប់ដំណាំបន្លែ

បន្លែជាប្រភេទដំណាំដែលមានអាយុកាលលូតលាស់ខ្លី ដូចនេះវាត្រូវការដីដែលមានជីជាតិគ្រប់គ្រាន់ជាបង្គួរ ដើម្បីការដុះលូតលាស់ និងបន្តពូជ ។ ដូច្នេះដើម្បីការដុះលូតលាស់ និងប្រសិទ្ធិភាពនៃការថែទាំជោគជ័យល្អ គេត្រូវមានវិធីសាស្រ្ត ក្នុងការគ្រប់គ្រង និងប្រើប្រាស់ជីជាតិបន្ថែមដល់ដីដូចតទៅ :

### ១-ប្រយោជន៍នៃជីកុំប៉ុស្តិ៍

ជីកុំប៉ុស្តិ៍ដែលប្រជាកសិករតែងនិយមប្រើប្រាស់ សម្រាប់ដំណាំបន្លែ មានពីរប្រភេទក្នុងនោះទំរង់ជាជីស្ងួត និងជីរាវ ។ អត្ថប្រយោជន៍នៃជីទាំងពីរនេះ ផ្តល់ទៅអោយដី និងដំណាំមានលក្ខណៈផ្សេងគ្នា គឺ :

#### ១-១-ប្រភេទជីកុំប៉ុស្តិ៍ស្ងួត

កុំប៉ុស្តិ៍ស្ងួតដែលផ្សំពីវត្ថុធាតុជាច្រើនដូចជា កាកសំណល់ដំណាំ មែក និងស្លឹកឈើ កំបោរស កាកសំណល់ផលិតផលបន្លែផ្សេងៗពីផ្ទះបាយ រួមជាមួយជីលាមកសត្វ ផេះអង្កាម សំដីស្រូវ និងចំបើង វាសំបូរទៅដោយម៉ាស់ស្ងួត (អំពុក) ។ ជីនេះគេផ្សំឡើងមានរយៈពេលពិតប្រាកដចាប់ពី ៣ ទៅ ៦ ខែ ដើម្បីអោយវត្ថុធាតុទាំងនោះវិវឌ្ឍន៍ពីភាពស្រស់រឹងទៅជាសារធាតុសរីរាង្គមួយ ក្រោមអំពើនៃកំដៅ សំណើម និងអុកស៊ីសែន ។ របៀបនៃការប្រើជីកុំប៉ុស្តិ៍ គេតែងយកជីទៅបាចលើរងដំណាំតាមលទ្ធភាពដែលមាន ប៉ុន្តែបរិមាណដ៏ប្រសើរពី ២ គ.ក្រ លើផ្ទៃដី ១ម៉ែត្រការ៉េ វាបានផ្តល់អោយការដុះលូតលាស់ និងការស្រូបយករបស់ដំណាំបានលឿន ហើយគ្រប់គ្រាន់ជាបង្គួរ ។ មួយផ្សេងទៀត គេអាចយកទៅដាក់តាមរណ្តៅមុននឹងដាំដុះដំណាំ តែគេក៏ត្រូវគិតអំពីចំនួនដូចខាងលើដែរ ។ ប្រភេទដីដែលទាមទារការប្រើជីកុំប៉ុស្តិ៍ គឺ ដីល្បាយខ្សាច់នៃខ្ពង់រាបមួយចំនួន ព្រោះដីនោះមានការហូរច្រោះនាំយក ទៅជាមួយនូវវត្ថុធាតុសរីរាង្គ រួមទាំងជីជាតិជាច្រើនចុះទៅតំបន់ទំនាប ជាមូលហេតុធ្វើអោយដីនោះបាត់បង់នូវម៉ាស់ស្ងួត ដីបន្ទល់ទុកនូវ ភាគរយគ្រាប់ខ្សាច់យ៉ាងច្រើន ពិបាកក្នុងការរក្សាទឹក ងាយបាត់បង់សំណើម ព្រមទាំងប្រែប្រួលកំដៅយ៉ាងលឿន ។

ដោយឡែកលើប្រភេទដីឥដ្ឋវិញ វាពុំមានការហូរច្រោះខ្លាំងឡើយ ប៉ុន្តែដីនេះត្រូវបានប្រើប្រាស់ជាយូរឆ្នាំ វត្ថុធាតុសរីរាង្គបាត់បង់ពីដីយ៉ាងច្រើន ដោយពុំមានលទ្ធភាពជំនួសអោយគ្រប់គ្រាន់ ពីកាកសំណល់ដំណាំ ។ ដូចនេះវាបង្កអោយកំហាប់នៃធាតុស្អិតកើនឡើង ធ្វើអោយដីហាប់ណែន គ្មានខ្យល់អុកស៊ីសែន ធ្វើអោយដីនោះពុល ជាពិសេសប្រភពកំណើតដែកអុកស៊ីដ ដែលគេហៅថា ថ្មបាយក្រៀម ។ ការប្រើជីកុំប៉ុស្តិ៍ លើដីប្រភេទនេះមិនមែនមួយឬពីររដូវធ្វើអោយដីនោះមានទំរង់ស្មើសាច់ និងបរិមាណជីជាតិគ្រប់គ្រាន់តាមតំរូវការរបស់ដំណាំនោះឡើយ គេត្រូវព្យាយាមប្រើអោយបានច្រើនឆ្នាំបន្តបន្ទាប់គ្នា ។ ម្យ៉ាងទៀតរបៀបប្រើគឺ ដំបូងគេ បាចលើរង ឬដាក់តាមរណ្តៅដាំជាមធ្យម ២គ.ក្រ ក្នុង១ម៉ែត្រការ៉េ ។ ដល់ពេលវគ្គលូតលាស់នៃដំណាំ គេដាក់បន្ថែមម្តងទៀត ជាការប្រសើរ ចំនួន

១ ទៅ ២គ.ក្រ ក្នុង១ម៉ែត្រការ៉េ ។ ការប្រើរបៀបនេះដីឥដ្ឋនោះវាបានបន្ថយនូវភាពល្អិត ជាបណ្តើរៗ ធ្វើអោយទឹកមានលទ្ធភាពជ្រាបចុះបានល្អ រក្សាសំណើមសមស្របដល់ដំណាំ ជួយបង្កើនបរិមាណអុកស៊ីសែនដល់ដី ជាលទ្ធភាពបង្កអោយបាក់តេរីនៃដីមានជីវិតល្អឡើងវិញ ។

## ១.២. ប្រភេទជីកុំប៉ុស្តិ៍រាវ

កុំប៉ុស្តិ៍រាវ គឺជាជីធម្មជាតិ ដែលអោយឈ្មោះថាជា ជីសរីរាង្គដែរ ប៉ុន្តែបានមកពីការត្រាំនូវកាកសំណល់មួយចំនួន ដែលលាយជាមួយជីលាមកសត្វ គ្រប់ប្រភេទ រួមជាមួយ ដើមរុក្ខជាតិមួយចំនួន ក្នុងនោះមានដើមទន្ទ្រេងខែត ដើមចង្រ្កងស្វា ដើមសណ្តែកដី ដើមសណ្តែកបាយ ដើមដង្ហិត ដើមសណ្តែកអង្គុយ ។ គេត្រូវកាត់ចិញ្រ្ចាំដើមទាំងនោះអោយល្អិតៗខ្លីៗ យកវាទៅដាក់បាតពាងអោយបានច្រើន បន្ទាប់មកយកជីលាមកគោ លាមកមាន់ ទា ជ្រូក គោ ក្របី មកដាក់ពីលើលាយជាមួយកាកសណ្តែក គ្រាប់សណ្តែកសៀង ចុងអង្ករ ត្រូវស្ងោរអោយរលួយបន្តិចៗ ទៅដាក់បន្ថែម ហើយចាក់ទឹកត្រាំទុកអោយរលួយរយៈពេល ១ ទៅ ២ ខែមុន ។ ជាពិសេសទៅទៀតបើអាចសន្សំបាន គេត្រូវប្រមូលយកទឹកនោមសត្វ មនុស្សមកចាក់ត្រាំជាមួយ ធ្វើអោយជីកុំប៉ុស្តិ៍នោះរិតតែមានគុណភាពល្អ ។

របៀបនៃការប្រើជីកុំប៉ុស្តិ៍រាវគឺ សម្រាប់ស្រោចបំប៉ន ក្រោយពីដំណាំដុះលូតលាស់ ។ ក្នុងវគ្គកូនសំណាប គេប្រើកំរិតសូលុយស្យុងទាបគឺ ១,៥/២០ (ទឹកជី ១,៥លីត្រ លាយទឹកធម្មតា ២០ លីត្រ ) តែក្នុងវគ្គពេញលេញរបស់ដំណាំ គឺ ២/២០ (២ លីត្រទឹកជី លាយទឹក ២០ លីត្រ) ស្រោច ឬបាញ់ទៅលើស្លឹករយៈពេល ៤ ទៅ ៥ថ្ងៃម្តង ។

## ២. ប្រយោជន៍នៃជីលាមកសត្វ

លាមកសត្វដែលគេតែងនិយមប្រើប្រាស់ជាងគេគឺ គោ ក្របី ជ្រូក និងមាន់ ។ វិធីសាស្ត្រនៃការប្រើប្រាស់គឺធ្វើឡើងទៅតាមប្រភេទនៃជីនីមួយៗដូចជា :

## ២.១. លាមកគោ និងក្របី

គេត្រូវសន្សំទុកនូវលាមកសត្វទាំងពីប្រភេទនេះ អោយយូរខែ យ៉ាងតិចបំផុតមានរយៈពេលពី ៨ ខែទៅមួយឆ្នាំ សម្រាប់បាចលើរងដំណាំ ឬដាក់តាមចន្លោះគុម្ពនៃដំណាំ តែបើលាមកនោះមិនទាន់ពុកល្អ គេត្រូវប្រើតាមវិធីបាចទៅលើដី ហើយភ្ជួរលប់ពេលរៀបចំដីលើកដំបូង កាលណាយកជីមិនពុកទៅដាក់ក្នុងវគ្គដាំដុះ ឬបំប៉នធ្វើអោយមានការប៉ះពាល់ដល់កូនដំណាំដោយសារកំដៅនៃអាមូនីញ៉ាក់ ($NH_4$) ។ មានវិធីមួយដែលគេឆ្អៃលាមកគោក្រៀមថ្មីៗអោយឆាប់បានប្រើគឺ : ទុកលាមកគោ ឬក្របីនៅក្នុងទ្រុង អោយវាដើរជាន់ទៅជាបំណែកតូចៗ ហើយស្ងួតបន្ទាប់មកប្រមូលយកលាមកនោះមកលាយជាមួយកំបោរស ហើយរក្សាទុកតាមរូបមន្ត ១០០គ.ក្រ ជីស្ងួត លាយកំបោរ ៣គ.ក្រ ហើយស្រោចទឹកមួយធុង បន្ទាប់មកច្រកទុកក្នុងការ៉ុងចងអោយជាប់ គរពីលើគ្នា ដាក់ក្រោមម្លប់ឈើ រយៈពេល ៤ ទៅ ៥ ថ្ងៃ ផ្សើមទឹកម្តង រហូតដល់ជីនោះអស់កំដៅទើបលែងស្រោចទឹក ហើយរក្សាទុកបន្តរហូតដល់មានរយៈពេល ៣ ខែ ទើបអនុញ្ញាតអោយយកទៅប្រើលើដំណាំបាន ។

### ២.២.អំពីលាមកមាន់

ត្រូវប្រមូលយកលាមកមាន់មកដាក់ហាលក្រោមម្លប់ឈើ ដោយលាយជាមួយអង្កាម ឬផេះអង្កាម រហូតដល់វាស្ងួតក្រោយមកយកទឹកទៅស្រោចអោយសើម១បន្តិច១ ប្រមូលច្រកការ៉ុងចងអោយជាប់គរទុករយៈពេល ២៥ ទៅ ៣០ ថ្ងៃ ទើបយកមកប្រើបាន ប៉ុន្តែមិនត្រូវដាក់តាមគុម្ពដំណាំឡើយ គេប្រើបាចលើថ្នាលហើយជ្រុំដីលប់ជាកាល្អ ។

### ២.៣.អំពីលាមកជ្រូក

គេត្រូវប្រមូលយកជីលាមកជ្រូកចេញពីទ្រុង ហើយដាក់ពង្រាយក្រោមម្លប់ឈើ អោយវាស្ងួតរយៈពេល ១០ ទៅ ១៥ ថ្ងៃ បន្ទាប់មកយកជី ទំងន់ ១០០ គ.ក្រ ទៅលាយជាមួយកំបោរស ២ គ.ក្រ ហើយស្រោចទឹកអោយសើម១ ពូនគរជីនោះជាពំនូត១ គ្របនឹងសំពត់កៅស៊ូអោយជិត ទុករយៈពេល ១ ទៅ ២ អាទិត្យទើបយកមកប្រើបាន ដោយបាចទៅលើដី ហើយជ្រុំលប់ទៅក្នុងថ្នាលដំណាំមុនដាំ ។

## ៣.ប្រយោជន៍នៃស្រកីដូង

ស្រកីដូងទុំជាសារធាតុមួយ ស្ងួតហើយគ្មានឥទ្ធិពល ឬផលប៉ះពាល់ណាមួយដល់ការដុះលូតលាស់របស់ដំណាំ។ កាលណាគេយកវាទៅលាយជាមួយដី សម្រាប់បណ្តុះ ឬផ្សាំកូនដំណាំ វាធ្វើអោយដីធូរ ស្រូបយកជាតិទឹកបានល្អ កាត់បន្ថយការជ្រាបទឹក ឬការហួតហែងរបស់ដីបានយ៉ាងច្រើន ។ លទ្ធផលពិសោធន៍បានបង្ហាញថា ទំងន់ស្ងួតរបស់ស្រកីដូង ១០០០ក្រាម អាចស្រូបយកជាតិទឹកបានទំងន់ ២៧០ក្រាម លក្ខខណ្ឌបែបនេះទើបធ្វើអោយវាមានលទ្ធភាពផ្តល់អោយការដុះលូតលាស់បានល្អ ។ វិធីសាស្ត្រនៃការប្រើស្រកីដូងទុំមានពីរយ៉ាងគឺ :

### ៣.១.ការលាយសម្រាប់បណ្តុះកូនបន្លែ

គេត្រូវយកស្រកីដូងទុំទៅត្រាំទឹក ១ ទៅ ២ យប់ ហើយយកមកវាយជំរុះយកលំអងកំទិចម៉ត់១ ងាយស្រួលលាយជាមួយវត្ថុធាតុឯទៀត ។ របៀបនៃការលាយគឺ ស្រកីដូងចំនួន ២ ធុង ត្រូវលាយជាមួយជីកុំប៉ុស្តិ៍ ១ ធុង ដីមានជីជាតិ ១ ធុង ផេះអង្កាម ១ ធុង និងអង្កាម ១ ធុង បន្ទាប់មកយកទៅដុតសំលាប់មេរោគរយៈពេល ២ ទៅ ៣ ម៉ោង ( ធុងលាយប៉ុនគ្នា) ។ ការធ្វើរបៀបនេះ កូនបន្លែដុះលូតលាស់លឿនហើយមិនរលួយ ។

### ៣.២.ការលាយសម្រាប់បណ្តុះកូនឈើហូបផ្លែ

គេត្រូវយកស្រកីដូងទុំដូចគ្នាដែរទៅដាក់ត្រាំទឹក ១ ទៅ ២ យប់ បន្ទាប់មកយកមកជំអោយទន់១ កាត់ចិញ្ច្រាំអោយខ្ចី១ ជាបំណែកតូច១ល្អិត១ ។ របៀបនៃការលាយគឺ កំទិចស្រកីដូង ២ធុង ជីកុំប៉ុស្តិ៍ ២ ធុង ផេះអង្កាម ១ធុង និងដីមានជីជាតិ ១ ធុង លាយបញ្ចូលគ្នា ហើយយកទៅច្រកក្នុងថង់បណ្តុះជាការស្រេច ( ធុងលាយប៉ុនគ្នា) ។

## ៤.ការដាំផ្លាស់មុខដំណាំ

អ្វីទៅជាការផ្លាស់មុខដំណាំ ? ហើយការដាំផ្លាស់មុខរបៀបនេះមានផលប្រយោជន៍ដូចម្តេច ? អត្ថបទនេះសូមធ្វើការណែនាំ និងបង្ហាញនូវលទ្ធផលការងារជាច្រើន ដែលទាក់ទងទៅនឹងការដាំផ្លាស់មុខដំណាំ ។ ជាធម្មតាផ្ទៃដី

កសិកម្ម ជារៀងរាល់ឆ្នាំកសិករយើងតែងតែធ្វើការដាំដុះដំណាំ ហើយទាញយកផលពីដំណាំ ។ ការផ្តល់ផលដំណាំ ទៅកសិករ គឺជាភាពបាត់បង់នូវកត្តាជីជាតិដី ជាបណ្តើរៗរៀងរាល់ឆ្នាំផងដែរ ជាក់ស្តែងប្រជាកសិករកម្ពុជា យើងដែលលោកពុំបានយល់ច្បាស់ពីផលប៉ះពាល់ នៃការដាំដំណាំដដែលៗ លើផ្ទៃដីតែមួយ ក្នុងរដូវបន្ទាប់គ្នា ដូចជាត្រសក់ ហើយគាត់ដាំត្រសក់ទៀត នៅរដូវទី ២ នេះភាគច្រើនកសិករបាត់បង់នូវប្រាក់ចំណូលយ៉ាងខ្លាំង ។ ដូចគ្នានេះដែរលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញនូវបរិមាណសារធាតុចិញ្ចឹម ដែលដំណាំស្រូបយកពីដីក្នុងមួយរដូវផលិតកម្ម ផ្តល់ទៅអោយទិន្នផល មានបរិមាណយ៉ាងច្រើនដូចក្នុងតារាងទី ៧ ។

**តារាងទី ៧ : ការស្រូបយកសារធាតុសំខាន់ៗពីដីផ្តល់អោយដំណាំ**

| **ដំណាំ** | **ទិន្នផល ត/ហត** | **ការស្រូបយកសារធាតុពីដី Kg-ha** | | | | |
|---|---|---|---|---|---|---|
| | | **N** | **$P_2O_5$** | **$K_2O$** | **CaO** | **MgO** |
| **១-ដំណាំយកស្លឹក** | | | | | | |
| -សាលាដក្តោប | ២១ | ១៣១ | ៣៤ | ២២៦ | ៤១ | ៤២ |
| -សាលាដស្លឹក | ១៨ | ៦៨ | ២១ | ១៣០ | ២០ | ៨ |
| -ស្ពៃក្តោប | ២៩ | ១៦៩ | ៤៥ | ១៤៨ | ២៩ | ៧ |
| -ស្ពៃខៀវចង្កឹះ | ២៩ | ១២១ | ៣២ | ១០៦ | ២១ | ៥ |
| **២-បន្លែយកផ្លែ** | | | | | | |
| -ត្រប់គ្រប់ប្រភេទ | ១០ | ២០៧ | ៤៦ | ៣៤០ | ១២ | ៤ |
| -អូក្រា | ២០ | ៧៩ | ៣២ | ៨៩ | ២៩ | ១៥ |
| -ប៉េងប៉ោះ | ២៤ | ១៧៧ | ៤៦ | ៣១៩ | ១២៩ | ៤៣ |
| -ម្ទេសគ្រប់ប្រភេទ | ២១ | ៧០ | ១៦ | ៩២ | ៦៧ | ១៨ |
| -ត្រសក់ | ២០ | ៣៩ | ២៧ | ៧០ | ៣៥ | ១០ |
| -ឪឡឹក | ១៥ | ៥៦ | ១៦ | ១០០ | ៩៨ | ២៥ |
| -សណ្តែកបារាំង | ១៣ | ១២៩ | ២១ | ៦៨ | ៥០ | ១៧ |
| -ពោត | ២០ | ២០៨ | ៦០ | ២២៨ | ៤២ | ២៥ |
| **៣-ដំណាំមើម** | | | | | | |
| -ការ៉ុត | ៤៣ | ១២៦ | ៧១ | ១៧៥ | ២២៤ | ២០ |
| -ខ្ទឹមបារាំង | ៤១ | ១០២ | ៤១ | ១១២ | ២៩ | ១៧ |
| -ឆៃថាវ | ១៩ | ២៧៦ | ៨៩ | ៣៨៩ | ១៤៧ | ៧៦ |

## ៤.១.វិធីសាស្ត្រនៃការដាំឆ្លាស់មុខដំណាំ

របៀបនៃការដាំឆ្លាស់មុខដំណាំតំបូង គេត្រូវណែនាំអោយស្គាល់នូវប្រភេទដំណាំនីមួយៗ ដែលស្ថិតនៅក្នុងក្រុម ឬអំបូរតែមួយ ដូចជា ដំណាំអំបូរត្រសក់ ដំណាំអំបូរម្ទេស ត្រប់ ប៉េងប៉ោះ និង អូក្រា ដំណាំអំបូរសណ្តែក ដំណាំអំបូរស្ពៃ ដំណាំអំបូរជីរ ។ កាលណាមិនបានយល់ដឹងនូវប្រភេទដំណាំទាំងនេះ ការដាំឆ្លាស់អាចបណ្តាលអោយមានការខុសឆ្គង ។ ដំណាំនីមួយៗមានអាយុកាលលូតលាស់របស់វាខុសគ្នា ហើយតំរូវការជីជាតិពីដីក៏ខុសគ្នាដែរ ដំណាំខ្លះស្រូបយកពីដី តែដំណាំខ្លះទៀតវាបានផ្តល់ជីជាតិដល់ដីវិញដែរ ។ កំហុសឆ្គងដែលបណ្តាលមកពីការដាំដំណាំអំបូរតែមួយ ឬប្រភេទដដែលៗ លើផ្ទៃដីដដែលក្នុងរដូវផ្សេងៗ ជាមូលហេតុបង្កឡើងដូចជា : បាត់បង់ជីជាតិដីច្រើន បង្កអោយកត្តាចង្រៃដូចជា សត្វល្អិត និង ជំងឺកាន់តែច្រើនឡើងៗ បណ្តាលអោយផលដំណាំកាន់តែចុះទាបទៅៗ ។ ប្រព័ន្ធនៃការឆ្លាស់មានដូចតទៅ :

-ដំណាំស្រូវរដូវទី ១ —រដូវទី ២ ជាបន្លែគ្រប់ប្រភេទបាន

-ដំណាំអំបូរត្រសក់ រដូវទី ១ រដូវទី ២ ដាំស្រូវ ឬ អំបូរសណ្តែក

-ដំណាំអំបូរសណ្តែក រដូវទី ១ រដូវទី ២ ដាំបន្លែគ្រប់ប្រភេទ

-ដំណាំអំបូរប៉េងប៉ោះ រដូវទី ១ រដូវទី ២ ដាំដំណាំអំបូរត្រសក់

-ដំណាំអំបូរពោត រដូវទី ១ រដូវទី ២ ដាំបន្លែទូទៅ

-ដំណាំអំបូរស្ពៃ រដូវទី ១ រដូវទី ២ ដាំដំណាំអំបូរសណ្តែក

បំរាម : គេអាចធ្វើការហាមឃាត់ លើប្រភេទដំណាំមួយចំនួនដូចជា :

-មិនអាចដាំម្ទេស ប៉េងប៉ោះ ត្រប់ ឬ អូក្រា ទោះជាមួយណាមុនក៏ដោយ ។

-មិនអាចដាំត្រសក់ ននោង ល្ពៅ ត្រឡាច ម្រះ ឪឡឹក ទោះជាមួយណាមុនក៏ដោយ ។

-មិនអាចដាំសណ្តែកកួរ ហើយរដូវបន្ទាប់ដាំសណ្តែកកួរទៀតឡើយ តែគេអាចដាំសណ្តែកផ្សេងៗទៀតបាន ដូចជា សណ្តែក បាយ សណ្តែកបារាំង ។ល។

## ៤.២.វិធីសាស្ត្រដាំដំណាំចំរុះ

ដំណាំចំរុះ គឺជាការដាំដំណាំពីរ ឬបីប្រភេទ ក្នុងវគ្គដំណាលគ្នា ឬមុនក្រោយគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ដើម្បីអោយដំណាំចំរុះទទួលបានលទ្ធផលល្អ គឺគេត្រូវគិតអំពីលក្ខណៈនៃការដុះលូតលាស់របស់ដំណាំដូចជា :

**-ដំណាំល្ហុង** : កាលណាគេដាំល្ហុងនៅជុំវិញសួន ឬជាចំការធំៗក៏ដោយ ក្រោយពីការដាំល្ហុងបានរយៈពេលមួយខែ គេត្រូវដាំប្រភេទម្ទេសគុយទាវតាមចន្លោះជួរល្ហុងបាន ។ ក្រៅពីនោះ គេអាចយកខ្ញី ទៅដាំតាមចន្លោះជួរល្ហុងក៏បាន

**-ដំណាំពោត** : នៅក្រោមដើមពោត គេអាចដាំត្រសក់ស្រូវ ដាំល្ពៅ ដាំត្រឡាចបាន គឺដាំក្នុងវគ្គដំណាលគ្នា

**-ដំណាំត្រសក់ចំណារ និង ប៉េងប៉ោះ :** ក្រោយពីត្រសក់ប្រមូលផលលើកដំបូង គេអាចដាំពោត តាមគែមរងដំណាំទាំងពីរនេះ ក្រោយពីបញ្ចប់ការប្រមូលផល ត្រូវដកដើមរើចំណារចេញ ពោតនឹងលូតលាស់តាមក្រោយ ។

**-ដំណាំជីរណា** : គេអាចដាំពីក្រោមធ្នើរននោងជ្រុង និង ននោងមូល ឬធ្នើរត្រឡាចបាន ក្រោយពីដំណាំនោះវារតោងលើទ្រើង ឬធ្នើរមានម្លប់ខ្លះៗ ។

**-ដំណាំស្ពៃ និងដំណាំពោត** : ក្រោយពីស្ទូងស្ពៃបានមួយសប្តាហ៍ គេអាចដាំពោត ចំកណ្តាលរងស្ពៃ អោយរង្វើលៗ ដើម្បីអោយម្លប់ស្លឹកពោតគ្របការពារស្ពៃនៅរដូវក្តៅ ក្រោយពីការកាត់ស្ពៃ គេត្រូវថែទាំពោតតាមក្រោយ ។

## ៥- ការវិភាគសេដ្ឋកិច្ច :

ការកំណត់ និងវិភាគសេដ្ឋកិច្ចលើទំហំសួន ១០ម × ១០ម = ១០០ម²

**ក-ធនធានកសិករផ្ទាល់ : ការសិក្សា និងវិភាគសេដ្ឋកិច្ចលើការចំណាយក្នុងដំណើរការសួនបន្លែគ្រួសារមួយ ហើយសំភារៈដែលកសិករចូលរួមមានដោយធ្វើតម្លៃប៉ាន់ស្មាន គឺ :**

| | | |
|---|---|---|
| - បង្គោលរបងប្រវែង ១,៣០ម | ចំនួន ៤០ | តម្លៃសរុប ៤៨០០០៛ |
| - របាររបងឫស្សី | ចំនួន ៦ ដើម | តម្លៃសរុប ២១០០០៛ |
| - ដែកគោលដំរបារ | ចំនួន ០,៤ គីឡូក្រាម | តម្លៃសរុប ៥៥០០៛ |
| - ជីកំប៉ុស្តិ៍ លាមកសត្វ | ចំនួន ៣០០គីឡូក្រាម | តម្លៃសរុប ២០០០០៛ |
| - ចំបើងស្ងួត | ចំនួន ១០០ គីឡូក្រាម | តម្លៃសរុប ៣០០០៛ |
| - ចំណារមែកឈើកូនឫស្សី ផេះអង្កាម | | តម្លៃសរុប ១០០០០៛ |
| | សរុប (ក) ............................... | ១០៧៥០០៛ |

**ខ-បដិភាគរបស់ម្ចាស់គំរោង : តម្លៃលើសំភារៈមួយចំនួនដែលកសិករពិបាកក្នុងការរកទិញ និងដឹកជញ្ជូនដូចជា:**

| | |
|---|---|
| - ពាងត្រាំជីកុំប៉ុស្តិ៍ទឹកចំណុះ ១៥០លីត្រ | តម្លៃសរុប ៣០០០០៛ |
| - គ្រាប់ពូជដំណាំចំនួន ១៦ ឬ ១៨ ប្រភេទ | តម្លៃសរុប ២០០០០៛ |
| - ប៉ោតស្រោចទឹកចំនួន ១គូ | តម្លៃសរុប ២៥០០០៛ |
| - ឧបករណ៍បណ្តុះកូនដំណាំ ៣ សម្រាប់ | តម្លៃសរុប ២១០០០៛ |
| សរុប(ខ) ........................ | ៩៦០០០៛ |

**សរុប(ក)+(ខ) រួមមាន ២០៣,៥០០៛**

**គ-ការចំណូលដោយប្រយោល ៈ**

ចំណូលប្រយោលនេះ គឺគិតអំពីទម្ងន់នៃផលិតផលបន្លែ ។ បន្លែដែលគាត់ប្រមូលបានពីសួនទំហំ ១០ម × ១០ម = ១០០ម$^{២}$ លើដំណាំសំខាន់ ប្រសិនបើគាត់មិនបានដាំ ហើយត្រូវចំណាយទិញបន្លែមកបរិភោគក្នុងគ្រួសាររបស់គាត់មួយរយៈពេលដំណាំ មានដូចខាងក្រោមៈ

- សណ្តែកកួរ ៥ម$^{២}$ អោយផលមធ្យម ៧ គីឡូក្រាម តម្លៃសរុប ៩១០០៛
- ត្រសក់ចំណារ ៥ម$^{២}$ អោយផល ៨ គីឡូក្រាម តម្លៃសរុប ៨០០០៛
- ដំណាំម្រះ ៥ម$^{២}$ អោយផលផ្លែស្រស់ ៦ គីឡូក្រាម តម្លៃសរុប ១០២០០៛
- ត្រួយម្រះ ៥ម$^{២}$ អោយទងខ្ចីៗ ១៥០ ដុំ តម្លៃសរុប ៤៥០០០៛
- ដំណាំម្ទេស ៥ម$^{២}$ អោយទំងន់ផ្លែ ២៥ គីឡូក្រាម តម្លៃសរុប ១២៥០០៛
- ត្រួយម្ទេស ៥ម$^{២}$ អោយស្លឹកត្រួយខ្ចីៗ ៣០ដុំ តម្លៃសរុប ៦០០០៛
- ននោងជ្រុង ៥ម$^{២}$ អោយចំនួនផ្លែសរុប ៦៥ ផ្លែ តម្លៃសរុប ១៦២៥០៛
- ននោងមូល ៥ម$^{២}$ អោយចំនួនផ្លែសរុប ៤៥ ផ្លែ តម្លៃសរុប ១៣៥០០៛
- ត្រួយម្ទុំ ៥ម$^{២}$ អោយត្រួយខ្ចីៗសរុប ១៥០ដុំ តម្លៃសរុប ៣០០០០៛
- ត្រួយងប់ ៥ម$^{២}$ អោយត្រួយខ្ចីៗសរុប ៨០ដុំ តម្លៃសរុប ១៤៤០០៛
- ត្រួយស្អំ ៥ម$^{២}$ អោយត្រួយខ្ចីៗសរុប ៥០ដុំ តម្លៃសរុប ៧៥០០៛
- ប៉េងប៉ោះ ៥ម$^{២}$ អោយទំងន់ជាផ្លែសរុប ៦,៥គីឡូក្រាម តម្លៃសរុប ១១៧០០៛
- ត្រួយផ្ទី ៥០ម$^{២}$ អោយត្រួយខ្ចីៗសរុប ៥០ ដុំ តម្លៃសរុប ១០០០០៛
- ស្ពៃចង្កឹះ ៥ម$^{២}$ អោយទំងន់ស្រស់សរុប ៥,៥ គីឡូក្រាម តម្លៃសរុប ៨២៥០៛
- ស្ពៃខៀវ ៥ម$^{២}$ អោយទំងន់ស្រស់សរុប ៥,៥ គីឡូក្រាម តម្លៃសរុប ៨២៥០៛
- ត្រកួនគោក ៥ម$^{២}$ អោយទំងន់សរុប ១៥ គីឡូក្រាម តម្លៃសរុប ១២០០៛
- ដំឡូង ៥ម$^{២}$ អោយទងខ្ចីៗសរុប ៨០ ដុំ តម្លៃសរុប ២០០០០៛
- ស្លឹកគ្រៃ, ជី, រំដេង, ខ្ទាយ, រមៀត តម្លៃសរុប ១៣០០០៛

---

**សរុបប្រាក់កម្រៃសួនរយៈពេល ៣ ខែ ២៤៤.៨៥០៛**

**ផលធៀបមុនចំណាយ ឬ ប្រាក់ចំណេញ ៤១៣៥០៛**

## VI-ផែនការ និងវិធីសាស្ត្រផ្សព្វផ្សាយ

ដើម្បីអនុវត្តនូវបទដ្ឋានបច្ចេកវិទ្យាសួនបន្លែគ្រួសារ ដែលហៅថា HomeVegetables Gardening អ្នកផ្សព្វផ្សាយទាំងអស់ ត្រូវអនុវត្តគោលការណ៍សំខាន់ៗដូចតទៅៈ

### ១-ការទំនាក់ទំនងអាជ្ញាធរមូលដ្ឋាន

ដំបូងត្រូវកំណត់យកតំបន់គោលដៅ ដែលគំរោងបានកំណត់ នូវចំនួនគ្រួសារពិតប្រាកដ ។ ត្រូវជួបពិគ្រោះយោបល់ផ្ទាល់ជាមួយអាជ្ញាធរដែនដី ជាពិសេសគឺភូមិដែលទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច និងកសិកម្ម គឺសិក្សាស្វែងយល់នូវព័ត៌មានទាក់ទងនិងសេដ្ឋកិច្ចកសិកម្ម ជំហានដំបូង ព្រមទាំងបង្ហាញនូវគំរោងការរបស់យើងដល់អ្នកគ្រប់គ្រង ក្នុងករណីចូលដល់ការព្រមព្រៀង គឺយើងស្នើសុំអោយថ្នាក់ដឹកនាំនោះ ធ្វើការអញ្ជើញ កសិករ ដែលមានលទ្ធភាពក្នុងការយកវិស័យកសិកម្មធ្វើជាមូលដ្ឋានសេដ្ឋកិច្ចនៃគ្រួសារ មកជួបជុំគ្នានៅកន្លែងណាមួយពិតប្រាកកដ ក្នុងរយៈពេល ២ ឬ ៣ ថ្ងៃបន្ទាប់ ។

### ២-របៀបជ្រើសរើសកសិករជាដៃគូ

ក្រោយពីបានកំណត់ទីតាំង និងពេលវេលាហើយ ប្រជាពលរដ្ឋបានជួបជុំទៅតាមការអញ្ជើញរបស់អាជ្ញាធរ ។ អ្នកផ្សព្វផ្សាយត្រូវសិក្សា និងប្រមូលព័ត៌មានពីអ្នកទាំងនោះ ក្នុងម្នាក់ៗព័ត៌មានត្រូវប្រមូលយកគឺ :

- ការប្រើប្រាស់បន្លែប្រចាំថ្ងៃ : តើសព្វថ្ងៃកសិករនិយមបរិភោគបន្លែឬទេ ? តើការបរិភោគបន្លែរាល់ថ្ងៃទិញពីផ្សារ ឬអ្នកជិតខាង ? តើពិបាកក្នុងការទិញដែរឬទេ ? ដូចជាខ្វះខាតថវិកាទិញ ផ្លូវឆ្ងាយចំណាយសោហ៊ុយ ឬបន្លែមិន សំបូរ ព្រមទាំងតម្លៃថ្លៃពេក ហើយប៉ាន់ស្មានចំណាយក្នុងមួយខែៗទៅលើបន្លែប៉ុន្មានរៀល ... ។

- បទពិសោធន៍ និងទំលាប់នៃការដាំដុះ : តើពីមុនរហូតមកទល់ពេលនេះ មានការដាំដុះបន្លែបន្តិចបន្តួចជុំវិញផ្ទះឬទេ ? ហើយការដាំដុះនោះ សម្រាប់បរិភោគ ឬលក់ទៅកាន់ទីផ្សារ?

តើប្រភេទបន្លែអ្វីខ្លះ ដែលកសិករធ្លាប់ដាំ និងនិយមប្រើ? ប្រសិនបើ គំរោងកម្មវិធីផ្តល់ជូននូវគ្រាប់ពូជសម្រាប់ដាំសំភារៈសម្រាប់ដាំដុះខ្លះៗ រួមជាមួយការបណ្តុះបណ្តាលផ្នែកទ្រឹស្តី និងអនុវត្តជាក់ស្តែងចំនួន ៤លើក តើលោកអ្នកចូលរួមឬទេ ?

ក្រោយពីទទួលបាននូវព័ត៌មានទាំងនោះ រួមជាមួយចំនួនគ្រួសារ ដែលមានចំណង់ចំណូលចិត្តរួចមក យើងត្រូវចុះទៅតាមលំនៅដ្ឋាននីមួយៗ ដោយពិនិត្យជាក់ស្តែងអំពី :

- ទិដ្ឋភាពជាក់ស្តែងជុំវិញផ្ទះ : ការដាំដុះដំណាំកន្លងមករបស់អ្នកគ្រប់ៗគ្នា ដែលជាសមាជិកចូលរួម បើមានប្រភេទដំណាំខ្លះ នៅដុះលូតលាស់យើងអាចចំណាត់ថ្នាក់ថា អ្នកនោះមានចរិតឧស្សាហ៍ព្យាយាម ។

- ពិនិត្យលើសក្តានុពលពីរយ៉ាងទៀតគឺ ទីកន្លែងដែលត្រូវកំណត់យកគឺ ផ្នែកចំហៀង ឬពីក្រោយផ្ទះធានាបាន

នូវការដាំដុះ ។ មួយផ្នែកទៀតជាប្រភពទឹក សម្រាប់ការស្រោចស្រព ជាពិសេសនូវរដូវប្រាំង ព្រោះដំណាំបន្លែវាត្រូវការទឹកជាបង្គួរ ទៅតាមប្រភេទដំណាំខ្លះ ។

- ផ្នែកធនធានផ្ទាល់របស់គាត់ : គឺកសិករ ឬមេគ្រួសារត្រូវមានកូនឈើ ឬ ឬស្សីសម្រាប់ធ្វើរបងព័ទ្ធជុំវិញសួន ឬអាចរកបាននូវចំណារដោតដំណាំ ធ្វើធ្នើរដំណាំ ចំបើងគ្របដី ព្រមទាំងជីកំប៉ុស្តិ៍ ឬ ជីលាមកសត្វសម្រាប់ដាក់ដំណាំ ។

## ៣-ការកំណត់ជារអាទិភាព នៃគ្រួសារជាដៃគូ

ក្រោយពីការទទួលបានទាំងព័តិមាន និងសក្តានុពលជាក់ស្តែង យើងធ្វើការសំរេចចិត្តកំណត់យកចំនួនកសិករអោយចូលធ្វើជាដៃគូក្នុងការបណ្តុះបណ្តាល និងគាំទ្រនាពេលខាងមុខ ចំនួនពី ៣ ទៅ ៥ គ្រួសារ ឬ ៣-៥ សួនបន្លែគ្រួសារក្នុង មួយភូមិ ។ ក្រោយពីការកំណត់ឈ្មោះបានហើយ ត្រូវបញ្ជាក់ប្រាប់ឱ្យគ្រួសារទាំងនោះ ត្រៀមលក្ខណៈដូចជា :

- បង្គោលរបងសួន ៣៥ ទៅ ៤០ បង្គោល
- បន្ទះឫស្សី ឬ កូនឈើធ្វើរបារព័ទ្ធជុំវិញសួន រួមទាំងចំណារដែកសម្រាប់ដោត ឬ ធ្វើធ្នើរដំណាំមួយចំនួន ។

## ៤- ការរៀបចំសួនតាមលំនៅដ្ឋាន

រយៈពេលមួយសប្តាហ៍ បន្ទាប់ពីកំណត់បាននូវចំនួនគ្រួសារ អ្នកផ្សព្វផ្សាយ ត្រូវកំណត់ពេលវេលាជាថ្មី ដើម្បីរៀបចំសួនតាមផ្ទះនីមួយៗ ក្នុងនោះអ្នកផ្សព្វផ្សាយត្រូវមានឧបករណ៍ទៅជាមួយគឺ រណាកាត់ ចបជីក ខ្សែម៉ែត្រ, ខ្សែបន្ទាត់, ចបកាប់ក្នុងការជួយចូលរួមដំណើរការរៀបចំ គឺធ្វើការវាស់វែងដាក់ប្លង់ ព្រមទាំងកំណត់ទំហំនៃសួននីមួយៗ ។ សួនទាំង ៣ ឬ ៥ ក្នុងមួយភូមិត្រូវប្រើប្រាស់រយៈពេល ៤ ទៅ ៧ថ្ងៃ ទើបចប់សព្វគ្រប់ ដោយឱ្យសមាជិកទាំងនោះចូលរួមធ្វើរួមគ្នាម្តងមួយៗ សួនទី ១ ដល់ទី ៣ ឬ ទី ៥ បន្ទាប់មកណែនាំឱ្យពួកគាត់កាប់ដីក្នុងសួនបំផុសឱ្យផុល ប្រមូលស្មៅចេញឱ្យស្អាតជាមុន ។

## ៥-ការណែនាំអនុវត្តជំហានដំបូង

ក្រោយពីការបង្កើតសួនហើយ យើងត្រូវប្រមូលម្ចាស់សួនទាំងនោះមកជួបជុំគ្នារយៈពេល ១ថ្ងៃ ដើម្បីបង្ហាត់បង្ហាញផ្ទាល់នូវវិធីសាស្រ្តក្នុងការបណ្តុះគ្រាប់ពូជ ក៏ដូចជាការដាំដុះនៅក្នុងសួនលើប្រភេទដំណាំដែលត្រូវដាំដោយគ្រាប់ផ្ទាល់ ឬ ដោយកំណាត់ទង ឬដើម ក្នុងនោះមាន :

- អោយកសិករដាំទឹកអោយពុះ មានទឹកត្រជាក់ មានធុងលាយទឹក និងធុងទឹកកកសម្រាប់ផ្អាប់ មានក្រណាត់ ស្អាតវិចខ្ចប់គ្រាប់ពូជ នៅថ្ងៃដំបូង ២ថ្ងៃបន្ទាប់មកត្រូវទៅជួបកសិករម្ចាស់សួន ដើម្បីណែនាំលាយ ដីបណ្តុះគ្រាប់ ឬ ត្រូវយកគ្រាប់ទៅដាំក្នុងសួន នៅលើរងនីមួយៗទៅតាមប្រភេទដំណាំ និងរងដាំដុះ ។

- ចុះដឹកនាំបណ្តុះ និងដាំក្នុងសួនទាំង ៣ ឬ ៥ ប៉ុន្តែមុននឹងដាំ ឬ បណ្តុះត្រូវអោយកសិករមានចំបើងស្ងួត ព្រម ទាំងកន្ទោងបណ្តុះជាមុន ។ ក្រោយពីបណ្តុះ និងដាំ ត្រូវណែនាំផ្ទាល់នូវរបៀបគ្របចំបើង, ស្រោចទឹក, ដករំលោះកូន ឬថែទាំបន្ត ។



**ការណែនាំបណ្តុះគ្រាប់ពូជបន្លែសម្រាប់ដាំក្នុងសួន**

## ៦. ការបណ្តុះបណ្តាលជាក្រុម

ការបណ្តុះបណ្តាលជាក្រុម ធ្វើឡើងជា ៣ លើក ដែលមានរយៈមួយខែម្តងៗ ចំនួន ៣ខែ ។ មុននឹងធ្វើការ បណ្តុះបណ្តាលរយៈពេល ៤-៥ថ្ងៃ គេត្រូវជូនដំណឹងដល់ផ្នែកដែលពាក់ព័ន្ធរួមជាមួយកសិករក្នុងភូមិ ដើម្បីកំណត់ បញ្ជាក់អំពីចំនួនសមាជិកចូលរួម ដែលហៅថាសិក្ខាសាលាបណ្តុះបណ្តាលសួនបន្លែគ្រួសារ ។ សមាជិកដែលចូលរួម លើកដំបូងត្រូវតែមានវត្តមានលើកទីពីរ និងលើកទីបី ព្រោះមេរៀនមានទំនាក់ទំនងពីដើមដល់ចប់ នៅតាមបទដ្ឋាននៃ សៀវភៅសួនបន្លែគ្រួសារ ពីគោលបំណងរហូតដល់ការសិរិតសំរាំងទុកពូជ និងការការពារដំណាំ ។

### វិធីសាស្ត្របង្រៀនគឺ :

- ពេលព្រឹក : ជាបទដ្ឋានទ្រឹស្តី នៃវគ្គនីមួយៗនៃ បអប
- ពេលល្ងាច : អញ្ជើញទៅតាមសួន ហើយពន្យល់ជាក់ស្តែងក្នុងសួន ដោយមានឧបករណ៍បង្ហាញគ្រាប់ គ្រាន់ ដូចជាគ្រាប់ពូជ ឧបករណ៍ថែទាំ សត្វល្អិតចង្រៃ ជំងឺផ្សេងៗលើដំណាំ ឬការគ្របគល់ ដំណាំ ព្រមទាំងការផ្លាស់ប្តូរមុខដំណាំ (សូមមើលកម្មវិធីការងារក្នុងតារាងទី ៨)



**សកម្មភាពអនុវត្តជាក់ស្តែងក្នុងសួន**

### តារាងទី ៨ កម្មវិធីអនុវត្តសួនបន្លែ

| **កាលបរិច្ឆេទ** | **ខ្លឹមសារការងារ** | **ប្រភពផ្សេងៗ** |
|---|---|---|
| កម្មវិធីទី ១ | សុំជួបគណៈកម្មការអភិវឌ្ឍន៏ភូមិ ឬ លោកមេភូមិ | អ្នកផ្សព្វផ្សាយ និងអាជ្ញាធរ |
| កម្មវិធីទី ២ | ជួបជុំកសិករក្នុងមូលដ្ឋាន និងកំណត់ជ្រើសរើស | អ្នកផ្សព្វផ្សាយ អាជ្ញាធរ និងកសិករចូលរួម |
| កម្មវិធីទី ៣ | ការរៀបចំសួនបន្លែតាមគ្រួសារនីមួយៗដែលបានកំណត់យក | អ្នកផ្សព្វផ្សាយ និងម្ចាស់សួន |
| កម្មវិធីទី ៤ | ជួបជុំកសិករម្ចាស់សួនបង្ហាញនូវវិធីសាស្ត្របណ្តុះកូនដំណាំ និងដាំ | អ្នកផ្សព្វផ្សាយឧបករណ៍បង្ហាញ និងកសិករ |
| កម្មវិធីទី ៥ | - បណ្តុះបណ្តាលខែទី១ (៣០ថ្ងៃ ក្រោយដាំ)<br>- បណ្តុះបណ្តាលខែទី២ (៦០ថ្ងៃ ក្រោយដាំ)<br>- បណ្តុះបណ្តាលខែទី៣ (៩០ថ្ងៃ ក្រោយដាំ) | អ្នកផ្សព្វផ្សាយ និងក្រុមអ្នកចូលរួមដែលនឹងពាក់ព័ន្ធ ព្រមទាំងម្ចាស់សួន រួមទាំងវិភាគសេដ្ឋកិច្ច |
| | គ្រោងចំណាយសំភារៈបណ្តុះបណ្តាល<br>- ក្រដាសសរសេរ ១ដុំ<br>- ហ្វឺតសរសេរ ១ប្រអប់<br>- ពូជដំណាំ ១៦មុខ<br>- កែវពង្រីកខ្នាតធំ ១សម្រាប់<br>- ឧបករណ៍បង្ហាញបណ្តុះពូជ (១០សម្រាប់) | <br>តម្លៃ ២០០០០រ<br>តម្លៃ ១៥០០០រ<br>តម្លៃ ២០០០០រ<br>តម្លៃ ៣០០០០រ<br>តម្លៃ ៤០០០០រ |
| | **សរុប** | **១២៥.០០០រ** |

## ៧_ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាម៉ីអង្គភាព ។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យារបស់នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម។

| **ថវិកា និង ការសន្មត់** | ចំនួន/តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនចូលរួមពីកសិករគំរូ (ខ) | កំលាំងពលកម្ម សួនបន្លែ និង សំភារៈសម្រាប់ដាំបន្លែ |
| ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ (គ) | $១២០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- ឯកសារ ឬ ការណែនាំពីបច្ចេកវិទ្យា បអប | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ង)<br>- អាហារសំរ៉ន់ | $៩០ |
| ទិវាស្រែកសិករ- អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែកសិករ - សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| **សរុប** | **$៣៦១** |

**ការសន្មត់ប្រើប្រាស់មាន:**

ក. ក្នុង បអប មួយ មានក្រុមកសិករ (៣០នាក់) ក្នុងនោះមានកសិករគំរូ ២នាក់ ដែលធ្វើបង្ហាញ ២កន្លែង

ខ. ទុនចូលរួមរបស់កសិករ សួនទំហំ៦០ម$^{២}$ ឧបករណ៍ផ្សេងៗ ទឹកសម្រាប់ស្រោចស្រព ជីកំប៉ុស្តិ៍ ធុងសំរាប់លាយជី និងកំលាំងពលកម្ម

គ. ទុនសម្រាប់ធ្វើបង្ហាញអំពីសួនបន្លែគ្រួសារ ដោយមានបញ្ចូលទាំង គ្រាប់ពូជបន្លែ/កូនបណ្តុះ = $១០ ថាស ឬស្លក សម្រាប់បណ្តុះកូន= $៥ សំភារៈសម្រាប់ធ្វើរបង =$២០ ធុងផ្កាឈូកស្រោចនិងឧបករណ៍ផ្សេងៗ = $១០ សំណាញ់នីឡុង= $៥ ជីកំប៉ុស្តិ៍/គីមី= $១០ សរុបរួម= $៦០ ទុនសម្រាប់ពីរកន្លែង =$៦០ x ២= $១២០។

ឃ. ឯកសារបណ្ដុះបណ្ដាលបច្ចេកវិទ្យា មានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្ត្របង្រៀន

ង. ការបណ្ដុះបណ្ដាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្ដិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ច. ទិវាស្រែកសិករមានកន្លះថ្ងៃមានតែម្ដងក្នុងវគ្គណាមួយក្នុងចំណោមវគ្គទាំងបី និងអាចមានការចូលរួមពីកសិករនៅ ក្បែរៗ ភូមិប្រហែល ៤០ ទៅ ៦០នាក់។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ (មេក្រូ) តង់ និងផ្ទាំងបដារូបភាពផ្សេងៗទៀត

ជ. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ ឬ ការចាប់ផ្ដើម ឬ ការត្រួតពិនិត្យតាមដាន។ ចំពោះការបណ្ដុះបណ្ដាលសម្រាប់ ៣វគ្គ ផ្ដល់អោយ ៦ថ្ងៃ និងទិវាស្រែផ្ដល់អោយ ២ថ្ងៃ។

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. អ្នកឯកទេសជំនាញរបស់មន្ទីរកសិកម្មខេត្ត ជាអ្នកផ្ដល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្ដុះបណ្ដាល បអប

## ឧបសម្ព័ន្ធ: ការជម្រើស និង ប្រើប្រាស់បន្លែសំបូរជីវជាតិ

ព្រះរាជាណាចក្រកម្ពុជាយើង ក៏ជាប្រទេសមួយដែលសំបូរទៅដោយធនធានដំណាំបន្លែជាបង្គួរ ប្រហែលគ្នាទៅនឹងប្រទេសឯទៀត នៅទ្វីបអាស៊ីយើងនេះ ក្នុងនោះមានប្រភេទបន្លែជាងមួយរយប្រភេទដែលដាំ និង ដុះដោយធម្មជាតិ ហើយត្រូវបានយកមកប្រើប្រាស់ ។

### ១-ការបែងចែកក្រុមបន្លែ

តាមប្រភពឯកសារពីវិទ្យាស្ថានស្រាវជ្រាវដំណាំបន្លែអន្តរជាតិ ដែលហៅថា AVRDC ក្នុងឆ្នាំ ១៩៩០ ប្រភពឯកសារដំណាំបន្លែឈ្មោះ ប្រូសៀវ ឆ្នាំ ១៩៩៤ ប្រភពឯកសារពីប្រទេសចិនឆ្នាំ ២00២ ប្រភពឯកសារពីប្រទេសថៃឆ្នាំ ២00៤ ស្តីអំពីប្រភេទបន្លែចំរុះ ហៅថា Indigenous Vegetables ក៏ដូចជាការយល់ដឹងបន្ថែមនូវក្រុមបន្លែ គេធ្វើការបែងចែកបន្លែជា ៣ក្រុមធំៗ ទៅតាមលក្ខណៈសម្បត្តិនៃការប្រើប្រាស់ក្នុងនោះរួមមាន :



**ប្រភេទបន្លែចំរុះដែលបានប្រើប្រាស់លើទីផ្សារ**

#### ១-១-ក្រុមបន្លែយកផ្លែដែលសំបូរជីវជាតិ

បន្លែយកផ្លែ គឺជាប្រភេទដំណាំដែលគេយកផ្លែមកធ្វើជាបន្លែសម្រាប់បរិភោគបាន បន្លែខ្លះបរិភោគឆៅ បន្លែខ្លះទៀតបរិភោគឆ្អិន ដូចជា : ផ្លែម្ទេស ផ្លែត្រប់ ផ្លែប៉េងប៉ោះ ផ្លែត្រសក់ផ្អ ឬ ចំណារ ផ្លែត្រសក់ស្រូវ ផ្លែនទោងមូល ផ្លែនទោងជ្រុង ផ្លែពាយជ្រុង ផ្លែអូក្រា ឬ ផ្លែសណ្តែកកួរ ផ្លែសណ្តែកហោឡាំងតាវ ផ្លែល្ពៅ ផ្លែត្រឡាច ផ្លែម្រះ ទោះប្រភេទខ្លះស្ថិតនៅក្នុងអំបូរ ដំណាំឈើហូបផ្លែក៏ដោយ ។



**ប្រភេទបន្លែផ្លែ សំបូរជីវជាតិ កសិករងាយរកពូជបាន**

### ១-២-ក្រុមបន្លែដើម ស្លឹក ផ្កា សំបូរដោយជីវជាតិ

មានដំណាំ និង រុក្ខជាតិព្រៃមួយចំនួនដែលបានដាំ និង ដុះដោយធម្មជាតិ ប៉ុន្តែ ផ្នែកដើម ស្លឹក និង ផ្ការបស់វាត្រូវបានគេប្រើប្រាស់ធ្វើបន្លែក្នុងនោះមាន : ដំណាំក្រុមអំបូរស្ពៃ អំបូរខាត់ណា សាលាដ ជីតាំងអោ ជីវ៉ាន់ស៊ុយ ភ្លៅកង្កែប កំព្លោត ត្រកួន ជីរណា ឬជីបារាំង ជីនាងវង ជីម្រះព្រៅ ជីអង្កាម ជីសាំងត្រហ៊ុំ ខ្ទឹមស្លឹក ដើមគូឆាយ ត្រួយម្រុំ ត្រួយនិងផ្កាអង្គ្រៀវដី ផ្កាអង្កាញ់ ត្រួយកន្ធំថេត ត្រួយស្លឹកបាស ត្រួយជន្លង់ ធាងក្តាត ធាងត្រាវ សណ្តែកបណ្តុះ ត្រួយផ្ទី ត្រួយស្ពំ ត្រួយងប់ ។



**ប្រភេទបន្លែស្លឹកដែលសំបូរជីវជាតិ កសិករងាយរកពូជបាន**

### ១-៣-ក្រុមបន្លែមើមដែលពេញនិយមប្រើប្រាស់សំបូរជីវជាតិ

បន្លែមើមក៏ដូចជា បន្លែផ្លែ និង ស្លឹកដែរ មួយចំនួនត្រូវបានគេដាំ និង ខ្លះទៀតដុះលូតលាស់ក្នុងព្រៃ ធម្មជាតិ ក្នុងនោះមាន : ការ៉ុត ឆៃថាវ ដំឡូងបារាំង ដំឡូងជ្វា ដំឡូងដូង ដំឡូងឈាមមាន់ ដំឡូងដៃខ្លា ដំឡូងបាស ដំឡូងឈើ ដំឡូងជ្រូក ដំឡូងខ្សារ ដំឡូងត្រែង ដំឡូងជ្រាំ ដំឡូងទៀន មើមត្រាវ មើមថ្ងូរ មើមខ្ទឹមស ខ្ទឹមក្រហម ខ្ទឹមបារាំង មើមឈូក ប៊ិគក់ ដំឡូងពស់ ខាត់ណាមើម ។

## ២-ការប្រើប្រាស់បន្លែនីមួយៗ

បន្លែទាំង៣ក្រុមធំៗ ដែលបានបកស្រាយមកខាងលើ សុទ្ធសឹងមានអត្ថប្រយោជន៏ក្នុងការប្រើប្រាស់ ប្រចាំ

ថ្ងៃ ហើយផ្តល់នូវឱជារស រួមជាមួយប្រភពប្រូតេអ៊ីន វីតាមីន សារធាតុចិញ្ចឹម ផ្សេងៗទៀត ។ ផ្នែកនីមួយៗដែលត្រូវប្រើប្រាស់ និងវិធីសាស្ត្រនៃការប្រើប្រាស់ ដូចមានក្នុងតារាងទី១ ខាងក្រោម :

## តារាងទី១: ប្រភេទ និង វិធីសាស្ត្រក្នុងការប្រើប្រាស់

| លេខរៀង | ឈ្មោះដំណាំ | ផ្នែកប្រើប្រាស់ | វិធីសាស្ត្រប្រើ | | | |
|---|---|---|---|---|---|---|
| | | | ឆៅឬស្រស់ | ចំអិន | ជ្រក់ | ក្រៀម |
| ១ | ដំណាំម្ទេស | ផ្លែ និង ត្រួយ | ផ្លែ | ទ្រួយ | ផ្លែ | ផ្លែ |
| ២ | ដំណាំត្រប់ | ផ្លែ | ផ្លែ | ផ្លែ | ផ្លែ | 00 |
| ៣ | ប៉េងប៉ោះ | ផ្លែ និង ត្រួយ | ផ្លែ | ផ្លែ និងត្រួយ | 0 | ផ្លែ |
| ៤ | ត្រសក់ផ្អែ | ផ្លែ | ផ្លែ | ផ្លែ | ផ្លែ | 00 |
| ៥ | ត្រសក់ស្រូវ | ផ្លែ | ផ្លែ | ផ្លែ | ផ្លែ | ផ្លែ |
| ៦ | ននោងមូល | ផ្លែ និង ត្រួយ | 0 | ផ្លែ និងត្រួយ | 0 | 00 |
| ៧ | ននោងជ្រុង | ផ្លែ និង ត្រួយ | 0 | ផ្លែ និងត្រួយ | 0 | 00 |
| ៨ | ពពាយជ្រុង | ផ្លែខ្ចីៗ | ផ្លែស្រស់ | ផ្លែស្រស់ | 00 | 00 |
| ៩ | ផ្លែអូត្រា | ផ្លែខ្ចីៗ | 00 | ផ្លែខ្ចីៗ | 00 | 00 |
| ១០ | សណ្តែកគួរ | ផ្លែ ឬ កួរខ្ចី | កួរស្រស់ | កួរខ្ចី | កួរខ្ចី | 00 |
| ១១ | សណ្តែកហោ ឡាំងតាវ | កួរខ្ចី | 00 | កួរខ្ចី | កួរខ្ចី | គ្រាប់ |
| ១២ | ផ្លែល្ពៅ | ផ្លែខ្ចី ទុំ | ផ្លែខ្ចី ទុំ | ផ្លែខ្ចី | ផ្លែខ្ចី | 00 |
| ១៣ | ផ្លែឪឡឹក | ផ្លែខ្ចី ទុំ | ផ្លែទុំ | ផ្លែខ្ចី | ផ្លែខ្ចី | 00 |
| ១៤ | ផ្លែត្រឡាច | ផ្លែខ្ចី ទុំ | 00 | ផ្លែខ្ចី | ផ្លែខ្ចី | ផ្លែទុំ |
| ១៥ | ដំណាំម្រះ | ត្រួយ ផ្លែខ្ចី | 00 | ផ្លែ ត្រួយ | 00 | 00 |
| ១៦ | ដំណាំស្វាយ | ត្រួយ ផ្លែខ្ចី ទុំ | ផ្លែត្រួយ | ផ្លែ | ផ្លែខ្ចី | 00 |
| ១៧ | ដំណាំអំបូរស្ពៃ | ស្លឹក ដើម ផ្កា | ស្លឹក | ស្លឹក | ស្លឹក | 00 |
| ១៨ | ដំណាំអំបូរខាត់ណា | ស្លឹកខ្ចី | 00 | ស្លឹក ដើម ផ្កា | ស្លឹក | ស្លឹក |
| ១៩ | ដំណាំសាលាដ | ស្លឹកខ្ចី | ស្លឹក | ស្លឹក | 00 | 00 |
| ២០ | ជីតាំងឱ | ស្លឹក ដើម | 00 | ស្លឹក ដើម | 00 | 00 |
| ២១ | ជីវ៉ាន់ស៊ុយ | ស្លឹក ដើម | ស្លឹកខ្ចីៗ | ស្លឹកខ្ចីៗ | 00 | 00 |
| ២២ | ត្រកួនកង្កែប | ស្លឹក ដើម | ស្លឹកដើមខ្ចីៗ | ស្លឹក ដើម | 00 | 00 |
| ២៣ | ដើមកញ្ឆែត | ស្លឹក ដើម | ដើមស្រស់ | ស្លឹក ដើម | 00 | 00 |

| | | | | | | |
|---|---|---|---|---|---|---|
| ២៤ | ត្រកួន | ស្លឹក ដើម | ត្រួយ | ត្រួយ | ត្រួយ | ០០ |
| ២៥ | ជីរណា | ស្លឹក | ស្លឹកខ្ចីៗ | ស្លឹកខ្ចី | ០០ | ០០ |
| ២៦ | ជីនាងវង | ស្លឹក | ត្រួយខ្ចីៗ | ត្រួយខ្ចី | ០០ | ០០ |
| ២៧ | ជីម្រះព្រៅ | ស្លឹក | ០០ | ត្រួយខ្ចី | ០០ | ០០ |
| ២៨ | ជីអង្កាម | ស្លឹក | ត្រួយខ្ចីៗ | ០០ | ០០ | ០០ |
| ២៩ | ជីសាំងត្រហុំ | ស្លឹក | ត្រួយខ្ចីៗ | ០០ | ០០ | ០០ |
| ៣០ | ខ្ទឹមស្លឹក | ស្លឹក គល់ | ស្លឹកខ្ចីនិងគល់ | ស្លឹក គល់ | ០០ | ០០ |
| ៣១ | គុយឆាយ | ស្លឹក ផ្កា | ០០ | ស្លឹក ផ្កា | ០០ | ០០ |
| ៣២ | ត្រួយម្រុំ | ត្រួយ | ០០ | ត្រួយ | ០០ | ០០ |
| ៣៣ | អង្កៀរដី | ត្រួយ ផ្កា | ០០ | ត្រួយ ផ្កា | ០០ | ០០ |
| ៣៤ | ដើមអង្កាញ់ | ផ្កា | ០០ | ផ្កា | ០០ | ០០ |
| ៣៥ | កន្ទំថេត | ស្លឹក ផ្លែ ខ្ចី | ត្រួយ | ០០ | ០០ | ០០ |
| ៣៦ | ដើមស្លឹកបាស់ | ស្លឹក | ០០ | ស្លឹកខ្ចី | ០០ | ០០ |
| ៣៧ | ត្រួយជន្លង់ | ស្លឹក | ០០ | ស្លឹកខ្ចី | ០០ | ០០ |
| ៣៨ | ធាងក្ដាត | ធាង | ០០ | ធាងខ្ចីៗ | ០០ | ០០ |
| ៣៩ | ព្រលិតរំចង់ | ដើម | ដើមខ្ចី | ដើមខ្ចី | ០០ | ០០ |
| ៤០ | ក្រអៅឈូក | ពន្លកខ្នែង | ខ្នែងខ្ចី | ខ្នែងខ្ចី | ០០ | ០០ |
| ៤១ | សណ្ដែកបណ្ដុះ | ពន្លក | ពន្លកខ្ចី | ពន្លកខ្ចី | ០០ | ០០ |
| ៤២ | ត្រួយផ្ទី | ស្លឹក | ០០ | ពន្លកខ្ចី | ០០ | ០០ |
| ៤៣ | ត្រួយងប់ | ស្លឹក | ០០ | ត្រួយខ្ចី | ០០ | ០០ |
| ៤៤ | ត្រួយស្ពំ | ស្លឹក | ០០ | ត្រួយខ្ចី | ០០ | ០០ |
| ៤៥ | ខាត់ណាមើម | ស្លឹក មើម | ០០ | ស្លឹក មើម | ០០ | ០០ |
| ៤៦ | ការ៉ុត | មើម ស្លឹក | ត្រួយ មើម | មើម | មើម | ០០ |
| ៤៧ | ផ្អែថាវ | មើម ស្លឹក | ០០ | មើម ស្លឹក | មើម ស្លឹក | មើម |
| ៤៨ | ដំឡូងបារាំង | មើម | ០០ | មើម | ០០ | មើម |
| ៤៩ | ដំឡូងឈ្វា | មើម ត្រួយ | ០០ | មើម ត្រួយ | ០០ | មើម |
| ៥០ | ដំឡូងដួង | មើម | ០០ | មើម | ០០ | ០០ |
| ៥១ | ដំឡូងឈាមមាន់ | មើម | ០០ | មើម | ០០ | ០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥២ | ដំឡូងដៃខ្លា | មើម | ០០ | មើម | ០០ | ០០ |
| ៥៣ | ដំឡូងបាស | មើម | ០០ | មើម | ០០ | ០០ |
| ៥៤ | ដំឡូងឈើ | មើម ត្រួយ | ០០ | ដើម ត្រួយ | ០០ | មើម |
| ៥៥ | ដំឡូងជ្រូក | មើម | ០០ | មើម | ០០ | ០០ |
| ៥៦ | ដំឡូងខ្យារ | មើម | ០០ | មើម | ០០ | ០០ |
| ៥៧ | ដំឡូងត្រែង | មើម | ០០ | មើម | ០០ | ០០ |
| ៥៨ | ដំឡូងជ្រាំ | មើម | ០០ | មើម | ០០ | មើម |
| ៥៩ | ដំឡូងទៀន | មើម | ០០ | មើម | ០០ | ០០ |
| ៦០ | ដំណាំត្រាវ | មើម | ០០ | មើម ធាង | ០០ | មើម |
| ៦១ | មើមថ្វរ | មើម | ០០ | មើម | ០០ | ០០ |
| ៦២ | ខ្ទឹមស | ដើម មើម | ០០ | មើម ដើម | មើម | មើម |
| ៦៣ | ខ្ទឹមក្រហម | ដើម មើម | ០០ | មើម ដើម | ០០ | មើម |
| ៦៤ | ខ្ទឹមបារាំង | ដើម មើម | ០០ | មើម ដើម | មើម | មើម |
| ៦៥ | មើមឈូក | ពន្លកខ្ចី | ពន្លកខ្ចី | ពន្លកខ្ចី | ពន្លកខ្ចី | ០០ |
| ៦៦ | ប៊ុគក់ | មើម | មើម | មើម | ០០ | ០០ |
| ៦៧ | ដំឡូងពស់ | មើម | ០០ | មើម | ០០ | ០០ |

## ៣.សារធាតុសំខាន់ៗដែលសរីរាង្គមនុស្សត្រូវការ

ដើម្បីអោយសរីរាង្គកាយលូតលាស់បានល្អ សុខភាពប្រព្រឹត្តទៅបានប្រកបដោយថាមពល មនុស្សម្នាក់ៗត្រូវការបរិភោគប្រភេទអាហារជាច្រើនមុខ ដូចជា ជាតិសាច់ ជាតិស្ករ ជាតិម្សៅ វីតាមីន និងប្រភេទរ៉ែរួមផ្សំ ។ ក្នុងនោះតាមការអះអាងរបស់ក្រុមជំនាញការមកពីអង្គការស្បៀង (FAO) និងកសិកម្មនៃអង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៧២ និងលទ្ធផលស្រាវជ្រាវរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ដំណាំបន្លែអាស៊ី (AVRDC) ក្នុងឆ្នាំ ១៩៩៨ អោយដឹងថា : មនុស្សម្នាក់មានទំងន់ ជាមធ្យម ៥៥ គ.ក្រ ក្នុងមួយថ្ងៃគេត្រូវការបរិភោគជាតិៈ សាច់ទំងន់ ៤៦ក្រាម វីតាមីនអា (A) ទំងន់១,៥ មីលីក្រាម វីតាមីន $B_1$ ១,០ មីលីក្រាម វីតាមីន $B_2$ ទំងន់ ១,៥ មីលីក្រាម វីតាមីន C ទំងន់ ៣០ មីលីក្រាម និងជាតិ ដែកទំងន់ ៩ មីលីក្រាម កាល់ស្យូម ៥០០ មីលីក្រាម ។

ដោយយោលទៅលើតំរូវការរបស់សរីរាង្គនៃមនុស្ស អត្ថបទនេះសូមធ្វើការណែនាំនូវប្រភេទសារធាតុនីមួយៗ ដែលមាននៅក្នុងក្រុមបន្លែទាំង ៣ ដូចតទៅ :

## ៣-១-ប្រភេទបន្លែផ្លែដែលសំខាន់ៗ :

បន្លែយកផ្លែដែលលើកយកមកបកស្រាយ អោយយល់ដឹង គឺភាគច្រើន ដែលប្រជាពលរដ្ឋកម្ពុជានិយមប្រើប្រាស់ជាងគេទាំងឆៅ និងឆ្អិនក្នុងទំងន់ ១០០ក្រាម (១ខាំ) ដូចជា : ម្ទេសផ្លោក ផ្លែត្រប់ ផ្លែប៉េងប៉ោះ ផ្លែត្រសក់ចំណារ ផ្លែត្រសក់ស្រូវ ផ្លែម្រះ ផ្លែននោងមូល ផ្លែននោងវែង ផ្លែសណ្តែកកួរ ផ្លែត្រឡាច ផ្លែពោយជ្រុង ផ្លែល្ហុង ផ្លែឃ្លោក ផ្លែល្ពៅ បានផ្តល់នូវសារធាតុសំខាន់ៗជាច្រើន ដូចមានក្នុងតារាងទី២ ខាងក្រោម:

**តារាងទី២ : សារធាតុសំខាន់ៗក្នុងទំងន់ ១០០ក្រាម បរិភោគបាន( ប្រភព FAO 1994 )**

| បន្លែ | ប្រភេទ បរិភោគ | ទំងន់នៃសារធាតុសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ប្រូតេអ៊ីន ក្រាម | វីតាមីន A មីក្រូក្រាម | វីតាមីន $B_1$ មក្រ | វីតាមីន $B_2$ មក្រ | វីតាមីន C មក្រ | ជាតិដែក មក្រ | កាល់ស្យូម មក្រ |
| ម្ទេសផ្លោក | ឆៅ<br>ចំអិន | ១,៣<br>០,៩ | ១៧៥០<br>១៩៥ | ០,០៧<br>០,០៣ | ០,០៨<br>០,០៣ | ០,៨០<br>០,៤០ | ០,៩<br>០,៨ | ១២<br>៨ |
| ត្រប់ | ឆៅ<br>ចំអិន | ១,៦<br>១,០ | ៥០<br>៥០ | ០,០៨<br>០,០៤ | ០,០៧<br>០,០៤ | ០,៧០<br>០,៥ | ០,៩<br>០,៥ | ២២<br>៤៣ |
| ប៉េងប៉ោះ | ឆៅ<br>ចំអិន | ១,២<br>០,៦ | ៥០៥<br>១៩០ | ០,០៦<br>០,៣២ | ០,០៤<br>០០ | ០,៦<br>០,៦ | ០,៦<br>៣,៣ | ៧<br>៨៦ |
| ត្រសក់ចំណារ | ឆៅ<br>ចំអិន | ០,៦<br>១,១ | ៨៥<br>១៥ | ០,០៣<br>០,០២ | ០,០៤<br>០,០៦ | ០,២០<br>០,៥០ | ០,៤<br>០,៤ | ២១<br>៦៨ |
| ត្រសក់ស្រូវ | ឆៅ<br>ចំអិន | ១,០<br>០,៧ | ០០<br>០០ | ០,០២<br>០,០១ | ០,០២<br>០,០៣ | ០,២<br>០០ | ០,៤<br>៤,២ | ៣០<br>៧៤ |
| ផ្លែម្រះ | ចំអិន | ០,៨ | ១១០ | ០,០៦ | ០,០៤ | ០,៣ | ២,៣០ | ២៦ |
| ននោងមូល | ចំអិន | ១,១០ | ១៧០ | ០,០៣ | ០,០៤ | ០,៣០ | ០,៧ | ២ |
| ននោងជ្រុង | ចំអិន | ០,៧ | ៣០០ | ០,០៣ | ០,០៣ | ០,២ | ០,៥០ | ២៥ |
| សណ្តែកកួរ | ឆៅ<br>ចំអិន | ៣,០<br>២,៧០ | ២២៥<br>២២៥ | ០,១២<br>០,០៦ | ០,១១<br>០,០៩ | ១,០<br>០,៧ | ០៧<br>០,៧ | ៤៤<br>៥៥ |
| ត្រឡាច | ចំអិន | ០,៥ | ៥ | ០,០៣ | ០,០៣ | ០,២ | ០,៤ | ១៧ |
| ផ្លែល្ហុង | ឆៅ<br>ចំអិន | ១,០<br>០,៥ | ១៥<br>៧១០ | ០,០២<br>០,០៣ | ០,០៣<br>០,០៥ | ០,៣<br>០,៤ | ០,៣<br>០,៧ | ៣៨<br>២៤ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ផ្លែឃ្លោក | ចំអិន | ០,៦ | ១០ | ០,០៣ | ០,០៣ | ០,៤ | ០,០៤ | ១៤ |
| ផ្លែល្ពៅ | ចំអិន | ០,៧ | ៧៨៥ | ០,០៣ | ០,០៤ | ០,៥ | ០,៧ | ២៤ |

- កំណត់សំគាល់ - ក្រ ទំងន់ជាក្រាម
  - មក្រូក្រ ទំងន់ជាមីក្រូក្រាម
  - មក្រ ទំងន់ជាមីលីក្រាម

# អត្ថបទដកស្រង់

១-ទិន្នន័យពិសោធន៍នៅស្ថានីយ៍ពិសោធន៍ស្រាវជ្រាវដំណាំបន្លែក្បាលកោះ ដោយក្រុមការងារពិសោធន៍ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០០៤ ។

២-សៀវភៅអត្ថប្រយោជន៍ដំណាំបន្លែ ដើម្បីសុខភាពរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៧២ ។

៣-សៀវភៅប្រភពនៃដំណាំបន្លែរបស់លោកបណ្ឌិត កាសេម ឆ្នាំ ១៩៩៤ ។

៤-សៀវភៅស្តីអំពីជំងឺ សត្វល្អិត និង វិធានការការពារ-កំចាត់របស់លោកបណ្ឌិត តាឡឹកា ឆ្នាំ ១៩៩៦ ។

៥-លទ្ធផលស្រាវជ្រាវថ្មីរបស់មជ្ឈមណ្ឌលស្រាវជ្រាវដំណាំបន្លែអាស៊ី ក្នុងឆ្នាំ ២០០៤ ។

៦-អត្ថបទគំរោងការស្រាវជ្រាវរបស់ ADB-AVRDC-RETA ៦០៦៧ ឆ្នាំ ២០០៣-២០០៥ ។


**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ : ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល : kunso@camnet.com.kh ឬ mak_soeun@camnet.com.kh